ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ

# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"

## សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩**

**សវនាការលើកទី៦០**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីសឺ

*(Ms. Natacha Wexels-Riser)*

លោក ម៉ាតូ គ្រីប្ពារ *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វាំងសង់ ដឺវ៉ាយឌ៍ ដេស្មាឯល

*(Mr. Vincent DE WILDE D'ESTMAEL)*

លោក ប៉ាក់ ចន្ទលីណូ

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារេស

*(Marie-Paule CANIZARES)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ម៉ុច សុវណ្ណារី

កញ្ញា ទី ស្រ៊ីនណា

លោក យ៉ុង ផានិត

លោកស្រី ស៊ីលឃីស្ទូត ហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស

*(Ms. Fabienne Trusse-Naprous)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# ឧបសម្ព័ន្ធ

## ដើមបណ្តឹងរដ្ឋប្បវេណី

### លោកស្រី អន់តូនីញ៉ា ត្វឡុង (ជូឡុង)

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ២

### លោកស្រី ហាវ សោភា

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ២៨
សួរដោយ លោក អាឡាំង វែ៉នណឺ ផ្តើមពី ........................................ ទំព័រ ៣១

### លោកស្រី សូ សូង

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ៤៨
សួរដោយ កញ្ញា ម៉ុច សុវណ្ណារី ផ្តើមពី ........................................ ទំព័រ ៥៦
សួរដោយ លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯល ផ្តើមពី ........................................ ទំព័រ ៦៤
សួរដោយ លោក ការ សាវុត្ថ ផ្តើមពី ........................................ ទំព័រ ៦៦
សួរដោយ លោកស្រ ម៉ារីប៉ូល កានីហ្សារេស ផ្តើមពី ........................................ ទំព័រ ៦៧

### លោក នេត ផល្លី

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ៧០
សួរដោយ លោក អាឡាំង វែ៉នណឺ ផ្តើមពី ........................................ ទំព័រ ៧៣
សួរដោយ លោក សេង ប៊ុនឃាង ផ្តើមពី ........................................ ទំព័រ ៨២

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោកស្រី ម៉ារីប៉ូល កានីហ្សារេស | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោកស្រី ហាវ សោភា | ខ្មែរ |
| លោក ឌឺ វ៉ាយថ៍ ដេស្មាងល | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ | បារាំង |
| កញ្ញា ម៉ុច សុវណ្ណារី | ខ្មែរ |
| លោក នេត ផល្លី | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |
| លោកស្រី សូ សូង | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី | អង់គ្លេស |
| លោកស្រី ត្សូឡុង អង់តូនីញ៉ា | បារាំង |
| លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស | បារាំង |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលមកកាន់បន្ទប់សវនាការ)*

[០៩:០៧:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ ហើយតាមកាលវិភាគដែលបានគ្រោងទុកថ្ងៃនេះគឺ ការស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយដោយសារមានការប្រែប្រួល ថ្ងៃនេះអង្គជំនុំជម្រះមានការកំណត់នូវកាលវិភាគស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួនរូប ។

ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលត្រូវបានកោះអញ្ជើញចូលរួមក្នុងកិច្ចដំណើរការសវនការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់ចម្លើយនៅក្នុងថ្ងៃនេះ លោកស្រី ត្យូឡុង អង់តូនីញ៉ា លោកស្រី ហាវ សោភា, លោកស្រី សូ សួង, លោក នេត ផល្លី មានវត្តមាន ។ ខ្ញុំបានត្រួតពិនិត្យអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីរួចរាល់ហើយ រង់ចាំការកហៅពីអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

មន្ត្រី-- សូមអញ្ជើញមេធាវី ស្ទូតហ្សីនស្គី ។

**លោកស្រី ស៊ីលយ៉ា ស្ទូតហ្សីនស្គី៖**

អរុណលោកប្រធាន លោក លោកស្រីចៅក្រម! ខ្ញុំចង់ជម្រាបថាកូនក្តីរបស់ខ្ញុំគឺ E2/77 និងមិនមកធ្វើសេចក្តីថ្លែងការណ៍នោះទេ ដែលយើងបានរៀបគ្រោងសម្រាប់សប្តាហ៍នេះ ។ ដោយសារតែមានហេតុការណ៍មួយគឺ គាត់ទទួលការប្រព្រឹត្តិមិនសមគួរដោយខាងការិយាល័យសហចៅក្រមស៊ើបអង្កេត។ ដូច្នេះហើយគឺគាត់មិនអាចចូលរួមមកផ្តល់សេចក្តីថ្លែងការណ៍នៅទីនេះទេ ។ នេះជាព័ត៌មានដែលខ្ញុំចង់ជម្រាបជូនអង្គសវនាការជ្រាប ។ សូមអរគុណ ។

[០៩:១០:១៥]

**ប្រធានអង្គជំនុំ៖**

អរគុណ មេធាវីដែលបានផ្តល់ព័ត៌មានអំពីការលះបង់ក្នុងការមិនមកធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះរបស់ដើមបណ្តឹងរដ្ឋប្បវេណីE2/77 នេះ ។ ដើម្បីទុកលទ្ធភាពដល់អង្គជំនុំជម្រះរៀបចំនូវកាលវិភាគ ដើម្បីដំណើរការសវនាការឲ្យបានល្អប្រសើរក្នុងការគ្រប់គ្រង និងការចាត់ចែងពេលវេលានៅក្នុងកិច្ចដំណើរការនេះ ។

មន្ត្រីតុលាការអញ្ជើញលោកស្រី ជូឡុង អង់តូនីញ៉ា មកកាន់ដៅអីដែលបានរៀបចំទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះ ។

*(លោកស្រី ជូឡុង អង់តូនីញ៉ា ចូលកាន់បន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម៖**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកស្រីឈ្មោះ ជូឡុង អង់តូនីញ៉ា អ៊ីចឹងមែនដែរទេ?

**លោកស្រី ជូឡុង អង់តូនីញ៉ា៖**

**ឆ៖** អង់តូញ៉ា ជូឡុង ចា៎ ។

**ស៖** លោកស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំ ៥៧ឆ្នាំ ខែតុលា ។

**ស៖** លោកស្រីមានសញ្ជាតិអ្វីដែរ?

**ឆ៖** ខ្ញុំជាសាសន៍បារាំង ។

**ស៖** តើសព្វថ្ងៃនេះលោកស្រីមានទីលំនៅ នៅទីកន្លែងណាដែរ?

**ឆ៖** (គ្មានការបកប្រែ) ។

**ស៖** សូមលោកស្រីនិយាយម្តងទៀត ដោយសារមិញលោកស្រីនិយាយលឿនរង់ចាំសញ្ញាក្រហមនៅក្បាលមីក្រូ ដើម្បីឲ្យសម្តីរបស់លោកស្រីចូលទៅនឹងប្រព័ន្ធសំឡេង ហើយនិងការប្រតិចារឹកកត់ត្រាទុកនូវសម្តីដែលបាននិយាយ ។ សូមឲ្យឆ្លើយនឹងសំណួរអំមិញម្តងទៀត ។

**ឆ៖** (និយាយភាសាបារាំង) ខ្ញុំនៅបារាំង អាជ្រេសខ្ញុំ លេខ១ ផ្លូវអែណេះ រីណង់ បារីសកែងហ្សៀមៗ ។

**ស៖** លោកស្រីមានមុខរបរអ្វីដែលសព្វថ្ងៃ?

[០៩:១៤:៣៨]

**ឆ៖** (និយាយភាសាបារាំង) ខ្ញុំនៅធ្វើការនៅក្នុងកាសែតបារាំងឈ្មោះ ឡិចប្រេស ហើយនិងខ្ញុំធ្វើជៀរីកទ្រីស ឌីកឹម៉ង់តាស្យុង របស់ឡិចប្រេស ។

**ស៖** លោកស្រីមានទីកន្លែងកំណើតនៅឯណាដែរ?

**ឆ៖** ខ្ញុំកើតនៅស្រុកបារាំង នៅអង់តូនី ។

**ស៖** ឪពុករបស់លោកស្រីឈ្មោះអ្វី?

**ឆ៖** លោកឪពុកខ្ញុំសម្តេចចក្រី ញ៉ឹក ជូឡុង ។

**ស៖** ចុះម្តាយរបស់លោកស្រីគាត់ឈ្មោះអ្វីដែរ?

**ឆ៖** លោកម្តាយ លោកជំទាវ មាស កេតសម្បុត្រ ។

**ស៖** លោកស្រីមានបងប្អូនបង្កើតប៉ុន្មាននាក់?

**ឆ៖** ខ្ញុំមានបងប្អូនស្រីប្រាំមួយ ។

**ស៖** ចូរលោកស្រីរៀបរាប់ឈ្មោះរបស់បងស្រី បងប្អូនរបស់លោកស្រីទាំងប្រាំមួយនាក់?

**ឆ៖** បងប្អូនខ្ញុំឈ្មោះ វីសាកា, រង្សុី, ដាឡា, ស៊ុនណារ៉ា, កេតទី, ហើយនិង នារ៉ាដេវី ។

**ប្រធានអង្គជំនុំ៖**

មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី សូមអញ្ជើញដើម្បីឡើងធ្វើសេចក្តីសង្ខេបអំពីអត្ត-សញ្ញាណដើមបណ្តឹងរដ្ឋប្បវេណី អំពីហេតុនៃការប្តឹងទាមទារ ភាពពាក់ព័ន្ធទៅនឹងអង្គហេតុដែលចោទប្រកាន់ទៅលើជនជាប់ចោទ ហើយនិងភស្តុតាងនានាដែលមាន ។ សូមអញ្ជើញ ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សណាព្រូស៖**

សូមអរគុណលោកប្រធាន ។ ជាការពិត អង់តូនីញ៉ា ជូឡុង មកផ្តល់សេចក្តីថ្លែងការណ៍ដោយសារតែការបាត់ខ្លួននិងការសម្លាប់បងស្រីរបស់ខ្លួន រង្សុី ជូឡុង ។ ហើយលោកស្រីនឹងធ្វើសេចក្តីថ្លែង-ការណ៍ក្នុងនាមគ្រួសាររបស់គាត់ ទាក់ទងទៅនឹងការស្លាប់របស់បងថ្លៃរបស់ខ្លួន បុរី ជូឡុង លីស៊ីម៉ៃ ។ ហើយនៅពេលនេះចំពោះករណីមួយនេះ ខ្ញុំសូមស្នើសុំឲ្យលោកប្រធានអនុញ្ញាតឲ្យលោកស្រី អង់តូនីញ៉ាជូឡុង ដែលគាត់ធ្វើសេចក្តីថ្លែងការណ៍ក្នុងនាមគ្រួសាររបស់គាត់ ដែលគ្រួសារនោះនៅក្នុងកន្លែងសាធារណជន ហើយនិងម្តាយរបស់គាត់ មាស កេតសម្បុត្រគឺ អង្គុយនៅក្នុងទីនេះ ។ ហើយខ្ញុំសូមអនុញ្ញាតឲ្យគាត់ថ្លែងសេចក្តីអំពីការស្លាប់របស់បងប្អូនរបស់គាត់ ។ ដោយសារតែតុលាការរបស់យើង យើងឃើញ

មានពាក្យសុំទាក់ទងទៅនឹង ជូឡុង រង្សុី ហើយជាពិសេសរឿងក្តី D25/08 ដែលវាពាក់ព័ន្ធទៅនឹងម្តាយរបស់ រង្សុី ជូឡុង ហើយនិងសំនុំរឿងD25/28 ដែលជា ជូឡុង រង្សុី ទាក់ទងទៅនឹងបុគ្គលរូបនោះ ហើយនិងសំណុំរឿង D25/26 ជាកូនរបស់ រង្សុី លីមគីម៉ារី ។ ហើយនិង E2/29 គីម៉ារី ឌីសាកា គឺជាកូនរបស់ រង្សុី ហើយនិង លីមគីម៉ារី ។

ចំពោះខ្ញុំគឺវាមានសារសំខាន់ណាស់ក្នុងការបញ្ជាក់ថា វាមានចំណងពាក់ព័ន្ធនៅក្នុងរឿងក្តី ដែលលោកអង្គសវនាការបានលើកឡើងម្សិលមិញ ។ យើងឃើញថា នៅក្នុងរឿងក្តីនេះមានការពាក់ព័ន្ធគ្នា ហើយខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន អនុញ្ញាតឲ្យលោកស្រី អង់តូនីញ៉ា ជូឡុង ធ្វើសេចក្តីថ្លែងអំពីការឈឺចាប់របស់គ្រួសាររបស់គាត់ ដោយសាររឿងទាំងអស់នេះវាពាក់ព័ន្ធគ្នា ។

ទាក់ទងទៅនឹងឯកសារយើងបានបង្កើតនៅអត្តសញ្ញាណរបស់លោកស្រី អង់តូនីញ៉ា ជូឡុង ហើយនិងអត្តសញ្ញាណរបស់ដើមរដ្ឋប្បវេណីផ្សេង ។ ហើយចំពោះទំនាក់ទំនងទាក់ទងទៅនឹងស-២១ វិញ គឺរឿងក្តីនឹងលើកឡើងដោយ អង់តូនីញ៉ា ជូឡុង ។ ហើយបើសិនជាមានមន្ទិលសង្ស័យណាមួយនោះ គឺយើងឃើញមានការសម្លាប់បងប្អូនរបស់គាត់នៅស-២១ ។ ដូច្នេះហើយយើងមានប្រវត្តិរូបទាំងអស់ដែលលេខ ERN00274780 លេខខ្មែរគឺ 00274785 លេខអង់គ្លេសគឺ 00274775 ។

ខ្ញុំសូមលើកឡើងផងដែរថា ឯកសារដែលគាត់លើកឡើងនោះ ដោយសារតែជនជាប់ចោទគាត់បានលើកឡើងអំពី រង្សុី ។ ឈ្មោះ រង្សុី ជូឡុង ហើយយើងឃើញមានសេចក្តីថ្លែងហេតុដែលមានសរសេរនៅក្នុងថ្ងៃទី២៩ ឆ្នាំ២០០៩ ហើយឃើញមានលេខ ERN ផងដែរ គឺ002355977 លេខ ERN អង់គ្លេសគឺ 00325874 ។ យើងឃើញប្រតិចារឹកនៅថ្ងៃទី២០ ខែមិថុនា បារាំងលេខ ERN គឺ 00344341 ហើយខ្មែរគឺ 00344440 អង់គ្លេសគឺមានលេខ 00344212 ហើយនិងប្រតិចារឹកនៅថ្ងៃទី១៦ ខែមិថុនា ERN បារាំងគឺ 00342140 លេខ ERN ជាភាសាខ្មែរគឺ 00342030 អង់គ្លេសគឺមានលេខ 00342808 ។ ចំពោះឈ្មោះ លឹមគី ម៉ារី ដែលជាប្រពន្ធរបស់ រង្សុី ជូឡុង យើងឃើញប្រវត្តិរូបរបស់គាត់រកឃើញនៅមន្ទីរស-២១ មានលេខ ERN ខ្មែរគឺ 00088013 អង់គ្លេសគឺមានលេខ 00344226 បារាំងមានលេខ 00211858 ហើយយើងក៏ឃើញមានរូបថតនៅស-២១ ដែលមានលេខ ERN ភាសាខ្មែរគឺ 00211859 អង់គ្លេសគឺ 00211859 បារាំងគឺ 00211859 ។

ហើយក្នុងការផ្តល់ការគាំទ្រទៅលើរឿងក្តីរបស់ លឹមគី ម៉ារី យើងឃើញក៏ឃើញមាននៅក្នុងឧបសម្ព័ន្ធ B44 ដែលជាបញ្ជីរបស់មន្ទីរ-- បញ្ជីអ្នកទោសនៅស-២១ ហើយយើងក៏មានលេខ ERN

បារាំងគឺ 00209848 ។ ដូច្នេះហើយខ្ញុំជឿថា យើងមិនមានការលំបាកក្នុងការស្វែងយល់អំពីអង្គហេតុថា លឹមគីម៉ារី គឺជា-- គឺបានជាប់នៅស-២១ ហើយស្លាប់នៅស-២១ ។ ដូច្នេះហើយខ្ញុំជឿថានឹងមានបញ្ហាចំពោះបញ្ហាទំនាក់ទំនងរវាងក្រុមគ្រួសារ ជូឡុង អង់តូនីញ៉ា ហើយនិងជនរងគ្រោះនោះទេ ។ ដូច្នេះហើយលោកស្រី អង់តូនីញ៉ា ជូឡុង គាត់មកពីប្រទេសបារាំង ហើយយើងសូមឆ្លៀតឱកាសនេះ សូមបញ្ជាក់ថា ឯកសារដែលយើងមិនទាន់មានពីមុននោះ គឺទាក់ទងទៅនឹងអត្តសញ្ញាណដែលយើងមិនទាន់មានលិខិតកំណើតរបស់លោកស្រីនេះ ។ ហើយយើងខ្ញុំសូមដាក់ឯកសារលិខិតកំណើតនេះនៅក្នុងដំណាក់កាលរបស់យើង ។ នេះគឺជាអ្វីដែលខ្ញុំបានលើកឡើងដើម្បីគាំទ្រទៅនឹងរឿងក្តី និងសេចក្តីថ្លែងការណ៍របស់លោកស្រី អង់តូនីញ៉ា ជូឡុង ។ សូមអរគុណ ។

[០៩:២៥:៣៥]

**ប្រធានអង្គជំនុំ៖**

លោកស្រី ជូឡុង អង់តូនីញ៉ា ចូរថ្លែងរៀបរាប់ជូនដល់អង់សវនាការអំពីទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលនាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការប្តឹងទាមទារសំណង និងអំពីស្ថានភាពព្យសនកម្មដែលមានចំពោះលោកស្រីជាអាទិ៍ និងការខូចខាតផ្នែកខាងរងកាយសម្ភារៈផ្លូវចិត្ត និងផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋព្យសនកម្មផ្ទាល់ខ្លួន នឹងបានកើតឡើងយ៉ាងពិតប្រាកដមកដល់ពេលបច្ចុប្បន្ន ។ ដោយបទឧក្រិដ្ឋដែលចោទប្រកាន់នេះ ហើយដែលបានប៉ះពាល់ដល់លោកស្រីនៅក្នុងអំឡុងពេលនៃការបង្កើតនិងប្រតិបត្តិការនៃមន្ទីរសន្តិសុខស-២១ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ សូមអញ្ជើញ ។

**លោកស្រី ជូឡុង អង់តូនីញ៉ា៖**

តែខ្ញុំសូមលោកប្រធានអនុញ្ញាតឲ្យខ្ញុំបន្តបទអន្តរាគមន៍របស់ខ្ញុំ ជាភាសាបារាំង ដោយសារខ្ញុំមិនសូវធ្លាប់និយាយភាសាខ្មែរ ពីព្រោះខ្ញុំត្រូវបាននិរទេសនៅប្រទេសបារាំងអស់រយៈពេលជិតសែសិបឆ្នាំហើយ។

[០៩:២៧:១០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមសំណើនេះ ពីព្រោះភាសាទាំងបីនេះគឺប្រើប្រាស់នៅក្នុងតុលាការនេះ។ អង្គជំនុំជម្រះអនុញ្ញាតតាមសំណើរបស់លោកស្រី ។ សូមអញ្ជើញ ។

**លោកស្រី ជូឡុង អង់តូនីញ៉ា៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមបញ្ជាក់ដូចដែលមេធាវីរបស់ខ្ញុំបានបញ្ជាក់ហើយ ខ្ញុំនិយាយនៅទីនេះចំពោះមុខតុលាការក្នុងនាមគ្រួសាររបស់ខ្ញុំ ។ ជាបឋម ក្នុងប្អូនស្រីរបស់ខ្ញុំ គឺ រង្សី ដែលត្រូវបានសម្លាប់ និងប្អូនស្រី លីម៉ាកា ក្នុងនាមម្តាយរបស់ខ្ញុំដែលគាត់អង្គុយក្នុងសាលសវនាការនេះដែរ ។ ហើយតាមពិតគាត់គឺជាមនុស្សទីមួយដែលដាក់ពាក្យបណ្តឹង ហើយធ្វើពាក្យបណ្តឹងក្នុងនាមប្អូនស្រីរបស់ខ្ញុំ ហើយប្អូនស្រីរបស់ខ្ញុំក៏នៅក្នុងបន្ទប់នេះដែរ ដើម្បីសម្តែងអំពីទុក្ខសោករបស់ក្រុមគ្រួសាររបស់យើង។

ខ្ញុំក៏សង្ឃឹមផងដែរថា ខ្ញុំនឹងជម្រាបដែលថា សម្តែងក្នុងនាមប្អូនស្រីរបស់ខ្ញុំ រង្សី ដែលគាត់មិនបានមកទីនេះថ្ងៃនេះទេ ។ ហើយដើម្បីការពារ ហើយដើម្បីនិយាយក្នុងនាមគាត់ហើយ ។ ជម្រាបលោកតុលាការថា តើគាត់ជាមនុស្សរបៀបម៉េច ហើយថាក្រុមគ្រួសារនឹកគាត់កម្រិតណា?

[០៩:២៨:៥៦]

ដូច្នេះ យើងមានបងប្អូនស្រីប្រាំពីរនាក់ក្នុងគ្រួសារ ។ សូមលោកប្រធានអនុញ្ញាតឲ្យជម្រាបរៀបរាប់អំពីគ្រួសាររបស់យើងមានលក្ខណៈដូចម្តេច? យើងមានបងប្អូនស្រីប្រាំពីរនាក់ ឪពុករបស់ខ្ញុំសម្តេចឧកញ៉ា ញឹក ជូឡុង ហើយបានចំណាយពេលមួយជីវិតសម្រាប់ប្រទេសជាតិ ។ ហើយខ្ញុំចង់បញ្ជាក់ពីបញ្ហានេះ ពីព្រោះថានឹងមានឥទ្ធិពលទៅអង្គហេតុដែលបានកើតមានឡើង ហើយគាត់ សម្តេច ស៊ីហនុ បានតែងតាំងគាត់ចុះហត្ថលេខឆ្នាំ១៩៤៧ ដើម្បីការពារប្រទេស ។ គាត់ជាមន្ត្រីជាន់ខ្ពស់ហើយគាត់ក្លាយជាអគ្គរដ្ឋទូត ហើយរដ្ឋមន្ត្រី នាយរដ្ឋមន្ត្រី ហើយនិងប្រមុខរាជកងទ័ពផង ដែលជាកងទ័ពស្វាមីភក្តិទៅនឹងសម្តេចឪ ។

រង្សី គឺជាមនុស្សទីពីក្នុងគ្រួសារ ជាកូនទីពីរ ហើយគាត់បានជួបប្តីរបស់គាត់ លឹម ការី ហើយគាត់បានរៀបការកាលពីគាត់នៅអាយុក្មេង ហើយគាត់មានកូនបី វីសាកា, នីរីនកា ហើយនិងកូនប្រុសឈ្មោះ មេត្តា ។ ប្អូនស្រីរបស់ខ្ញុំ រង្សី គឺជាតំណាងនៃមន្ទីរពិសោធន៍មួយរបស់អាល្លឺម៉ង់ ហើយគាត់គឺជាអ្នកធ្វើការនៅវិទ្យុបារាំង ។ បងថ្លៃខ្ញុំ លឹម គីម៉ារី ធ្វើការឲ្យធនាគារពាណិជ្ជកម្មមួយ ។ ដូច្នេះ ខ្ញុំនឹងសូមអនុញ្ញាតនឹងរៀបរាប់អំពីប្រវត្តិជីវិតរបស់នៅថ្ងៃ ១៧ មីនា ក្នុងរបប លន់ នល់ គឺថាគេចេញសេចក្តីសម្រេចថា មិនអនុញ្ញាតឲ្យក្រុមគ្រួសារ ជូឡុង ចូលស្រុកខ្មែរទៀតទេ ពីព្រោះតែ-- ពីព្រោះម្តាយរបស់ខ្ញុំមានចំណងជាមួយសម្តេច សីហនុ ។

[០៩:៣១:១៤]

ប្អូនស្រី រង្សី របស់ខ្ញុំ ហើយត្រូវបានកោះហៅដោយ លឹម គីម៉ារី នៅប្រទេសបារាំង ហើយយើងក៏រក្សាទំនាក់ទំនងជាមួយប្ដីរបស់គាត់ឲ្យបារាំងហើយទៅលេងយើង ។ ហើយមួយឆ្នាំទៅពីរបីខែ ហើយប្ដីក៏បានជួបគ្នាមួយខែ ហើយគេបានរស់នៅក្នុងប្រទេសបារាំង ។ ក្នុងរយៈពេលការស្នាក់នៅនោះគាត់បានសរសេរសំបុត្រមកយើង ហើយសរសេរសំបុត្រផ្ទាល់ខ្លួនទៅឪពុកម្ដាយ ហើយបានរក្សារទុកចំណងគ្រួសារហ្នឹងនៅរឹងមាំ ។

នៅក្នុងឆ្នាំ១៩៧៣ សង្គ្រាមស៊ីវិលក៏ចាប់ផ្ដើមឡើងកាន់តែខ្លាំង ហើយសាលាទាំងឡាយត្រូវបានបិទដោយសាររក្សាសន្តិសុខដើម្បីការពារកូនរបស់ខ្លួន គាត់បានបញ្ជូនកូនទៅប្រទេសបារាំង ឲ្យរស់នៅជីតា ។ នៅក្នុងឆ្នាំ១៩៧៤ ដោយពិនិត្យឃើញថា សង្រាមស៊ីវិលកាន់តែធ្ងន់ធ្ងរទៅនោះ យើងបានសុំ រង្សី គីម៉ារី ឲ្យបានចូលមកនៅជាមួយយើងនៅប្រទេសបារាំង ហើយគាត់បានឆ្លើយថា យើងមានមុខវិជ្ជារបស់យើងនៅភ្នំពេញ ហើយនៅប្រទេសបារាំង យើងអត់មានអ្វីធ្វើទេ ។ យើងមិនអាចទៅប្រឈមមុននឹងបញ្ហានោះទេ ដូច្នេះហើយយើងនៅភ្នំពេញតទៅទៀត ។

[០៩:៣២:២៩]

ហើយការស្នាក់នៅប្រទេសបារាំងចុងក្រោយនោះ គឺដែលយើងបានជួបពួកគាត់ ដែលយើងបាននិយាយជាមួយពួកគាត់ យើងបានពេញចិត្តនឹងភាពសប្បុរសធម៌របស់គាត់គឺនៅក្នុងឆ្នាំ១៩៧៤ ។ ហើយគេបានកំណត់ថា គេនឹងមកជួបពួកយើងនៅក្នុងរដូវក្ដៅក្នុងឆ្នាំ១៩៧៥ ។ នៅក្នុងឆ្នាំទាំងមូលនេះ ចាប់ពីឆ្នាំ១៩៧៤ដល់៧៥ នោះគឺលិខិតឆ្លើយបតរបស់យើងនឹងចេះតែបន្តឆ្លើយឆ្លងគ្នា ប៉ុន្តែ ប្អូនស្រីរបស់ខ្ញុំ គឺមានការព្រួយបារម្ភកាន់តែខ្លាំងចំពោះការសិក្សារបស់កូនៗរបស់គាត់ ។ កាលណាគេរៀនក្នុងថ្នាក់មួយ- - ហើយគាត់និយាយថានៅឆមាសទីពីរអាចនឹងល្អប្រសើរ គេហូបមិនបានស្រួលទេ នៅក្នុងរេសស្តូរ៉ង់នៅក្នុងសាលា ហើយគាត់បានសរសេរបញ្ជាក់ទៅកូនរបស់គាត់ ហើយចាប់អារម្មណ៍នឹងការងារប្រចាំថ្ងៃរបស់កូន ។ ហើយគាត់សរសេរថា ការរស់នៅទីនេះមានការលំបាកដោយមានគ្រប់ផ្ដោងជាច្រើនផ្ដោងមកភ្នំពេញ ហើយគាត់ក៏បានគូសផែនទីថា តើគ្រាប់ផ្ដោងធ្លាក់កន្លែងណាខ្លះ ហើយគេបញ្ជាក់ថាគេចៀសវាងបានពីមួយថ្ងៃទៅមួយថ្ងៃ ។ ពេលខ្លះគឺគ្រាប់ធ្លាក់នៅជាតិជណ្ដើររបស់ខ្លួន ជិតផ្ទះ ហើយគេមានការភ័យខ្លាច ហើយមិនហ៊ានចេញដើរទៅណាឆ្ងាយទេ ។

ខ្ញុំសូមអនុញ្ញាតដើម្បីអានសេចក្ដីដកស្រង់ពីសំបុត្រប្អូនស្រី ខែមីនា ឆ្នាំ១៩៧៥ ។

“នេះជាលិខិតដែលសរសេរមកឪពុកខ្ញុំ តើពុកអាចឲ្យយោបល់ដូចម្ដេច? តើចង់ឲ្យយើងធ្វើដូច

ម្តេច? តើខ្ញុំត្រូវចេញឆាប់បំផុតតាមដែលអាចធ្វើបានឬត្រូវតែ-- ខ្ញុំត្រូវតែចាកចេញតាមពេលដែលថាកំណត់ ខ្ញុំមិនមានអ្វីត្រូវសម្រេចទេ ។ ខ្ញុំមិនអាចចាកចេញពីប្តីរបស់ខ្ញុំទេ ពីព្រោះកំពុងតែមានគ្រប់ផ្លោងជាញឹកញាប់បែបនេះ ។ ប្រសិនបើលោកឪពុកអាចសរសេរព័ត៌មានជាសម្ងាត់ ថាអាចសុំឲ្យក្រសួងការបរទេសបារាំងឲ្យបញ្ជូនសំបុត្រមកខ្ញុំ មកទូតបារាំងដើម្បីខ្ញុំចេញបាននោះ ។ ខ្ញុំនឹង-- ដោយមានកិច្ចសហប្រតិបត្តិការជាមួយបារាំងនៅក្នុងភ្នំពេញនោះ ។”

នេះគឺជាដំណឹងចុងក្រោយដែលយើងបានទទួលពីប្អូនស្រីរបស់ខ្ញុំ ហើយនិងពីបងថ្លៃប្រុសរបស់ខ្ញុំ ។ ខែមេសា ឆ្នាំ១៩៧៥ នៅប៉ារីស យើងបានដឹងថា ខ្មែរក្រហមបានកាន់កាប់ភ្នំពេញ ហើយយើងបានដឹងរឿងច្រើនណាស់ ។ សារព័ត៌មានបារាំងបាននិយាយថា ការជោគជ័យរបស់សង្គមនិយមនៅក្នុងអាស៊ីអាគ្នេយ៍ ។ ហើយយើងបានគិតថា របបកុម្មុយនីស្ត ហើយនិងបង្កើតនៅក្នុងរបបកុម្មុយនីស្តធម្មតាយើងមិនបានគិតថាវាមានអ្វីជាសោកនាដកម្មដែលជាផលចេញពីរបបនោះទេ ។ ហើយក្នុងចន្លោះឆ្នាំ១៩៧៥និងឆ្នាំ១៩៧៩ គឺជារយៈពេលរង់ចាំដ៏យូរអង្វែង យើងមិនដឹងថា ប្អូនស្រីនិងបងថ្លៃប្រុសហ្នឹង ជួបជោគវាសនាដូចម្តេចទេ ។ យើងព្យាយាមប្រឈមមុខថែរក្សាកូនៗរបស់គាត់ ។ ហើយយើងគិតថានៅទីបំផុតថ្ងៃណាមួយគេនឹងត្រឡប់មកវិញ។ នៅពេលដែលអាយុ១៦ឆ្នាំ ក្មួយៗអាចនឹងជួបជាមួយឪពុកម្តាយហើយយើងនឹងបង្កើតក្រុមគ្រួសាររបស់អ្នកឯងជាថ្មី ។ នីវីនកា នោះ គឺថាមានទុកចិត្ត ហើយទន្ទឹងរង់ចាំនូវថ្ងៃខួបកំណើតអាយុ១៦ឆ្នាំ ថានឹងជួបឪពុកម្តាយរបស់ខ្លួនវិញ ។

ដូច្នេះ ហើយយើងបានព្យាយាមសរសេរលិខិតឆ្លើយឆ្លងម្តាយរបស់ខ្ញុំបង្ហាញរូបថតប្អូនស្រីរបស់ខ្ញុំទៅអង្គការអន្តរជាតិផ្សេងៗដែលបង្កើតនៅប្រទេសថៃ ហើយប្រាប់គេថា យើងរករូបថតនេះ ហើយគឺហើយនឹងបញ្ជូនភ្នាក់ងារឲ្យស្វែងរកនៅក្នុងកម្ពុជា ហើយបានចំណាយលុយឲ្យភ្នាក់ងារហ្នឹងច្រើនណាស់ដើម្បីរក ហើយមនុស្សម្នាក់ថាគេតាំងខ្លួនថាគេបានរកឃើញប្អូនស្រីរបស់ខ្ញុំនៅកម្ពុជា ។ ឪពុករបស់ខ្ញុំគ្មានអំណាចអ្វីទៀតទេ។ គាត់បានចំណាយពេលវេលាមួយជីវិតរបស់គាត់ដើម្បីការពារប្រទេស ហើយនៅទីបំផុត គឺមិនបានមានឥទ្ធិពលអ្វី ហើយមិនអាចជួយប្អូនស្រីរបស់ខ្ញុំបានទៀតទេ ។ នេះហើយជាការព្រួយបារម្ភមួយរបស់គាត់ ហើយគាត់រក្សាមិត្តភាពជាមួយអ្នករួមការងាររហូតដល់ទីបញ្ចប់ ។ ដើម្បីថែរក្សា ជាពិសេសចៅៗរបស់គាត់ដែលនៅជាមួយគាត់ ដែលជួបប្រទះនូវបញ្ហា ដើម្បីជំនួសឪពុកម្តាយដែលមិនបានជួបពួកគេនោះ ។ ហើយពួកគេបានធំធាត់នៅក្នុងអាយុ១៤ឆ្នាំ នៅក្នុងប្រទេសមួយដែលថាមិនបានដឹងអ្វីច្រើននៅទីនោះទេ។ ហើយបានចូលរួមនៅក្នុងក្រុមគ្រួសារ ថានឹងបានជួបនៅថ្ងៃណាមួយ។

ប៉ុន្តែជាគ្រួសារមួយដែលត្រូវបានទាក់ទងគ្នាតែតាមរយៈសំបុត្រមិនមានអ៊ីនធឺណេត មិនមានប្រព័ន្ធអ៊ីនធឺណេតនោះអ្វីទេ ។

[០៩:៣៨:៥១]

នៅក្នុងឆ្នាំ១៩៧៩ នៅពេលដែលអ្នកដែលទៅតាមទូកវៀតណាមបានទៅដល់អឺរ៉ុបនោះ នៅពេលដែលជនភៀសខ្លួនខ្មែរក៏បានចូលទៅដល់កំពង់ផែថៃ នៅក្នុងប្រទេសបារាំងគេនិយាយអំពីជនភៀសខ្លួនវៀតណាម។ គេមិននិយាយអំពីសោកនាដកម្មរបស់កម្ពុជាទេ ដែលគេព្យាយាមឆ្លងទៅប្រទេសថៃនោះ។ ហើយគេបានឆ្លងកាត់វាលមីន ហើយត្រូវស្លាប់ដោយសារអត់អាហារ គឺថាមានកម្ពុជាពីរនាក់ ដែលនៅពេលនោះយើងបានធ្វើកូដកម្មអត់អាហារពីរថ្ងៃនៅប៉ារីស នៅមុខវត្តមួយ ដើម្បីបង្ហាញអាជ្ញាធរបារាំងថា វាមានហេតុការណ៍មួយអាក្រក់កើតឡើង ដែលយើងត្រូវយកចិត្តទុកដាក់ជួយដល់ជនភៀសខ្លួនកម្ពុជា។ ពេលនោះរដ្ឋាភិបាលបារាំងនោះនិយាយថា ខ្ញុំមិនមាន-- អ៊ីចឹងហើយខ្ញុំមាន-- ជានាយករដ្ឋមន្ត្រីនៅពេលនោះ គេបាននិយាយថា ជនភៀសខ្លួនខ្មែរបានកើតឡើងជាច្រើន ហើយខ្ញុំបានធ្វើការងារហ្នឹង គឺក្នុងឋានៈជាពលរដ្ឋមួយ ទាក់ទងទៅនឹងជនរួមជាតិរបស់ខ្ញុំ ។

ប៉ុន្តែក្រោយមកខ្ញុំបានធ្វើការងារដើម្បីប្អូនស្រីរបស់ខ្ញុំ ។ ខ្ញុំសង្ឃឹមថាអាចនឹងគាត់នៅក្នុងចំណោមអ្នកជនភៀសខ្លួនខ្មែរនៅកាលនោះ ដើម្បីជួយគាត់ ។ ប៉ុន្តែ ខ្ញុំមិនបានដឹងថា គាត់ត្រូវបានបាត់ខ្លួនរួចទៅហើយទេ ។ ខ្ញុំតែងតែគិតអំពីប្អូនស្រីរបស់ខ្ញុំនៅក្នុងឆ្នាំនោះ ។ ខ្ញុំមិនដែលឈប់គិតទេ ។ ខ្ញុំប្រហែលជាឆោតល្ងង់។ យើងជាអ្នកពុទ្ធសាសនា ហើយយើងបានបន់ស្រន់ ហើយយើងរំពឹងថានឹងជួបប្អូនស្រីហើយនិងបងថ្លៃប្រុសវិញ គឺគាត់ថាជានៅពេល គឺជាអាចទទួលជើងឯកមួយនៅក្នុងកម្មវិធីមួយហ្នឹង ។ ហើយអាចនឹង-- គាត់អាចចៀសផុតពីបញ្ហា ប៉ុន្តែអ្វីដែលខ្ញុំគិតហ្នឹងគឺថាជាភាពឆោតល្ងង់ទេ ។ យើងមិនបានទទួលដំណឹងអ្វីទៀតទេ ។ ខ្ញុំបន្តនៅខែមីថុនា ការកូដកម្មហ្នឹងតទៅទៀត ប៉ុន្តែយើងបានទទួលលិខិតមួយដែលផ្តល់ដោយអ្នកទូរទស្សន៍បារាំងមួយមកយកព័ត៌មាននៅភ្នំពេញ ហើយគាត់បានជួបបងប្អូនជីដូនរបស់ខ្ញុំដែលនៅរស់ដែលបានសួរយើងឲ្យជួយពួកគេឲ្យបានចាកចេញពីកម្ពុជា ។ ហើយដើម្បីឲ្យពួកគេបានទៅនៅប្រទេសបារាំង គេបាននិយាយថា ប្តីរបស់គាត់ត្រូវបានគេសម្លាប់រួចហើយ ។ ហើយគាត់គឺជាមនុស្សម្នាក់ដែលនៅរស់ ហើយមិនបានឮពាក្យអ្វីអំពីប្អូនស្រីរបស់ខ្ញុំទេ ហើយមិនដឹងថា គាត់នៅរស់ ឬស្លាប់ទេ ។ ប្រហែលជាពួកគេបែកគ្នា ប្រហែលជាមិនអាចជួបប្អូនស្រីរបស់ខ្ញុំ ប្រហែលជានៅកន្លែងណាមួយឈឺក៏មិនដឹង ។ អាចនឹងជួបនឹងការលំបាកនៅក្នុងខេត្តណាមួយ ឬក៏ភ្នំពេញ ហើយ

យើងអាចនឹងថ្ងៃណាមួយសង្ឃឹមថានឹងរកឃើញ ។

ប៉ុន្តែ នៅពេលដែលប្អូនជីដូនមួយរបស់ខ្ញុំបានមកដល់ មកជួបធ្វើដំណើរតាមរទេះគោចេញពី-- បានទៅដល់ព្រំដែនថៃ ។ ហើយយើងអាចរៀបចំឲ្យគាត់បានទៅដល់ប្រទេសបារាំង ហើយយើងបានជួបគាត់ ហើយក៏គេត្រូវការជំនួយ ហើយយើងមើលស្ថានភាពសុខភាពគេ គឺអាក្រក់ គាត់ស្រកទំងន់ គឺបាក់ធ្មេញអស់ច្រើន ហើយមានរោគជាច្រើន ត្រូវព្យាបាលជាច្រើនសប្តាហ៍ ដើម្បីឲ្យជា ដើម្បីឲ្យអាចនឹងមានសុខភាពធម្មតាវិញ ។

[០៩:៤៣:០៣]

អ្វីដែលគាត់ប្រាប់យើងនោះ គឺអំពីរឿងអាក្រក់សោកនាដកម្ម គឺជាថ្ងៃមួយនោះឯង ដែល រង្ស៊ី ហើយនិងប្តីរបស់គាត់ត្រូវបានសម្លាប់ដោយជនជាប់ចោទ ។ ហើយឈ្មោះ យ៉ុង នោះ នៅពេលដែលវៀតណាមបានមកដល់ក្នុងថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ ហើយគាត់បានជួប អ៊ឹង ប៊ុច ដែលជាអ្នកផលិតខ្មោះសម្រាប់ទួលស្លែង ។ ហើយគាត់បានចំណាយពីរបីថ្ងៃជាមួយគាត់ ហើយគាត់ប្រាប់ខ្ញុំថាគាត់បានឃើញនូវគំនរខោអាវមួយចំនួន ហើយឃើញរូបថតមួយគំនរ ហើយនិងចម្លើយសារភាពមួយគំនរធំ ហើយគាត់បានទៅទួលស្លែងគេបានប្រាប់ខ្ញុំថា រង្ស៊ី ត្រូវបានគេឃុំខ្លួន ហើយពិនិត្យទៅឃើញមានស្នាមឈាមនៅទួលស្លែង ហើយគាត់បានឃើញឈាមបានពិនិត្យមើលគំនរឯកសារហ្នឹង ។ ហើយក៏បានរកឃើញចម្លើយសារភាពច្បាប់ដើម ប្អូនស្រីរបស់ខ្ញុំសរសេរជាភាសាខ្មែរ ហើយស្គាល់អក្សរសរសេរដោយដៃរបស់គាត់ទៀត ។ ហើយគាត់ទទួលស្គាល់ពាក្យបរទេសដែលប្រើហ្នឹង គឺថាជាឈ្មោះរបស់មិត្តភក្តិជាជនជាតិបារាំងនៅក្នុងនោះផង ។ ហើយក៏បានរកឃើញរូបថតរបស់នាងនៅក្នុងគំនរនោះផងដែរ ។ ចំពោះយើងខ្ញុំ គឺជាការរន្ធត់ដ៏តក់ស្លុតនៅក្នុងឆ្នាំ១៩៧៩ គឺធ្វើឲ្យយើងបាក់បែកខ្ទេចខ្ទីក្នុងផ្លូវអារម្មណ៍ទាំងអស់ ។ ហើយយើងបានព្យាយាមការពារកូនៗរបស់គេ ។

ប៉ុន្តែ មុនពេលដែលការឈឺចាប់ដ៏ធ្ងន់ធ្ងរបែបនេះកើតឡើង បងប្អូនជីដូនមួយរបស់យើងនោះបានរៀបរាប់សេចក្តីលម្អិតអំពីអ្វីបានកើតឡើងចំពោះប្អូនស្រីរបស់ខ្ញុំប្រាប់ទៅកូនៗរបស់គាត់ ដែលថាប្អូនស្រីរបស់ខ្ញុំបានទទួលនូវទារុណកម្មដ៏ធ្ងន់ធ្ងរ ។ គាត់បាននិយាយលម្អិតមួយចំនួនអំពីរឿងរ៉ាវ គឺជារឿងរ៉ាវដ៏គួររន្ធត់ ។

មេត្តា ហ្នឹងគាត់អាយុទើបតែ ១១ឆ្នាំទេពេលនោះ យើងត្រូវតែប្រយ័ត្នក្នុងការនិយាយពីរឿងហ្នឹង បើសិនថា និយាយទៅអាចធ្វើឲ្យគាត់ឈឺចាប់កាន់តែខ្លាំង ឬក៏មានជំងឺខូចផ្លូវអារម្មណ៍ ។ ហើយឪពុក

ម្តាយស្ថិតនៅក្នុងភាពទុក្ខសោកដ៏ខ្លាំង ឪពុករបស់ខ្ញុំក៏បានគ្រប់គ្រងអារម្មណ៍របស់គាត់ ។ ហើយម្តាយរបស់ខ្ញុំក៏មិនយល់ពីអ្វី គាត់នៅតែឆ្ងល់រហូតដល់ថ្ងៃនេះ ថាហេតុអ្វីបានគេសម្លាប់កូនរបស់គាត់? ថាតើគេធ្វើហ្នឹងដើម្បីអ្វី? ចង់បានអ្វី?

[០៩:៤៦:០៨]

ឪពុករបស់ខ្ញុំក្រោយមក ហើយគាត់បានបៀមទុក្ខតែម្នាក់យ៉ាងខ្លាំង ដោយសារថាគាត់មានភាពសាម្មីភក្តិចំពោះសម្តេច សីហនុ ហើយក៏គាត់បាននាំគាត់មកវិញ មកចរចាជាមួយខ្មែរក្រហម ជាមួយខៀវ សំផន ។ ហើយគឺថា គាត់បន្តធ្វើការជាបុគ្គលិករដ្ឋ អ្នកបម្រើរដ្ឋរហូតដល់ទីបញ្ចប់ ។ ប៉ុន្តែផ្ទុយទៅវិញ គាត់មានទុក្ខព្រួយថា មានកំហុសមិនអាចជួយកូនរបស់គាត់បាន ។

ហើយសុំអនុញ្ញាត ខ្ញុំរំឭកឡើងវិញ ហើយគាត់ចូលរួមនៅក្នុងការការពារប្រទេសជាតិរបស់គាត់ ផលប្រយោជន៍ប្រទេសរបស់គាត់ ហើយកូនៗបានធំធាត់ដោយសារការឃុំគ្រង ចួនកាលបានរស់នៅបែកពីឪពុកម្តាយ ។ វិសាកា នីរីនកា គឺថាមានការរងគ្រោះក្នុងផ្លូវចិត្ត មិនមានសេចក្តីក្លាហាននឹងមកតុលាការនេះបានទេ ។ ខ្ញុំសូមសម្តែងអំពីទុក្ខសោករបស់ខ្ញុំ មេត្តា ក៏បានស្លាប់នៅក្នុងឆ្នាំ១៩៧៩ ទទួលជំងឺផ្លូវសរសៃប្រសាទដ៏ធ្ងន់ធ្ងរក្នុងអាយុ១១ឆ្នាំតែប៉ុណ្ណោះ ។ គាត់មានជំងឺម្យ៉ាងផ្លូវចិត្ត ហើយខ្ញុំបាននាំគាត់ទៅជួបគ្រូពេទ្យចិត្តសាស្ត្រ ។ ហើយគេបញ្ជាក់ថា ជំងឺរបស់គាត់ គឺថាពាក់ព័ន្ធទៅជំងឺប៉ះទង្គិចផ្លូវអារម្មណ៍ ហើយគាត់ទទួលជំងឺថ្នាំពេទ្យមួយជីវិត ។ ហើយនៅថ្ងៃមួយ គាត់គឺជាកូនតែម្នាក់ក្នុងកូនរបស់ប្អូនស្រីរបស់ខ្ញុំ ដែលថាអាចមកធ្វើការជាគណនេយ្យមួយ ។ ហើយគាត់បានមានគ្រោះថ្នាក់មួយនៅក្នុងចរាចរដែលបុកវិមានឯករាជ្យ ហើយនាងនោះក៏បានស្លាប់ទៅ ។ អ៊ីចឹងហើយ គឺជាបញ្ហាដែលកើតឡើងចំពោះក្រុមគ្រួសារ ។

ហើយនៅក្នុងសំណុំឯកសារនោះគឺជាលិខិតបញ្ជាក់របស់ពេទ្យចិត្តសាស្ត្រដែលថា នាងមានជំងឺគេងមិនលក់ ហើយមានជំងឺបេះដូង ។ វិសាកា នោះក៏បានព្យាយាមរស់នៅក្នុងប្រទេសមួយនៅក្នុងប្រទេសលុចសំបួរ ដើម្បីព្យាយាមកែប្រែជីវិត ហើយក៏បានមានគ្រួសារមួយនៅទីនោះ ។ ដោយហេតុថា យើងរស់រានក្នុងការលំបាកដែលយើងមានការលំបាកបែបនេះ យើងចេះតែព្យាយាមបន្តទៅទៀត ហើយនឹងចូលរួមនៅក្នុងការកសាងរបស់ប្រទេសរបស់ខ្លួនដែរ ។ ទោះបីជាមានទុក្ខសោកយ៉ាងម៉េចមិនអាចបំភ្លេចបាននោះក៏ដោយ ។

ខ្ញុំសង្ឃឹមថា អាចនឹងថ្ងៃណាមួយនឹងមានការជំនុំជម្រះ ។ ហើយខ្ញុំនឹងនិយាយពីរឿងតទៅទៀត

យើងបានព្យាយាមរស់នៅជាមួយគ្នា ។ ប៉ុន្តែ ក្រៅពីអ្វីៗក្នុងជីវិតរបស់យើង យើងទុកជីវិតជាឯកជន ។ ហើយ រង្សុី ជាប្អូនរបស់ខ្ញុំនិងប្តីរបស់គាត់ ហើយយើងនឹងលើកឡើងវិញនូវអំពីវិញ្ញាណក្ខន្ធគាត់ និងប្តីរបស់គាត់ ហើយប្អូនប្រុស បងថ្លៃខ្ញុំតែងតែនិយាយកំប្លែងគឺថាជានំដែលបានដុត ហើយគឺថាបានសំឡេងសើច និងភាពសេចក្តីរីករាយ ។

[០៩:៥០:០០]

ហើយយើងនិយាយអំពីគាត់ទាំងពីរនេះជាញឹកញាប់ ដើម្បីឲ្យយើងបានចូលរួមនៅក្នុងជីវិតរបស់យើង។ ហើយកូនស្រីរបស់គាត់មិនបានស្គាល់គាត់ទេ ហើយ គឺជាគំនិតមួយដែលធ្វើអ្វីឲ្យគេបានដឹងតាមរយៈពីជីដូនជីតារបស់គេ ។ កូនរបស់ខ្ញុំក៏នៅក្នុងបន្ទប់ ក៏ប៉ុន្តែ គាត់មិនអាចជួបមីងរបស់គាត់នោះទេ ។ ដូច្នេះ យើងបានចាកចេញពីប្រទេសនេះ ។

នៅក្នុងឆ្នាំ១៩៩៤ ជាលើកទីមួយ ខ្ញុំបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ។ ភស្តុតាងដែលខ្ញុំមានចំពោះការបាត់ខ្លួនបងស្រីរបស់ខ្ញុំ គឺរឿងរ៉ាវដែលពាក់ព័ន្ធជាមួយនឹងជីដូនមួយរបស់ខ្ញុំ ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតនិយាយអំពីរឿងរ៉ាវនេះឡើងវិញ ។

ខ្ញុំដឹងថាមានអ្វីកើតឡើងរវាងខែមេសា ឆ្នាំ១៩៧៥ហើយនិងខែវិច្ឆិកា ឆ្នាំ១៩៧៥ នៅពេលនោះខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ ។ បងស្រីរបស់ខ្ញុំដែលរស់នៅជិតវិមានឯករាជ្យ ត្រូវបានគេដេញចេញពីផ្ទះជាមួយនឹងជីដូនមួយរបស់ខ្ញុំ ។ ហើយពួកគេអាចឡើងជិះឡានចំនួនបីដែលមានម្ហូបអាហារបន្តិចបន្តួច និងសម្លៀកបំពាក់បន្តិចបន្តួច និងគ្រឿងអលង្ការបន្តិចបន្តួច ។ ហើយពួកគេអាចឈប់នៅច្បារអំពៅ ហើយពួកគេបានធ្វើដំណើរទៅ ហើយនិងបានផ្តែល្អុតហ្វូបក្នុងរយៈពេលប្រាំមួយសប្តាហ៍ ។ ហើយពួកគេអាចញ៉ាំបានតិចតួចតាមស្ថានភាព ដោយសារតែបញ្ហាខ្មែរក្រហមនៅថ្មីថ្មោងនៅឡើយ ។ ហើយពួកគេព្យាយាមធ្វើយ៉ាងណារកម្ហូបអាហារដើម្បីផ្គត់ផ្គង់ជីវិតរបស់ពួកគេ ។

ប្រាំមួយសប្តាហ៍ក្រោយមក ក្រោយពីរស់នៅក្រោមដើមឈើ គ្រួសារត្រូវបានគេដេញចេញដោយខ្មែរក្រហមម្តងទៀត ។ ហើយពួកគេត្រូវចាកចេញក្នុងភាពប្រញាប់ប្រញាល់ ហើយដើរជាច្រើនថ្ងៃតាមទន្លេសាប ហើយពួកគេបានទៅដល់នៅភូមិទួលទ្រាយ ។ ក្នុងរយៈពេលជាច្រើនខែ រហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៧៥ ពួកគេអាចរស់នៅក្នុងជីវិតសាមញ្ញ ។ ហើយយើងអាចពិចារណាថា ជីវិតខ្មែរក្រហមនៅក្នុងអំឡុង ពេលខ្មែរក្រហមពេលនោះវាសាមញ្ញទេនៅខាងដើម ។ ហើយគ្រួសាររស់នៅពេញនៅក្នុងភូមិផ្សេងៗ ហើយគ្រួសាររបស់ខ្ញុំ គឺ យ៉ុង នោះបានប្រាប់ថា ខ្មែរក្រហម គឺល្បួចស្តាប់នៅពេល

យប់នូវការជជែកគ្នាទាំងឡាយ។ ហើយគេបាននិយាយថា ពួកគេមិនមានអាហារគ្រប់គ្រាន់ញ៉ាំនោះទេ។ ហើយពួកគេព្យាយាមរកអាហារ ហើយអាហារចាប់ផ្តើមថយទៅៗ ។ ហើយទាំងអស់នេះគឺជាសញ្ញា-- ហើយពួកគេឃើញមាន់ ទា អីផ្សេងៗ ហើយមាន់ នោះបានពងនៅជិតផ្ទះ ហើយវាជាសញ្ញាមួយដែលប្រាប់ទៅដល់ពួកគេ ហើយបានន័យថា គ្រួសារនោះនឹងទទួលបានពងមាន់ទាំងអស់ដែលមាន់នឹងផ្តល់ឲ្យ ហើយនៅពេលនោះមានបុគ្គលអ្នកឃាមបានមកធ្វើការលួចស្តាប់យកព័ត៌មានដើម្បីធ្វើការស្វែងយល់និងស្រាវជ្រាវអំពីពងមាន់នោះ ។

[០៩:៥៤:០៥]

នៅពេលនោះគេអាចមានពេលវេលាគ្រប់គ្រាន់បោះពងមាន់ចោលទៅក្នុងបង្គន់ ។ ហើយពងមាន់នោះអាចប្រហែលជាផ្តល់អាហារដល់មនុស្សចំនួន១០នាក់ ។ ប៉ុន្តែ ពួកគេបានគ្រវាត់ចោលទាំងអស់ ។ គាត់ក៏បាននិយាយថា ខ្មែរក្រហមឃើញបងស្រីរបស់ខ្ញុំនិយាយភាសាបារាំងជាញឹកញយ ។ ហើយនៅពេលនោះ គឺគាត់មិនអាចនិយាយភាសាខ្មែរបានច្រើន ហើយគឺបងរបស់ខ្ញុំតែងតែនិយាយភាសាបារាំង។ ហើយពួកគេឆ្ងល់ថា តើបងរបស់ខ្ញុំគឺជានរណា? ហើយគេបានបញ្ជូនទៅធ្វើការតាមវាលស្រែផ្សេងៗ ដូចជីដូនមួយរបស់ខ្ញុំដែរ គឺគាត់ធ្វើយ៉ាងណាបង្ហាញថា គាត់ធ្វើការប្រឹងប្រែង ។ ហើយគាត់ព្យាយាមស្លូងស្រូវក្នុងលក្ខណៈមួយដែលជំនាញ ទោះបីជាគាត់កាលពីមុនរស់នៅក្នុងទីក្រុងក៏ដោយ ។

ហើយបន្ទាប់ពីប៉ុន្មានសប្តាហ៍ក្រោយមក ពួកគេត្រូវបានគេនាំយកទៅដាក់ក្នុងអគារ គឺនៅចុងភូមិ ហើយគេថានឹងមានការសួរចម្លើយផ្សេងៗ ។ ហើយនៅពេលនោះគឺក្រុមនោះ ក្រុមបងប្អូនរបស់ខ្ញុំ គឺគេបង្ខំឲ្យប្រាប់នូវការពិត ។ គ្រួសារត្រូវបានគេសួរចម្លើយម្តងមួយៗ ។ ហើយគេបានចងមុខ គេបាននាំសមាជិកគ្រួសារម្តងម្នាក់ៗចូលទៅក្នុងអគារ ។ ហើយនៅពេលដែលបងស្រីរបស់ខ្ញុំចេញមកពីអគារនោះ គឺគាត់បាននិយាយទៅកាន់ជីដូនមួយរបស់ខ្ញុំថា "ខ្ញុំប្រាប់គេថា ខ្ញុំគឺជា ជូឡុង រង្សី ហើយជាកូនរបស់សម្តេចចក្រី ញឹក ជូឡុង ហើយក៏បាននិយាយអំពីការទំនាក់ទំនងជាមួយនឹងសម្តេច សីហនុ" ។ ហើយគឺគាត់គិតថា មានការកើតឡើងហើយក្រោយពេលដែលគាត់ប្រាប់ទៅលើព័ត៌មានទាំងអស់នេះ ។ ប៉ុន្តែ ជីដូនមួយរបស់ខ្ញុំ គឺម្តងម្នាក់ៗក្រោយពីបានសួរចម្លើយ គឺពេលពួកគេបានប្រាប់អត្តសញ្ញាណ ហើយរស់នៅជាមួយគ្នាប៉ុន្មានថ្ងៃនៅភូមិព្រែកពោធិ ។

នៅថ្ងៃមួយនោះពួកគេបានជុំគ្នា ហើយពួកគេបានបំបែកស្ត្រីពីបុរស ហើយគេបាននាំយកស្ត្រីចេញ។ ហើយនៅពេលនោះ ខ្មែរក្រហមបានហៅឈ្មោះបងស្រីរបស់ខ្ញុំទុកគាត់ម្ខាង ហើយក៏បានហៅបុត្រីរបស់

សម្តេច សីហនុ ហើយនៅពេលនោះបងស្រីរបស់ខ្ញុំ គឺស្រែកយំ ។ ដូច្នេះ ជីដូនមួយរបស់ខ្ញុំគឺគាត់ឈប់ផ្តល់ព័ត៌មានទាំងអស់ ហើយបាត់ដំណឹងអំពីបងស្រីរបស់ខ្ញុំ គឺវានៅក្នុងឆ្នាំ១៩៧៥ ខែក្តៅ គឺនៅពេលនោះដែលចូលទៅដល់ទួលស្លែង ។ ហើយគឺយើងឃើញមានរូបថតបងស្រីរបស់ខ្ញុំនិងចម្លើយសារភាព ។

[០៩:៥៧:៣៧]

នៅក្នុងឆ្នាំ១៩៩៤ ខ្ញុំវិលត្រឡប់មកប្រទេសកម្ពុជាវិញ ។ ខ្ញុំដឹងរឿងរ៉ាវពីជីដូនមួយរបស់ខ្ញុំថាបងស្រីរបស់ខ្ញុំបានបាត់ខ្លួននិងស្លាប់ ។ ហើយយើងមិនមានផ្នូររបស់គាត់ទេ ។ ជាទូទៅយើងគួរតែមាន។ ហើយយើងបានធ្វើពិធីបុណ្យសាសនាផ្សេងៗ ដើម្បីឲ្យព្រលឹងរបស់គាត់រស់នៅក្នុងសុគតិភព ។ ហើយខ្ញុំចង់រកភស្តុតាងច្បាស់លាស់អំពីការឃុំខ្លួនរបស់បងស្រីរបស់ខ្ញុំ ។ ហើយខ្ញុំបានទៅទួលស្លែង ហើយនៅពេលនោះទីកន្លែងឯកសារមិនទាន់រៀបចំបានស្រួលនៅឡើយទេ ។ ខ្ញុំបានមើលរូបថតនៅតាមជញ្ជាំងនិងក្តារនៅទួលស្លែង ។

ជាការពិត ខ្ញុំមានការតក់ស្លុតនៅពេលដែល ឃើញមានការភ័យខ្លាចចំពោះរូបភាពអ្នកដែលស្លាប់ កូនក្មេង ស្ត្រី ដែលមើលទៅទំនងជាជនស្លូតត្រង់ ។ ហើយខ្ញុំមានសំណាងណាស់ដែលខ្ញុំអាចរកឃើញរូបថតបងស្រីរបស់ខ្ញុំ ។ ដោយសារតែវាពិបាកណាស់នៅពេលដែលយើងចូលទៅតាមបន្ទប់ហ្នឹង ។ ហើយខ្ញុំបានរកឃើញរូបថតនោះនៅក្នុង បន្ទប់ទីពីរ នៅពេលដែលខ្ញុំចូលទៅដល់បន្ទប់ទីពីរនោះ គឺខ្ញុំបានឃើញ ហើយបន្ទាប់មក គឺខ្ញុំមើលសំណុំឯកសារ ដើម្បីខ្ញុំរកឯកសារជាលាយលក្ខណ៍អក្សរស្តីពីការឃុំខ្លួនរបស់បងស្រីខ្ញុំ ។ ហើយខ្ញុំឃើញទំព័រ ពណ៌លឿងដែលសរសេរភាសាខ្មែរ ប៉ុន្តែខ្ញុំមិនអាចអានខ្មែរល្អនោះទេ ។ ហើយគឺមានសាស្ត្រាចារ្យបារាំងម្នាក់គាត់នៅទីនោះ ហើយគាត់បានបកប្រែឯកសារនោះដល់ខ្ញុំ ។ ហើយខ្ញុំបានទាញយកឯកសាររបស់ រង្សុី ហើយឯកសារនោះត្រូវបានរៀបចំឡើង ហើយចងភ្ជាប់ទៅនឹងសំណុំឯកសារទាំងអស់នោះ ។

គាត់បានស្លាប់នៅថ្ងៃទី៣១ ខែមេសា ឆ្នាំ១៩៧៦ ប៉ុន្តែខ្ញុំមិនដឹងថាវាត្រឹមត្រូវ ឬមិនត្រឹមត្រូវនោះទេ ។ នេះគឺជាមូលហេតុដែលគាត់ត្រូវបានស្លាប់ គឺដោយសារតែគេវាយគាត់រហូតដល់ស្លាប់ ។ ហើយកាលដែលគេថាគាត់ស្លាប់ដោយសារការវាយដំនោះ គឺសរសេរនៅក្នុងសំណុំឯកសារ និងសន្លឹកដែលខ្ញុំទាញចេញយកមកមើលនោះ ។ ក្រោយមក ខ្ញុំសួរអ្នកថតរូបជនជាតិអាមេរិកាំងមួយរូបឲ្យថតរូបថតបងស្រីរបស់ខ្ញុំនៅលើជញ្ជាំងនៅទួលស្លែងដើម្បីអាចឲ្យខ្ញុំធ្វើការសូត្រមន្តលើកទីមួយ ។ ហើយខ្ញុំដាក់រូបថតបងស្រីរបស់ខ្ញុំនៅជិតព្រះពុទ្ធ ដើម្បីរំឭកឲ្យគាត់ និងជូនពរគាត់ឲ្យស្ថិតក្នុងសុគតិភព ។ ហើយនៅ

ពេលនោះ គឺយើងនៅភ្នំពេញ ។

កាលដែលបងប្អូនខ្ញុំមកទួលស្លែងនោះ គឺថាមានការលំបាក ណាស់ពួកគាត់មិនចង់មកនោះទេ ។ ខ្ញុំឃើញ គឺឃើញគាត់បានមកនៅចុងក្រោយ បានមកនៅទួលស្លែង ដើម្បីស្វែងរករូបថតនៅទួលស្លែង។ ដូច្នេះហើយនៅចុងក្រោយជាលើកទីមួយដែលយើងអាចរំឭក និងធ្វើការគោរពវិញ្ញាណក្ខន្ធទៅដល់បងស្រីរបស់ខ្ញុំ ហើយរៀបចំពិធីបុណ្យសាសនាផ្សេងៗទោះបីជាការដែលយើងធ្វើដូច្នោះវាមិនមែនជាបុណ្យសពជាក់លាក់ក៏ដោយ ។ យើងបានធ្វើការប្រមូលយកអ្វីដែលយើងអាចថា គោរពទៅដល់វិញ្ញាណក្ខន្ធគាត់ហើយធ្វើការកសាងជាផ្នូរទាំងបងស្រីរបស់ខ្ញុំ និងបងថ្លៃរបស់ខ្ញុំ ។

[១០:០១:៣១]

ហើយនៅពេលដែលមើលចម្លើយសារភាពផ្សេងៗនោះ គឺវាបានបញ្ជាក់ថា បងស្រីរបស់ខ្ញុំគឺដឹកនាំខ្សែ *សេអ៊ីអា* ។ ហើយ គឺគាត់ត្រូវបាន *សេអ៊ីអា* បានជួលឲ្យបំរើការងារ ។ ហើយបងស្រីរបស់ខ្ញុំទទួលបន្ទុកស៊ើបការណ៍ ។ ហើយបន្ទាប់ពីឆ្នាំ១៩៧៥ ខែមេសា បងស្រីរបស់ខ្ញុំគាត់សរសេរថា គាត់ប្រមូលកម្លាំងធ្វើ ការឆក់ និងប្រមូលដី និងគោក្របី ។ ហើយគាត់សរសេរថា គាត់ជំរុញឲ្យប្រជាជនធ្វើការតតាំងនិងប្រឆាំងទៅនឹងអង្គការបិសាច ហើយនិងធ្វើការញុះញុងប្រជាជននៅខាងក្រៅទីក្រុងភ្នំពេញឲ្យត្រឡប់ចូលភ្នំពេញវិញ ហើយធ្វើការក្តោបក្តាប់យកទីក្រុងភ្នំពេញឡើងវិញ ។ ហើយគាត់បានលើកឡើងថា គាត់សរសេរថា ឲ្យប្រជាជនមានការរៀបចំបាតុកម្ម ហើយប្រមូលម្ហូបអាហារ សម្លៀកបំពាក់ ដូចអ្វីដែលបានធ្វើឡើង ដែលប្រជាជននឹងធ្វើឡើង ។ នៅក្នុងចម្លើយសារភាពគាត់បានសរសេរថា គឺមានការសរសេរថាស្លាប់នៅក្នុងឆ្នាំ១៩៧៦ គឺគាត់ត្រូវបានទទួលទារុណកម្មគិតចាប់ពីឆ្នាំ១៩៧៥ រហូតដល់ពេលគាត់ស្លាប់ ។ ហើយវាមានការភ័យខ្លាច នេះជាការឈឺចាប់ការដែលឈឺចាប់ថា តើគាត់នឹងរងគ្រោះយ៉ាងម៉េច ក្នុងជីវិតមួយថ្ងៃៗរបស់គាត់ក្នុងរយៈពេលប៉ុន្មានខែនោះ? គឺប្រហែលជាគាត់ឈឺចាប់យ៉ាងយូរ យើងបានធ្វើការពិភាក្សាក្នុងចំណោមគ្រួសាររបស់យើង ។ ហើយយើងបានសួរគ្នាថា ហេតុអ្វីបានជាវាមានភាពសាហាវយ៉ាងដូច្នេះ? ហើយហេតុអ្វីបានជាមានភាពអមនុស្សធម៌? ហើយហេតុអ្វីបានជា វាកើតឡើងនៅក្នុងបរិបទទាំងអស់នេះ?

ដោយសារនៅពេលនេះយើងនិយាយអំពីខ្មែរសម្លាប់ខ្មែរខ្លួនឯង ដោយមិនមានមូលហេតុច្បាស់លាស់ ។ ខ្មែរជនជាតិខ្មែរខ្លួនឯងធ្វើឲ្យខ្មែរខ្លួនឯងឈឺចាប់ ។ ហើយបានសម្លាប់បាញ់ខ្មែរខ្លួនឯងដោយកាំភ្លើង ហើយខ្មែរខ្លួនឯងសម្លាប់ជនរួមជាតិរបស់ខ្លួន ។ ពួកគេរីករាយនឹងសម្លាប់ខ្មែរខ្លួនឯង ។ ហើយ

ពួកគេរីករាយនឹងធ្វើឲ្យខ្មែរឈឺចាប់ ។ ហើយបងស្រីរបស់ខ្ញុំ និងបងថ្លៃ របស់ខ្ញុំ គឺគាត់ទទួលរងគ្រោះដែលមិនអាចស៊ូទ្រាំបាន ។

លោកប្រធានអ្វីដែលវាតាមលងយើងខ្ញុំនោះ គឺនៅពេលដែលបងស្រីរបស់ខ្ញុំប្រហែលជាគាត់សួរថា ហេតុអ្វីបានជាបងប្អូនរបស់គាត់មិនមកជួយគាត់? ហេតុអ្វីបានជាបារាំងគាត់មិនមកជួយដែលជាមិត្តភក្តិដ៏ជិតស្និទ្ធ? ហេតុអ្វីបានជាបារាំងមិនមកជួយ ហើយបណ្តេញខ្មែរក្រហមចេញពីការកាន់អំណាច? នោះគឺជាអារម្មណ៍នៃពិរុទ្ធភាព ។ ហើយខ្ញុំបានគិតថា វាជាការបាក់ស្មារតីផ្លូវអារម្មណ៍របស់បងស្រីរបស់ខ្ញុំ។

[១០:០៥:០០]

ហើយ គឺខ្ញុំមិនស្វែងយល់បានទៅលើស្ថានភាពទាំងអស់នេះ ហើយគឺឪពុករបស់ខ្ញុំ គាត់ទ្រាំមិនបានអ្វីដែលកើតឡើងនឹងកូនរបស់គាត់ ហើយខ្ញុំជឿថា អ្វីដែលគាត់ឈឺចាប់នេះឆ្លុះបញ្ចាំងតាមរយៈជំងឺរបស់គាត់ ដែលគាត់ទទួលរងនូវ-- ។ ខ្ញុំចង់បង្ហាញអំពីបុគ្គលិកលក្ខណៈរបស់បងស្រីរបស់ខ្ញុំ ខ្ញុំការពារគាត់ថា គាត់ពិតជាមិនមែន *សេអ៊ីអា* នោះទេ គាត់គឺជាអ្នកដែលនិយាយភាសាបារាំង ហើយគាត់មិនពាក់ព័ន្ធជាមួយនឹងអាមេរិកាំងដែរ ហើយខ្ញុំក៏មិនពាក់ព័ន្ធជាមួយអាមេរិកាំងដែរ ។ ខ្ញុំធ្វើការប្ដូនឆ្នាំជាមួយនឹងអាមេរិកាំងនៅក្នុងឆ្នាំ១៩៧៤ នៅប៉ារីស ហើយបងស្រីរបស់ខ្ញុំមិនមានចំណងជាមួយនឹងអាមេរិកាំងនោះទេ ។ មិត្តរបស់គាត់គឺជាអ្នកវេជ្ជបណ្ឌិតនៅក្នុងទូតអាមេរិកាំង ។ ហើយមិត្តរបស់គាត់នោះ គឺជាសមាជិកនៅក្នុងទូតអាមេរិកាំង ។ ដូច្នេះហើយ គឺគាត់សរសេរតាមរយៈទូតអាមេរិកាំង គាត់គឺជាអ្នកធ្វើការនៅក្នុងផ្នែកវិទ្យុ ។ នៅក្នុងចម្លើយសារភាពរបស់គាត់ គាត់បានបញ្ចូលនូវខ្សែក្បត់ ដែលក្នុងនោះមានអ្នកធ្វើការនៅក្នុងផ្នែកវិទ្យុនៅក្នុងស្ថានទូតអាមេរិកផងដែរ ដែលជាមិត្តភក្តិរបស់គាត់ ដែលគាត់បានបញ្ចូលថាជាខ្សែរបស់ *សេអ៊ីអា* ។

ហើយជាការពិត គឺមុខវិជ្ជាជីវពិតប្រាកដរបស់បងស្រីរបស់ខ្ញុំ គឺគ្រាន់តែជាអ្នកតំណាងខាងផ្នែកមន្ទីរពិសោធន៍តែប៉ុណ្ណោះ ។ ហើយគ្រាន់តែគាត់ជាអ្នកធ្វើការបង្ហាញ ឬការរៀបចំកម្មវិធីកំសាន្តរបស់បារាំងតែប៉ុណ្ណោះ ។ គឺបងស្រីរបស់ខ្ញុំ មិនមានចំណងពាក់ព័ន្ធនឹងសម្ព័ន្ធភាពជាមួយពួកចារករ ឬក៏អង្គភាពចារកម្មណាមួយ *សេអ៊ីអា, កាហ្សេបេ* ឬក៏ភ្នាក់ងារបារាំងទាល់តែសោះ ។ គាត់គ្រាន់តែជាសមាជិកនិងពលរដ្ឋខ្មែរមួយរូបតែប៉ុណ្ណោះ ហើយក៏ដូចជាស្វាមីរបស់គាត់ដែលជាអ្នកធនាគារមួយរូប។

ការខឹងសម្បាដែលយើងមានកាន់តែខ្លាំងឡើងនោះ គឺនៅពេលដែលយើងគិតថាតើពួកគេទាំង

អស់នោះគឺជានរណា? យើងមិនអាចនិយាយប្រាប់ខ្លួនថា អំពីអ្វីដែលវាជាលក្ខណៈអយុត្តិធម៌នោះឡើយ បងស្រីរបស់ខ្ញុំ គឺជាអ្នកដែលគាត់ចូលចិត្តមានភាពរីករាយ ហើយគាត់គឺជាគូរស្វាមីដែលល្អ និងមានភាពជិតស្និទ្ធនឹងគ្នា ។ ហើយគូរស្វាមីខ្មែរនោះ គឺគាត់មិនដែលបង្ហាញអំពីភាពជិតស្និតស្រឡាញ់គ្នានៅចំពោះមុខសាធារណជននោះទេ គឺគ្រាន់តែនៅស្ងៀម ហើយញញឹមដាក់គ្នាទៅវិញទៅមក ។ ហើយគឺជាគូស្វាមី ដែលគាត់មានការស្រឡាញ់គ្នា ហើយគឺគាត់យល់អំពីបរិយាកាសនៅជុំវិញខ្លួន ។ អ្នកទាំងពីរ គឺគាត់ហាក់ដូចជាសម្តែងអាកប្បកិរិយាដូចបងប្អូននឹងគ្នា។ នៅក្នុងវប្បធម៌សង្គមខ្មែរ ដែលថាបងប្រុសត្រូវយកចិត្តទុកដាក់ចំពោះប្អូនស្រី ។ បងស្រីរបស់ខ្ញុំ តែងតែយកចិត្តទុកដាក់នឹងខ្ញុំ និង សូមូរ៉ា ។

ហើយនៅក្នុងឆ្នាំ១៩៧០ នៅពេលដែលគ្រួសារត្រូវបាននិរទេសទៅក្រៅ ខ្ញុំធ្វើការប្រឡងខាងផ្នែកមេធាវី ហើយខ្ញុំនៅទីនោះឈរ និងរស់ដោយម្នាក់ឯង ដោយបងស្រីរបស់ខ្ញុំនៅក្នុងប្រទេសកម្ពុជា។ ហើយខ្ញុំប្រឡងបាក់ឌុបនៅក្នុងខែមិថុនា ខ្ញុំទៅរស់នៅជាមួយនឹងគ្រួសារបារាំង ជាមួយគ្រួសារខ្ញុំនៅបារាំង ។ ហើយនៅពេលនោះ គឺគាត់បានមានស្វាមីឈ្មោះ លឹម គីមម៉ារី ហើយគាត់រស់នៅក្នុងប្រទេសកម្ពុជា ។ ហើយគាត់រស់នៅប្រទេសកម្ពុជាជាមួយគ្នា ចំពោះគូស្វាមីរបស់គាត់ ។ ហើយយើងមិនរស់នៅជាមួយគ្នាទេ គឺយើងរស់នៅដាច់ដោយឡែកពីគ្នា ប៉ុន្តែយើងអាចយល់គ្នា ។ ហើយយើងនៅតែមានមោនភាពចំពោះគ្រួសាររបស់យើង ហើយតារបស់ខ្ញុំ គឺឯកឧត្តម មាស ណាល់ ដែលគាត់នៅក្នុងប្រទេស ។ គាត់បានជម្រាបថា វាជាកិត្តិយស ហើយយើងត្រូវតែឈរដោយខ្លួនឯង យើងជាកូនស្រីរបស់ ញ៉ឹក ជូឡុង ហើយយើងជានៅក្នុងសមាជិកគ្រួសារទាំងអស់ ។ បងប្អូនរបស់ខ្ញុំ គឺធ្វើការរស់នៅជាមួយគ្នាមួយចំនួន ហើយយើងបានរៀនធ្វើម្ហូបជាមួយគ្នា ហើយយើងបានរស់នៅនិងយល់ចិត្តគ្នាទៅវិញទៅមក ។ ហើយយើងក៏បានតែងតែចូលរួមនូវសកម្មភាពដើរលេងជាមួយគ្នា ដូចជា ការមើលខ្សែភាពយន្តជាដើម ។ ហើយ គឺខ្ញុំចូលរួមរំលែកអារម្មណ៍របស់បងស្រីរបស់ខ្ញុំនិងបងថ្លៃរបស់ខ្ញុំ ។ ហើយបងស្រីរបស់ខ្ញុំ និងបងថ្លៃរបស់ខ្ញុំ គាត់មើលថែតារបស់ខ្ញុំ ដែលគាត់បានមើលថែតារបស់ខ្ញុំរហូតដល់ពេលគាត់ស្លាប់ ។

ហើយគាត់ការពារកូនគាត់ បញ្ជូនកូនទៅនៅបារាំង ហើយគាត់ក៏បានការពារខ្ញុំនៅក្នុងឆ្នាំ១៩៧០ នោះនៅពេលដែលខ្ញុំទទួល-- នៅពេលដែលខ្ញុំទទួលសញ្ញាបត្របាក់ឌុប ហើយខ្ញុំបានព្យាយាមរកទិដ្ឋាការទៅប្រទេសបារាំងនោះ គាត់បានជួយខ្ញុំ ហើយអាជ្ញាធរប៉ូលិសនៅពេលនោះ បានចំណាយដើម្បីជួយហើយចំណាយពេលជាពីរបីសប្តាហ៍ ថាតើឪពុកម្តាយរបស់ខ្ញុំធ្វើអី? ហើយគាត់កាលនោះធ្វើការនៅ

ជាមួយសម្តេចនៅប្រទេស--នៅប៉េកាំង? ហើយគាត់ឆ្លើយថា អត់ទេ, ឪពុកម្តាយខ្ញុំនៅប៉ារីសទេ ។ ហើយប៉ូលិសនោះបានសួរចម្លើយនោះ ខ្ញុំអាយុតែ១៨ឆ្នាំទេ ។ បងស្រីខ្ញុំមកជាមួយខ្ញុំ ហើយបងថ្លៃប្រុសខ្ញុំក៏មកជាមួយខ្ញុំ គឺជួយខ្ញុំគ្រប់ពេលវេលា ហើយថាជួយគ្រប់កិច្ចការទាំងអស់ ។ នៅទីបញ្ចប់នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧០ ខ្ញុំបានទទួលវីសាចេញពីប្រទេស ។

គាត់ បងស្រីខ្ញុំក៏បានប្រញាប់ប្រញាល់ទៅអាកាសចរណ៍បារាំង អែរហ្វ្រង់ ដើម្បីទិញសំបុត្រយន្តហោះ ហើយមួយថ្ងៃបន្ទាប់ខ្ញុំបានចេញ ។ ហើយគាត់បានការពារខ្ញុំជារៀងរហូត ប៉ុន្តែគាត់មិនអាចការពារខ្លួនរបស់គាត់បានទេ ។

[១០:១២:៥២]

ដូចដែលខ្ញុំបានជម្រាបអង្គជំនុំជម្រះថា គាត់បានការពារខ្ញុំ ក្រុមគ្រួសារគ្រប់ពេលវេលា តួនាទីរបស់គាត់ គឺជាអ្នកការពារប្អូនៗក្តី ប៉ុន្តែដូចដែលខ្ញុំមកថ្ងៃនេះ ដើម្បីការពារអ្នកដទៃក្នុងក្រុមគ្រួសារ ប៉ុន្តែបងខ្ញុំ ហើយនិងប្អូនខ្ញុំ ថាត្រូវធ្វើដូចម្តេចចំពោះកូនៗ? ប៉ុន្តែទោះជាធ្វើយ៉ាងណាក្តី យើងមិនអាចជំនួសតួនាទីរបស់ឪពុកម្តាយគេបានទេ ចំពោះក្មួយរបស់ខ្ញុំនោះ ។ ខ្ញុំក៏-- អ្វីជាជោគវាសនារបស់គាត់ គឺគាត់ប្រឈមមុខដោយអំពើអយុត្តិធម៌ ប៉ុន្តែខ្ញុំមានការខ្មាស់អៀន ដែលនិយាយថាជាអ្នកប្រកាន់សិទ្ធិសេរីភាពនោះ យើងមានបុព្វសិទ្ធិនៅក្នុងសង្គមមួយដែលថា-- គំនិតមួយដែលថាបងស្រីរបស់ខ្ញុំ គឺជាមនុស្សសាមញ្ញ គឺមិនដែលអួតអាង ទោះបីជាជិះរថយន្តជាមួយ-- អាចជិះបាន*ម៉ាកសឺដេស* ក៏ដោយ ប៉ុន្តែគាត់បរឡានខ្លួនឯងក្នុងឡានសាមញ្ញ ហើយគាត់មិនសម្តែងបង្ហាញខ្លួនថា ខ្លួនជាគ្រួសារ ជូឡុង ទេ គឺគាត់និយាយថា គឺជា គីមារី ធម្មតា ។

នេះហើយ ជារឿងដែលធ្វើឲ្យយើងឈឺចាប់នោះ ជាពេលដែលថា គាត់អះអាងថា ឈ្មោះរបស់គាត់ ព្រោះថាគេអះអាងប្រាប់ខ្មែរក្រហម ក្រែងលោសង្គ្រោះជីវិត ខំលាក់យ៉ាងណាក៏មិនអាចលាក់បាននោះ គឺថាប្រាប់តែឈ្មោះ ជូឡុង គឺមិនអាចប្រាប់ឈ្មោះនាមត្រកូលបានយ៉ាងណាក៏ដោយនោះ ។ នេះអ្វីដែលជា យើងបានឮតាមរយៈជីដូនមួយនោះ ។

នៅក្នុងឆ្នាំជាច្រើនដែលកន្លងផុត ហើយយើងសង្ឃឹមថានឹងមានការជំនុំជម្រះមួយ។ តាមដែលយើងដឹងនោះគឺថា មានអំពើប្រល័យពូជសាសន៍និងបទឧក្រិដ្ឋសង្គ្រាម ។ ហើយយើងដឹងពីសៀវភៅប្រវត្តិសាស្ត្រថា អំពើសោកនាដកម្មដែលបានប្រព្រឹត្តនៅក្នុងពិភពលោក ដូចជាការសម្លាប់ដោយប្រើឧស្ម័ន ការសម្លាប់កុមារ ការធ្វើពិសោធន៍វេជ្ជសាស្ត្រដោយវេជ្ជបណ្ឌិតមួយក្នុងរបបណាហ្ស៊ីនោះ ។

ប៉ុន្តែយើងដឹងថា អ្វីដែលកើតឡើងនៅទួលស្លែងនោះ គឺថាវាមានលក្ខណៈធ្ងន់ធ្ងរខ្លាំងជាងនោះទៅទៀតនៅចំពោះអ្នកទោសមួយចំនួន ។ ពីព្រោះពេលខ្លះឧស្ម័នសម្លាប់នោះ គឺថាអាចនឹងគេសម្លាប់មនុស្សបន្ទាប់ពីរបីថ្ងៃ ប៉ុន្តែបងស្រីខ្ញុំនិងបងថ្លៃរបស់ខ្ញុំនឹងចំណាយពេលប្រាំមួយ ឬប្រាំពីរខែក្នុងអំពើទារុណកម្ម ដែលថាអាចអាក្រក់ជាងអំពើរបស់អាល្លឺម៉ង់ ណាហ្ស៊ី ប្រឆាំងនឹងជនជាតិជ្វីបនោះទៅទៀត ដែលមិនអាចពិពណ៌នាបានអំពីអំពើឃោរឃៅដែលខ្ញុំអាចនិយាយថា ជនជាប់ចោទបានប្រព្រឹត្តអំពើដែលថាមិនអាចពិពណ៌នាបានថា វាឃោរឃៅប៉ុនណានោះទេ ។ គឺជាមនុស្សដែលមានការចេះដឹង ហើយយើងឃើញភាពពិត ដែលថាកំណត់អំពីអត្តសញ្ញាណរបស់ក្រុមគ្រួសារខ្ញុំ អំពីអាយុបងប្អូនស្រីរបស់ខ្ញុំគឺថាសុទ្ធតែត្រឹមត្រូវ ប៉ុន្តែការពិតនោះ គឺអាចនឹងច្រលូកបូកបល់ទៅនឹងអ្វីដែលថា គាត់ឆ្លើយថា ជាភ្នាក់ *សេអ៊ីអា* ជាអ្នកតាមដាន ដើម្បីធ្វើឲ្យពលរដ្ឋបះបោរនេះ គឺថាអាចនឹងធ្វើឲ្យភ័ន្តច្រឡំ ប៉ះពាល់ទៅដល់ការពិត ដែលវាមែនទែនពិតប្រាកដនោះ ។

ក្នុងរបបណាហ្ស៊ីវិញ គេមិនមានការប្រុងប្រយ័ត្នដូចរបបនេះទេ គេគ្រាន់តែចង់កំណត់អំពីអាកប្បកិរិយារបស់គេ ហើយអនុវត្តនៅទីបំផុត គឺថាអាចនឹងរកឲ្យឃើញថា ជនរងគ្រោះជាមានពិរុទ្ធភាព ហើយទារុណកម្ម ដើម្បីឲ្យគេឆ្លើយសារភាពទៅតាមអ្វីដែលខ្លួនចង់បាន ។ ហើយកាបែបនេះក្នុងរយៈពេលវែង ហើយយើងសង្ឃឹមថាថ្ងៃណាមួយនឹងមានការជំនុំជម្រះដោយយុត្តិធម៌ចំពោះឧក្រិដ្ឋជនសង្គ្រាមរបស់ណាស៊ី ។ ហើយ គឺថាមានតុលាការសម្រាប់អតីតយូហ្គោស្លាវី ហើយនិងរ្វ៉ាន់ដា ប៉ុន្តែអ្វីមិនទាន់បានកើតឡើងចំពោះឡើងខ្មែរនៅឡើយទេ ប៉ុន្តែ គឺខ្មែរដែលថាមនុស្សជាងមួយលាននាក់ជាជនរងគ្រោះនោះ ថាតើរឿងហ្នឹងអាចទៅដោយកើតទេ? គឺជារឿងធំធេងដែរឬទេ ដែលមិនមានឆន្ទៈដើម្បី-- អំពើឧក្រិដ្ឋកម្មរបស់គេហ្នឹង ដើម្បីធ្វើការជំនុំជម្រះ? ដែលថាឃាតករមិនទាន់បាននាំមកជំនុំជម្រះ អ៊ីចឹងហើយនៅក្រុមគ្រួសាររបស់យើងនៅតែរង់ចាំៗ ហើយមិនទាន់មានអ្វីកើតឡើងទេកាលនោះ ។

នៅក្នុងឆ្នាំ១៩៩៩ ហើយលោក ពីណូចេ ដែលឧត្តមសេនីយ៍ *ឈីលី* ក៏បានធ្វើដំណើរឆ្លងកាត់ទីក្រុងឡុង ក្រោយមកគេបានប្រព័ន្ធតុលាការអង់គ្លេសបាននាំទៅជំនុំជម្រះ ហើយក៏គេបានធ្វើការចោទប្រកាន់ដោយជោគជ័យ ។ ហើយគិតថា ប្រហែលជាមានសង្ឃឹមអាចនឹងធ្វើរឿងហ្នឹងណាមួយនៅក្នុងប្រទេសបារាំង ដែលថាមិត្តភក្តិជាខ្មែរនៅបារាំងនោះ ខ្ញុំបានសម្រេចដាក់ពាក្យបណ្តឹងមួយអំពីការឃុំខ្លួនបទឧក្រិដ្ឋមួយចំនួន ដែល ឌុច បានធ្វើ ។ ហើយជាថ្មីម្តងទៀត ខៀវ សំផន, ជា ស៊ីម, នួន ជា ហើយ

និង អៀង សារី ។ ខ្ញុំបានឮពីចៅក្រមស៊ើបអង្កេតនៅកាលនោះ គឺថារឿងក្តីនោះត្រូវបានច្រានចោល ដោយមាននិយាយថា ជនរងគ្រោះមិនមែនជាបារាំងទេ ហើយខ្ញុំពេលនោះ-- អាចនឹង គឺថាជនរងគ្រោះកើតនៅក្នុងតំបន់ការពារដោយបារាំង-- មាន ហើយ ល្វីហ្សាប៊េត នោះ គឺថាបានប្រព្រឹត្តនូវបទល្មើសមួយ ដែលថា ក្រោយមកគេបានត្រឡប់មកកម្ពុជា ដើម្បីលើកឡើងអំពីបញ្ហានេះអំពីអំពើនិទណ្ឌភាពនៃការដឹកនាំរបស់ខ្មែរក្រហមនោះ ប៉ុន្តែជាអកុសល នាងក៏មិនបានកាន់តំណែងជាយូរទេ ដើម្បីសម្រេចឱ្យដល់លទ្ធផលដល់ពេលមួយនោះ ។ ប៉ុន្តែ ថ្ងៃនេះនៅពេលដែលឆ្នាំទៅនោះ យើងដឹងថាការជំនុំជម្រះជាអន្តរជាតិនោះនឹងបានបង្កើតហើយ យើងមានសេចក្តីសង្ឃឹមជាថ្មីឡើងវិញ ។

[១០:២០:00]

សុំអនុញ្ញាតពីលោកប្រធាន ដើម្បីសម្តែងនូវអំណរគុណរបស់ខ្ញុំដែលបានផ្តល់ឱកាសរបស់ខ្ញុំ ឱ្យខ្ញុំបាននិយាយក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ឱ្យមានឱកាសដើម្បីនិយាយថាក្រុមគ្រួសាររបស់យើងគឺបានធូរស្រាលអារម្មណ៍ តាមរយៈអង្គជំនុំជម្រះត្រូវបានបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមទោះបីជាអ្នកទាំងអស់ហ្នឹងមិនមានវត្តមានចំពោះលោក លោកស្រីចៅក្រមក៏ដោយ គឺថាអ្នកទាំងអស់នោះ គឺអាចនឹងចូលរួមក្នុងការធ្វើទារុណកម្ម ហើយនិងសម្លាប់បងប្អូនស្រីរបស់ខ្ញុំ និងគ្រួសាររបស់គាត់នោះ គឺបានវត្តមាននៅទីនេះដែរហើយ ។ អ៊ីចឹងហើយក្នុងសាលាក្តីនេះ គឺបើកផ្លូវមួយសម្រាប់ស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនទៀតដែលថា នៅក្នុងតុលាការអនាគតអាចនឹងគេស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីហើយកាន់តែច្រើនទៀត ។ ហើយយើងទទួលស្គាល់នូវតម្លៃបែបនេះ ដែលថាកម្ពុជាឥឡូវនេះគេចាត់ទុកថាជាប្រទេសតូច ។ ប៉ុន្តែ ខ្លួនជាអ្នកបើកទ្វារមួយផ្តល់ឧទាហរណ៍ សម្រាប់ការជំនុំជម្រះបែបនេះដែលថាស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ដែលថាជាឱកាសសំខាន់សម្រាប់យើងទាំងអស់គ្នា ។ សាលក្រមដែលនឹងចេញដោលសាលាក្តីនេះ ហើយចំពោះរូបខ្ញុំហើយនិងចិត្តគំនិតរបស់ខ្ញុំ គឺវាលើសពីអ្វីថាជាបញ្ហារបស់ខ្មែរ គឺថាប្រល័យពូជសាសន៍របស់ខ្មែរ មិនមែនជារឿងរបស់ខ្មែរតែមួយទេ គឺជា គឺអំពើឧក្រិដ្ឋឃាតកម្មក្នុងសាកលលោកដែលគេចាប់អារម្មណ៍ មិនគប្បីឱ្យកើតមានឡើងទេ គឺថាមិនអាចធ្វើឱ្យបុគ្គលដូចជាជនជាប់ចោទ អាចនឹងមានលទ្ធភាពនឹងធ្វើអំពើនេះម្តងទៀតនៅអនាគតនោះ ។ យើងត្រូវតែបង្រៀនជំនាន់ក្រោយខ្មែរ គឺថាឱ្យមានការអប់រំថា បទឧក្រិដ្ឋរបៀបនេះ គឺជាបទឧក្រិដ្ឋ ដែលមិនអាចអត់ឱនបានទាល់តែសោះ។ មិនអាចបិតនៅមិនមានការជំនុំជម្រះ ហើយវាគ្រប់គ្រាន់ហើយ គ្រាន់តែនិយាយថាខ្ញុំសុំទោសថា គឺថាត្រូវតែដាច់ខាត ត្រូវតែមានការដោះស្រាយ ហើយត្រូវមានការកាត់ទោស ។ ហើយ

ខ្ញុំសុំឲ្យ សុំអង្វរក ឲ្យអង្គជំនុំជម្រះចេញនូវសេចក្ដីសម្រេចមួយ នូវសាលក្រមដែលសមស្របទៅតាមបទឧក្រិដ្ឋ ដែលជនជាប់ចោទបានប្រព្រឹត្ត ។ ហើយខ្ញុំមិនមែនជាចៅក្រមទេ ប៉ុន្តែ ខ្ញុំគ្រាន់តែជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះមួយ ខ្ញុំមានគំនិតមួយដើម្បីរំឭកទៅដល់ជនជាប់ចោទ គឺថាដើម្បីឲ្យកាត់ទោស ហើយខ្ញុំនឹងបញ្ជាក់នៅពេលក្រោយ ។

[១០:២៣:១២]

អ្វីដែលខ្ញុំចង់បាននៅក្នុងដំណាក់កាលនេះ គឺថា វង្សី ហើយបងថ្លៃរបស់ខ្ញុំ លឹមគី ម៉ារី ឲ្យទទួលស្គាល់ថា គាត់ជាជនរងគ្រោះរហូតមកទល់នេះ គឺអ្វីដែលមាន គឺយើងមានតែរូបថតនៅលើជញ្ជាំង។

ហើយនិងមានចម្លើយ ដែលផ្អែកទៅលើទារុណកម្ម ដែលចោទថា គាត់ជា *សេអ៊ីអា* ហើយសុំឲ្យទទួលស្គាល់ថា ជាជនរងគ្រោះនៃបទប្រល័យពូជសាសន៍ ។ ហើយចារីជាអ្នកប្រព្រឹត្តហ្នឹងត្រូវតែទទួលស្គាល់ ហើយត្រូវតែមានយុត្តិធម៌សម្រាប់អំពើហ្នឹង។ ហើយនិងសម្រាប់បងស្រីខ្ញុំនិងបងថ្លៃខ្ញុំ ខ្ញុំសង្ឃឹមថា តុលាការនឹងបានស្ដាប់ពាក្យពេចន៍របស់ខ្ញុំ ហើយនិងជា-- ហើយខ្ញុំបានបញ្ជាក់នៅក្នុងធ្វើការអះអាងសម្រាប់បងស្រីខ្ញុំហើយនិងប្ដីរបស់គាត់ ។ ហើយមានការជំនុំជម្រះចំពោះបទឧក្រិដ្ឋប្រហាក់ប្រហែលគ្នានៅក្នុងបស្ចិមប្រទេស ។ ហើយអ្វីអ្នកដែលបញ្ជា យើងទទួលបញ្ជាមក គឺយើងគ្រាន់តែអនុវត្តបញ្ជាដើម្បីកសាងប្រទេស ប៉ុន្តែអ្នកទាំងអស់នោះត្រូវទទួលទណ្ឌកម្មដល់ប្រហារជីវិត គឺថាអ្វីនៅក្នុង *នូរឹមប៊ឺក* គឺថាឈ្មោះរបស់គេ ឈ្មោះ ស្ពែរ *(speer),* អេស *(Hess)* ។ ខ្ញុំមិនអាច មិនអាចនឹងគូសបន្ទាត់ឲ្យស្របគ្នានៅទីនេះទេ ខ្ញុំជឿថា ជនជាប់ចោទមានការទទួលខុសត្រូវ គឺជាការទទួលខុសត្រូវរបស់គាត់ វាមានសារសំខាន់ប្រហែលជាសំខាន់ជាងហ្នឹងទៅទៀត ជាងមនុស្សម្នាក់ដែលត្រូវប្រឈមមុខនៅតុលាការក្ដី *នូរឹមប៊ឺក* នោះទៀត ។

ជនជាប់ចោទ បានសម្ដែងនូវគំនិត ឬក៏ការសុំអភ័យទោស ហើយសម្ដែងនូវវិប្បដិសារី ហើយខ្ញុំសូមរំឭកគាត់ថា នៅក្នុងពាក្យជាក់ស្ដែងថា ថាតើបងស្រីរបស់ខ្ញុំ គឺគាត់ជាអ្នកណា? ហើយខ្ញុំសុំបង្ហាញអនុញ្ញាតបង្ហាញរូបថតរបស់គាត់នៅទួលស្លែង ។ ហើយរូបថតរបស់បងស្រីរបស់ខ្ញុំនៅពេលដែលគាត់មិន ដែលបានជួបគាត់ ឬក៏យើងមិនដែលបានជួបគាត់ទេនោះ ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្ស ណាព្រួស៖**

លោកប្រធានសុំអនុញ្ញាត លោកស្រី ជូឡុង គាត់ចង់បង្ហាញរូបថតពីរ តើអនុញ្ញាតសុំបង្ហាញនៅលើ *ប្រូចិចទ័រ* នៅលើអេក្រង់កុំព្យូទ័រ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយមន្ត្រីតុលាការរៀបចំដាក់បញ្ចាំងនូវរូបថតនោះនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

សូមអញ្ជើញមេធាវី ។

[១០:២៦:៣៤]

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សូណាព្រូស៖**

រូបភាពរបស់ស-២១ នឹងត្រូវបង្ហាញដោយលោកស្រី ជូឡុង គឺថាជារូបថតមួយ ដែលបានរកឃើញនៅក្នុងប្រវត្តិរូប គឺថាមានដោយអ្នកថតរូបរបស់អាមេរិកាំង ដោយគាត់បានរៀបរាប់ពីខាងដើម នឹងពន្យល់ថា ហេតុអ្វីបានយើងមានរូបភាពធំនេះ គឺរូបថតនេះមាននៅជាមួយម្ដាយលោកស្រី ជូឡុង ហើយនៅហ្នឹងផ្ទះ ។ ប៉ុន្តែ លោកស្រី ជូឡុង នោះបានទទួលយកថា យើងឯកភាព និងឲ្យបញ្ចាំងនៅថ្ងៃនេះជូនអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

ទទួលយករូបពីគាត់ទៅ ហើយនិងដាក់ស្កាយនៅម៉ាស៊ីនស្កាយហ្នឹងទៅ ដើម្បីមានរូបភាពនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។ ដូរដាក់រូបភាពទីពីរ ។

**លោកស្រី ជូឡុង អង់តូនីញ៉ា៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំចង់បង្ហាញជនជាប់ចោទ ថាតើនេះជារូបភាពហ្នឹងដែលជនជាប់ចោទកម្ទេចដោយផ្ទាល់ដែរឬទេ? គឺថាជារូបដំបូងដែលគាត់ជួបយើងនៅបារាំងជាលើកចុងក្រោយហើយយើងមុខរបស់គាត់។ ហើយទោះយ៉ាងណា ខ្ញុំសូមអរគុណដែលតុលាការអនុញ្ញាតឲ្យខ្ញុំបាននិយាយដើម្បីនាំពាក្យរបស់នាងជូនអង្គសវនាការ ដែលបញ្ជាក់ដោយជនជាប់ចោទ អំពីវិប្បដិសារីនោះ គឺថាអ្វីដែលអង្គជំនុំជម្រះឃើញហ្នឹង គឺថាអ្វីដែលគាត់-- ខ្ញុំមិនជឿថា អ្វីគាត់លើកឡើងនោះជាការពិតថា ជាការសោកស្ដាយនោះទេ ។ ប៉ុន្តែខ្ញុំគិតថា គាត់មិនខ្វល់ខ្វាយពីរឿងនេះទេនៅក្នុងខែកុម្ភៈ នោះ គឺថា ដែលគាត់ស្វែងរកការសុំអភ័យទោសនោះ គឺថាខ្ញុំប្រគល់នាទីឲ្យអង្គជំនុំជម្រះ ។ ហ្នឹងគឺថាគាត់បានធ្វើហ្នឹងតាមរយៈមេធាវី រូ ប៉ុន្តែខ្ញុំមិនស្ដាប់គាត់ទេ ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថា ដោយហេតុថា ការប្រព្រឹត្តដ៏ឃោរឃៅទៅលើបងស្រីខ្ញុំ និងបងថ្លៃរបស់ខ្ញុំ ។ ហើយខ្ញុំមិនដែលទទួលអ្វីការសុំអភ័យទោសនោះទេ ប៉ុន្តែខ្ញុំចង់ឲ្យគាត់គិតថា ឲ្យមានវិប្បដិសារី ហើយឲ្យការសោកស្ដាយនោះ គឺវាមានទំហំធំធេង គឺថា គឺឲ្យស្មើ

នឹងការទុក្ខសោកផ្លូវចិត្តនិងផ្លូវកាយ ដែលទៅលើជនរងគ្រោះមួយម៉ឺនប្រាំមួយពាន់នាក់នោះ ។ ដូចនេះ ហើយដែលយើងចង់បាននោះខ្ញុំជឿថា ជនជាប់ចោទមានសំណាងដែលគាត់បានប្រឈមមុខនឹងការជំនុំជម្រះ ។ នេះហើយ គឺការតុលាការអន្តរជាតិ ដែលមានការជំនុំជម្រះដោយយុត្តិធម៌ ប៉ុន្តែជនរងគ្រោះទាំងអស់នោះមិនមានឱកាសបែបនេះទេ ។ ថាតើជនរងគ្រោះនោះមានឱកាសទេដើម្បីចំពោះមុខចៅក្រមដើម្បីនិយាយ? ហើយមានសម្លៀកបំពាក់ មានចំណីអាហារធម្មតាទេ? គឺថាគេមិនបានជួបទេ ។ ប៉ុន្តែជនជាប់ចោទ គឺថាអាចសម្រាន្តលក់យ៉ាងស្រួល មានគ្រែ មានខ្នើយភួយធម្មតា ហើយគឺថា គាត់អាចនឹងរស់នៅក្នុងជីវភាពមួយដែលថា ជនរងគ្រោះក្នុងសម័យនោះ គេឈឺចាប់យ៉ាងណា ។ ហើយពួកអ្នកទាំងអស់នោះ គឺមិនដែលនឹងអនុគ្រោះលើកលែងទោសឲ្យគាត់នោះទេ ។ សូមអរគុណលោកប្រធានដែលបានផ្តល់ឱកាសជូនខ្ញុំបានថ្លែង ធ្វើសេចក្តីថ្លែងការណ៍នេះ ។ សូមអរគុណ ។

[១០:០៣:៥៩]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការសវនាការរបស់យើងតទៅទៀត ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីអាចត្រឡប់ទៅរកកន្លែងសម្រាកទីនោះសមរម្យ ហើយចាំដល់ពេលម៉ោងចូលសូមអញ្ជើញចូលមកកាន់ទីនេះ ដើម្បីបន្តនីតិវិធីរបស់យើងតទៅទៀត ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:៣២នាទី ដល់ម៉ោង ១០:៥៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ ហើយជាបន្តនេះ អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ដើម្បីឲ្យមានឱកាសក្នុងការតាំងសំណួរបញ្ជាក់បន្ថែមចំពោះដើមបណ្តឹងរដ្ឋប្បវេណីនេះ ដើម្បីអត្ថប្រយោជន៍នៃបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមនេះ ។ សូមអញ្ជើញ ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សណាព្រូស៖**

សូមអរគុណលោកប្រធាន ។ ចំពោះខ្ញុំៗពុំមានសំណួរបន្ថែមសួរទៅកាន់លោកស្រី អង់តូនីញ៉ា ជូឡុង នោះទេ ។ សេចក្តីថ្លែងការណ៍របស់លោកស្រីនោះ គឺមានការគួរឱ្យចាប់អារម្មណ៍ ហើយគាត់បានថ្លែងសេចក្តីទុក្ខសោកចំពោះគ្រួសាររបស់គាត់ ដែលបានបណ្តាលឡើងដោយការសម្លាប់របស់លោកស្រី ជូឡុង រង្សី ។ បើសិនជាលោកប្រធានអនុញ្ញាតនោះ ខ្ញុំជឿថាលោកស្រី ជូឡុង ចង់សួរសំណួរតាមរយៈលោកប្រធានទៅកាន់ជនជាប់ចោទ ។ ដូច្នេះហើយសូមការអនុញ្ញាតពីលោកប្រធាន សួរសំណួរទៅកាន់ជនជាប់ចោទ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ។ ហើយទន្ទឹមនឹងនេះ សូមរំឭកដល់ជនជាប់ចោទផង សូមមានការត្រងត្រាប់ស្តាប់នូវសំណួរ ដែលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនឹងតាំងសំណួរចំពោះលោកតាមរយៈប្រធាន គឺរូបខ្ញុំ ជាប្រធានអង្គជំនុំជម្រះ ។ អាចរំឭកឡើងវិញអំពីសំណួរដែលសួរ ឬក៏ជាការប្រគល់ផ្ទេរបញ្ជូននូវសំណួរនោះ ដើម្បីឱ្យលោកឆ្លើយតប ដូចដែលយើងបានធ្វើម្សិលមិញ ។

សូមអញ្ជើញលោកស្រី អង់តូនីញ៉ា ជូឡុង ។

**លោកស្រី ជូឡុង អង់តូនីញ៉ា៖**

សូមអរគុណលោកប្រធាន ។ នៅពេលនេះយើងដឹងថា ឬក៏យើងបានរកឃើញថា បងស្រីរបស់ខ្ញុំគឺទទួលរងទារុណកម្មជាច្រើនខែមុនពេលដែលគាត់ស្លាប់ ។ គ្រួសារយើងខ្ញុំចង់ដឹងថា តើបញ្ហារបស់ជនជាប់ចោទយ៉ាងម៉េច? ថាហេតុអ្វីបានជាគេជ្រើសរើសគាត់មកធ្វើទារុណកម្ម ហើយសម្រេចធ្វើការសម្លាប់គាត់?

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទស្តាប់នៅសំណួរនេះបានហើយ ហើយយើងបញ្ជូននូវសំណួរនេះដើម្បីឱ្យជនជាប់ចោទឆ្លើយតបទៅនឹងសំណួរនេះ ។ សូមអញ្ជើញ ។

[១១:០១:២៩]

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន ។ ខ្ញុំសូមឆ្លើយនៅសំណួរនេះដោយសារលោកស្រី អង់តូនីញ៉ា អញ្ជើញមកមានប្រសាសន៍នៅទីនេះ តំណាងឱ្យក្រុមគ្រួសារទាំងមូល ហើយជាពិសេសតំណាងឱ្យលោកជំទាវ

មាស កេត ដ៏ជាទីគោរព ។ ខ្ញុំសូមឆ្លើយនៅសំណួរនេះ ដោយស្មោះ និងដោយត្រង់ដូចតទៅ៖

រង្សុី ទៅដល់ស-២១ តាំងពីខ្ញុំនៅធ្វើអនុប្រធានម្ល៉េះ ។ គេសួរចម្លើយចប់យូរហើយ នៅពេលដែលខ្ញុំឡើងធ្វើប្រធាន រង្សុី ឆ្លើយចប់យូរហើយ តែខ្ញុំគ្មានបានគិត បានគូរអីដល់រឿងទាំងអស់នេះទេ បើតាមឯកសារដែលនៅសល់ រង្សុី ប្រហែលជាស្លាប់ដោយឈឺ នេះដោយឡែក រង្សុី ។ ឯចំណែក លឹម គីម៉ារី វិញខ្ញុំអត់ដឹងទេ ។ ខ្ញុំស្មានតែ លឹម គីម៉ារី នេះ ជាកូនរដ្ឋមន្ត្រី លឹម គី ។ ប៉ុន្តែ ដល់មើលប្រវត្តិមកក្រោយមក ខ្ញុំសន្និដ្ឋានថា លឹម គីម៉ារី ហើយនិង រង្សុី ជីដូនមួយនឹងគ្នា ព្រោះម្តាយរបស់ លឹម គី ឈ្មោះ ញ៉ឹក សេដ្ឋា ។

ដូច្នេះខ្ញុំជម្រាបដោយត្រង់ រឿង លឹម គី ខ្ញុំអត់បានដឹងដំណឹង ទើបតែនឹងក្រោយនៅពេលដែលខ្ញុំ ប៉ុន្តែខ្ញុំទទួលស្គាល់ថា ទាំងពីរនាក់នេះពិតជាទៅស្លាប់នៅស-២១ ដែលដំបូង ខ្ញុំធ្វើជាអនុប្រធាន ក្រោយមកខ្ញុំធ្វើជាប្រធាន ។ ដូច្នេះ ខ្ញុំសូមគោរព រាយការណ៍ជូនប៉ុណ្ណេះ ដោយគោរព ។

**ប្រធានអង្គជំនុំ៖**

នៅសំណួរមួយទៀត អំមិញគឺមានពីរ ។ សំណួរមួយទៀត គឺហេតុផលយ៉ាងដូចម្តេចដែលការជ្រើសរើសយកបងបរបស់គាត់ ហើយយកមកឃុំឃាំងនិងសម្លាប់នៅស-២១ នេះតាមសំណួររបស់គាត់ អំមិញគឺការសម្លាប់ ។ ប៉ុន្តែ ការជ្រើសរើស តើលោកបានដឹងទេ មូលហេតុនៃការជ្រើសរើសយកបងរបស់គាត់ និងបងថ្លៃរបស់គាត់ហ្នឹង យកមកឃុំឃាំង និងសម្លាប់នោះ?

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន ។ ការចាប់មនុស្សចូលមកដាក់ស-២១នេះ វាជាគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ក្រោយ១៧មេសា ចាប់ចូលមកតាំងពីខ្ញុំមិនទាន់ចូលមកដល់ ហើយតាំងពីស-២១ មិនទាន់កើតជារូបរាង ។ នៅពេលដែលស-២១ កើតជារូបរាងហើយ ខ្ញុំបាទនៅជាអនុប្រធាន។ នៅពេលនុ៎ង ខាងជនបទគេចាប់ផ្ញើមកស-២១ ដែលមាន ណាត នៅធ្វើជាប្រធាននៅឡើយ ។ ដូច្នេះ មូលហេតុដែលចាប់ គឺមាគ៌ាបក្សរបស់បក្សកុម្មុយនីស្តកម្ពុជាកំណត់ ។ ឯចំណែក រឿងកម្ទេច ឬក៏ទុកឲ្យស្លាប់ ជាគោលការណ៍នៅក្នុងស-២១ទាំងមូល មនុស្សដែលចាប់ហើយត្រូវតែកម្ទេច ។ ដូចយើងខ្ញុំបានរាយការណ៍ជូនអង្គប្រជុំជាហូរហែមកហើយ អ្នកណាដែលគេចាប់ បក្សចាប់មកប្រគល់ឲ្យស-២១ ហើយ ស-២១ត្រូវតែកម្ទេច ដោយខានមិនបាន អត់ជួយអ្នកណារស់ទេ ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ សូមបញ្ជាក់ជូន ។

[១១:០៥:០៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ តើមានសំណួរអ្វីចង់សួរទៀតទេ បើមានសូមអញ្ជើញ លោកស្រី ជូឡុង អង់តូនីញ៉ា ។

**លោកស្រី ជូឡុង អង់តូនីញ៉ា៖**

អត់ទេលោកប្រធាន ។ សូមអរគុណយ៉ាងច្រើនដែលអនុញ្ញាតឲ្យខ្ញុំតាំងសំណួរសួរទៅកាន់ជនជាប់ចោទតាមរយៈលោកប្រធាន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

តើខាងតំណាងខាងសហព្រះរាជអាជ្ញា តើមានសំណួរអ្វីចង់សួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ?

**លោក វាំងសង់ វ៉ាយដឺដេស្មាឯល៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព ។ ដូចដែលកាលពីម្សិលមិញសហព្រះរាជអាជ្ញាហាក់ដូចជាមិនបាននិយាយទេ ឬក៏មិនបានសួរទេតាមរយៈការថ្លែងសេចក្តីសន្និដ្ឋានសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដូច្នេះហើយ សេចក្តីថ្លែងការណ៍និងសេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺគ្រប់គ្រាន់ហើយ ។ យើងខ្ញុំពុំមានសំណួរចង់សួរបន្តទៀតនោះទេសូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បើសិនជាមាន សូមអញ្ជើញ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន យើងខ្ញុំជាមេធាវីការពារក្តីមិនមានសំណួរអ្វីសួរទៅដើមបណ្តឹងរដ្ឋប្បវេណីទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះផ្តល់ឱកាសដល់ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់នូវខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជូឡុង អង់តូនីញ៉ា ដោយបន្ថែមលើអ្វីដែលលោកបានឆ្លើយតបនូវសំណួរអម្បាញ់មិញនេះ ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ដំបូង ខ្ញុំសូមអនុញ្ញាតលោកប្រធានថ្លែងសេចក្តីគោរពយ៉ាងជ្រាលជ្រៅបំផុត ចំពោះលោកជំទាវ មាស កេត ដែលលោកចាស់ហើយ លោកបានអញ្ជើញមកនៅទីនេះ ។ នេះជាកិត្តិយសមួយសម្រាប់ខ្ញុំ ។ លោកជំទាវ មាស កេត ចាស់ជាងម្តាយខ្ញុំបីឆ្នាំ ។ លោកអញ្ជើញមក ខ្ញុំសូមអរគុណ ហើយសូមថ្វាយបង្គំលោកពីចម្ងាយ ។ នេះជារឿងមួយ ។

ឯចំណែករឿង ជូឡុង រង្សី ខ្ញុំដឹងតាំងពីខ្ញុំនៅធ្វើអាអនុប្រធានម្ល៉េះ ។ ខ្ញុំស្គាល់សំឡេង រង្សី តាំងពីខ្ញុំនៅជាប់គុក ឮសូរសំឡេងតាមវិទ្យុ ។ ដូច្នេះ ជូឡុង រង្សី ចូលមកដល់ស-២១ ខ្ញុំអត់បានទៅអើតមើលមុខគាត់យ៉ាងម៉េចទេ ខ្ញុំឃើញដែលខ្ញុំឡើងធ្វើប្រធានហើយ ឯកសារគឺចប់បាត់ហើយ ។ ពេលនោះ ខ្ញុំជម្រាបដោយត្រង់ ខ្ញុំស្មានតែមកជាប់តែ រង្សី ទេ លឹមគី ម៉ារី គេនៅឯស្រុកបារាំងឯណោះ ។ ដល់ក្រោយមក ខ្ញុំឃើញឱទាំងពីរនាក់ជាប់ពីអង្កាល់ ។ នេះពីរឿងផ្ទាល់ខ្លួនខ្ញុំ ដែលដឹងអំពីរឿងនេះ ។

ដោយឡែកសក្ខីកម្មរបស់ អង់តូនីញ៉ា ជាសក្ខីកម្មរស់ ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររស់ ជាទុក្ខវេទនារបស់ក្រុមគ្រួសារមួយដែលបាត់បង់មនុស្សពីរនាក់ ។ នេះវាជាឯកសារប្រវត្តិសាស្ត្រដែលមានលក្ខណ:អមតៈ ដែលអាចទុកជាកេរដំណែលឲ្យអ្នកស្រាវជ្រាវជំនាន់ក្រោយលោកដឹង ថាឧក្រិដ្ឋកម្មជំនាន់នេះ វាយ៉ាងម៉េច ប៉ះពាល់ដល់គ្រួសារណាខ្លះ គ្រួសារនីមួយៗ វាមានការចុកចាប់ប៉ុនណា ខ្ញុំសូមទទួលស្គាល់ថា នេះជាការពិត ។

ដោយឡែកចំពោះរូបខ្ញុំ ខ្ញុំនៅតែរក្សាពាក្យដដែលអត់វេចវេរស្មារតីទទួលខុសត្រូវចំពោះមុខឧក្រិដ្ឋ-កម្មនេះទេ ។ សូមជម្រាបលោកជំទាវដោយស្មោះ ។ សូមជម្រាបអ្នកស្រីដោយស្មោះ ។

សូមគោរព សូមចប់ ។

[១១:១០:00]

**ប្រធានអង្គជំនុំ៖**

លោកស្រី អង់តូនីញ៉ា ជូឡុង គឺការស្តាប់សេចក្តីថ្លែងការណ៍លោកស្រីក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី គឺបានចប់ហើយ ។ អ៊ីចឹងលោកស្រីអាចសម្រាកបាន ។ សូមអញ្ជើញទៅរកកន្លែងសម្រាកចុះ។

ជាបន្តសូមអញ្ជើញលោកស្រី ហាវ សោភា ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមមួយ អញ្ជើញមកកាន់កៅអីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះនេះ ។

*[លោកស្រី ហាវ សោភា ចូលកាន់កន្លែងអង្គុយ]*

**តាំងសំណួរដោយចៅក្រម៖**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកស្រី តើលោកស្រីឈ្មោះ ហាវ សោភា អ៊ីចឹងពិតមែនដែរឬទេ?

**លោកស្រី ហាវ សោភា៖**

**ឆ៖** ចា៎!

**ស៖** លោកស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** នាងខ្ញុំមានអាយុ៣៣ឆ្នាំ ។

**ស៖** លោកស្រីមានសញ្ជាតិអ្វីដែរ?

**ឆ៖** សញ្ជាតិខ្មែរ ។

**ស៖** លោកស្រីមានទីកន្លែងកំណើតនៅទីណាដែរ?

**ឆ៖** ទីកន្លែងកំណើតនាងខ្ញុំនៅភូមិជ័យមង្គល ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមរំឭកលោកស្រីថា សូមបង្អង់បន្តិច ដើម្បីឲ្យភ្លើងសញ្ញាក្រហមនេះមានសិនសឹមនិយាយទើបសំឡេងរបស់លោកស្រីបានទៅប្រព័ន្ធ ហើយទាំងអ្នកចូលរួម ទាំងសាធារណជនបានស្តាប់សំឡេងរបស់លោកស្រី ហើយនិងប្រតិចារឹកកត់ត្រានូវសម្តីរបស់លោកស្រីបានមានប្រសាសន៍ ។

[១១:១២:៤១]

**ស៖** តើលោកស្រីសព្វថ្ងៃហ្នឹងរស់នៅទីកន្លែងណា ហើយប្រកបមុខរបរអ្វីដែរ?

**លោក អាឡាំង វ៉ែនណឺ៖**

*(គ្មានការបកប្រែ)* ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក អាឡាំង វ៉ែនណឺ តើមានបញ្ហាអ្វីដែរ?

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំសូមអភ័យទោសដែលខ្ញុំកាត់ ខ្ញុំគ្រាន់តែជម្រាបទៅកាន់លោកប្រធានថាកូនក្តីរបស់ខ្ញុំពុំមានឧបករណ៍ស្តាប់សំឡេង ។ សូមអរគុណ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ឪពុកបង្កើតរបស់លោកស្រីគាត់ឈ្មោះអ្វី? ហើយសព្វថ្ងៃហ្នឹង គាត់នៅរស់ ឬក៏ទទួលមរណភាពហើយ?

**លោកស្រី ហាវ សោភា៖**

**ឆ៖** ឪពុកនាងខ្ញុំឈ្មោះ ចិន សៀ ហៅ ហាន សព្វថ្ងៃគាត់ស្លាប់ហើយ ។

**ស៖** ចុះម្តាយរបស់លោកស្រី គាត់ឈ្មោះអ្វីដែរ ហើយសព្វថ្ងៃនេះគាត់នៅរស់ ឬក៏គាត់ទទួលមរណភាពហើយ?

**ឆ៖** ម្តាយឈ្មោះ ញ៉ែម សុផាត សព្វថ្ងៃគាត់នៅរស់ ។

**ស៖** លោកស្រីមានបងប្អូនបង្កើតប៉ុន្មាននាក់?

**ឆ៖** ចាស, មិនមានទេ ។

**ស៖** លោកស្រី ហាវ សោភា ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមមួយ ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមឡើងធ្វើការថ្លែងដោយសង្ខេបនូវអត្តសញ្ញាណនូវរឿងហេតុទាំងឡាយដែលនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានសម្រេចចិត្តក្នុងដាក់ការបណ្តឹងទាមទារ ហើយនិងរឿងរ៉ាវទាំងឡាយដែលមានការពាក់ព័ន្ធទៅនឹងអង្គហេតុបទឧក្រិដ្ឋដែលបានចោទប្រកាន់ជនចំពោះជនជាប់ចោទ និងភស្តុតាងនានាដែលគាំទ្រចំពោះបណ្តឹងនៃដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ សូមអញ្ជើញ ។

[១១:១៥:១៦]

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន ។ សូមគោរពលោក លោកស្រីចៅក្រម កូនក្តីរបស់ខ្ញុំ ហាវ សោភា ដូចដែលលោក លោកស្រី បានជម្រាបហើយ ជាកូនស្រីរបស់ ចិន សៀ ហៅ ហាន ឬក៏ហៅថា ហាវ ហាន ។ ចិន សៀ ត្រូវបានគេឃុំខ្លួននិងបានសម្លាប់ចោលនៅមន្ទីរស-២១ ។ ឈ្មោះរបស់លោកឃើញមាននៅក្នុងបញ្ជីអ្នកទោស ឯកសារ D68/1 ទំព័រ៦៤ ។ ឈ្មោះរបស់លោកក៏បានឃើញនៅក្នុងបញ្ជីអ្នកទោសទី២ ដែលយោងតាមប្រព័ន្ធទិន្នន័យរបស់ *ឌីស៊ីខេម* គឺជាបញ្ជីអ្នកទោសស-២១ ផងដែរ ។ បញ្ជីអ្នកទោសទាំងពីរនោះបានបង្ហាញថា ឪពុករបស់កូនក្តីរបស់ខ្ញុំត្រូវបានគេសម្លាប់នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦ ។ យើងបានដាក់បញ្ជីអ្នកទោសទី២ ហើយនិងការបញ្ជាក់ពីប្រព័ន្ធទិន្នន័យរបស់ *ឌីស៊ីខេម*

កាលពីសប្តាហ៍មុន ។ ហើយយើងក៏បានផ្តល់លិខិតកំណើតរបស់កូនក្តីខ្ញុំ ហើយនៅក្នុងលិខិតកំណើតនោះ ឈ្មោះបានចុះឈ្មោះថា ឪពុករបស់គាត់-- របស់លោកស្រីឈ្មោះ ហាវ ហាន ដូចដែលយើងខ្ញុំបានបញ្ជាក់នៅក្នុងឯកសារ ខ្ញុំដាក់កាលពីសប្តាហ៍មុន បញ្ជីលិខិតកំណើតនោះមានឈ្មោះថា-- ឈ្មោះឪពុកមានឈ្មោះថា ហាវ ហាន ហើយយើងដឹងថា ចិន សៀ ហៅ ហាន ។ លិខិតកំណើតនេះធ្វើនៅឆ្នាំ ១៩៨២ ហើយនៅពេលនោះម្តាយរបស់កូនរបស់ខ្ញុំ ដែលជាប្រពន្ធរបស់លោក ចិន សៀ ។

ប្តីរបស់គាត់ហ្នឹង គឺ ហាវ ហាន ប៉ុន្តែក្រោយមកប្រពន្ធរបស់លោក ហាវ ហាន ដឹងថា ឈ្មោះរបស់ស្វាមីរបស់គាត់ពីដើមគឺ សៀ ។ យើងក៏មានប្រវត្តិរូបរបស់ ចិន សៀ ហើយនៅប្រវត្តិរូបនោះមានសរសេររៀបរាប់អំពីប្រពន្ធរបស់លោក ចិន សៀ ។ ឈ្មោះរបស់លោកស្រីគឺ ញ៉ែម ផាត ។ ហើយ ញ៉ែម ផាត នេះ គឺជាឈ្មោះរបស់ម្តាយកូនក្តីរបស់ខ្ញុំប្រើនៅសម័យខ្មែរក្រហម ប៉ុន្តែ នាពេលបច្ចុប្បន្នឈ្មោះរបស់ម្តាយគឺ សុផាត ដូច្នេះហើយគឺព័ត៌មាននេះ ខ្ញុំគិតថាមិនមានការជំទាស់ឡើយ ហើយគ្មានអ្វីសង្ស័យនោះទេ ។ ចិន សៀ ក៏មានឈ្មោះហៅថា ហាន ឬក៏ ហាវ ហាន ។ ហើយជាការពិតគឺជាឪពុករបស់កូនក្តីរបស់ខ្ញុំឈ្មោះ ហាវ សោភា ។ ដូច្នេះ ខ្ញុំពន្យល់ទាំងអស់នេះ ខ្ញុំជឿថាខ្ញុំបានឆ្លើយតបទៅនឹងសំណួរបឋមរបស់អង្គសវនាការ ហើយខ្ញុំសូមជម្រាបអង្គសវនាការថា យើងបន្តនីតិវិធីយើងយ៉ាងម៉េច? កូនក្តីរបស់ខ្ញុំមិនធ្វើសេចក្តីថ្លែងការណ៍នោះទេ ។ ខ្ញុំនឹងសួរសំណួរទៅកាន់គាត់ ដើម្បីបង្ហាញភស្តុតាង ហើយនៅចុងក្រោយយើងខ្ញុំស្នើសុំការអនុញ្ញាតពីលោកប្រធាន អនុញ្ញាតឲ្យកូនក្តីរបស់ខ្ញុំសួរសំណួរចំនួនបីទៅកាន់ជនជាប់ចោទ ។ សូមអរគុណ ។

[១១:១៩:២០]

**ប្រធានអង្គជំនុំ៖**

ការលើកឡើងរបស់មេធាវីរបស់លោកស្រី តើជាការត្រឹមត្រូវទេដែលលោកស្រីរក្សាសិទ្ធិក្នុងការមិនធ្វើសេចក្តីថ្លែងការណ៍នាពេលនេះនៅចំពោះមុខអង្គជំនុំជម្រះ លោកស្រី ហាវ សោភា?

**លោកស្រី ហាវ សោភា៖**

ចាំ, ត្រឹមត្រូវ ។

**ប្រធានអង្គជំនុំ៖**

បើដូច្នេះអង្គជំនុំជម្រះប្រគល់វេទិកានេះទៅមេធាវី អាឡាំង វ៉ែនណឺ ដែលជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ដើម្បីតាំងសំណួរឲ្យដាក់លាក់ចំពោះកូនក្តីរបស់លោក ។ សូមអញ្ជើញ។

**តាំងសំណួរដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន ។ ជាបឋមខ្ញុំស្នើសុំ សូមៗឲ្យបញ្ចាំងរូបថតរូបដែលខ្ញុំកំពុងកាន់នេះ ខ្ញុំនឹងផ្តល់ជូនមន្ត្រីតុលាការ ។ រូបថតនេះ គឺជារូបថតរបស់ឪពុកកូនក្តីរបស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការទទួលយករូបថតពីមេធាវី អាឡាំង វ៉ែនណឺ ដើម្បីដាក់បញ្ចាំងនូវម៉ាស៊ីនស្លាយ ដើម្បីបង្ហាញរូបភាពនៅកញ្ចក់អេក្រង់ទូរស្សន៍ ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

រូបថតនេះគឺ មាននៅក្នុងប្រវត្តិរូបរបស់កូនក្តីរបស់កូនក្តីរបស់ខ្ញុំដែលបានដាក់អមជាមួយនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។

**ស៖** តើលោកស្រីអាចបញ្ជាក់បានដែរឬទេ? នេះគឺរូបថតរបស់ឪពុករបស់លោកស្រី?

**ឆ៖** ចំា ។

**ស៖** សូមអរគុណ ។ លោកស្រី តើលោកស្រីអាចជម្រាបតុលាការនេះបានដែរឬទេថា ឪពុករបស់លោកស្រីមានតួនាទីអ្វីនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

[១១:២២:០៨]

**ឆ៖** ចំា, ឪពុកខ្ញុំគាត់ធ្វើជាយោធានៅអង្គភាព គ-៩២ ។

**ស៖** តាមអ្វីដែលលោកស្រីបានដឹង តើមានអ្វីកើតឡើងចំពោះជោគវាសនារបស់ឪពុករបស់លោកស្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** នៅឆ្នាំ១៧៥ ខាងអង្គភាពគាត់បានបញ្ជូនគាត់មកពីខេត្តកំពង់ធំទៅ-- មកកាន់រាជធានីភ្នំពេញ ហើយគាត់នៅភ្នំពេញនៅមណ្ឌលបឹងត្របែក ដល់ថ្ងៃទី១៥ ខែ១ ៧៦ មានការចាប់ខ្លួនគាត់តែម្តង ។

**ស៖** តើវាត្រឹមត្រូវដែរឬទេលោកស្រី ថានៅពេលនោះ នៅពេលដែលចាប់ខ្លួនឪពុករបស់លោកស្រី លោកស្រីពុំទាន់ចាប់កំណើតនៅឡើយទេ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ចំា ។

**ស៖** តើលោកស្រីអាចជម្រាបបានដែរឬទេ តាមអ្វីដែលម្ដាយរបស់លោកស្រីជម្រាបលោកស្រីមុនពេលដែលចាប់ខ្លួនឪពុករបស់លោកស្រី ។ ឪពុករបស់លោកស្រីបានប្រាប់ម្ដាយរបស់លោកស្រីថាត្រូវធ្វើយ៉ាងម៉េចមុនពេលដែលមានការចាប់ខ្លួននោះ តើអីចឹងដែរឬទេ?

**ឆ៖** ចំា, មុនពេលមានការចាប់ខ្លួនឪពុកខ្ញុំ គាត់ធ្លាប់បានផ្ដាំនឹងម្ដាយខ្ញុំថាឲ្យគាត់តស៊ូរស់ រស់ដើម្បីជីវិតទៅថ្ងៃមុន ។

**ស៖** ថាតើលោកស្រីចាំទេ ថាឪពុករបស់លោកស្រីបាននិយាយអ្វីផ្សេងពីហ្នឹងទេប្រាប់ម្ដាយរបស់លោកស្រី?

**ឆ៖** គាត់ធ្លាប់ផ្ដាំឲ្យម្ដាយខ្ញុំរៀបការគ្រួសារថ្មី ហើយថ្ងៃមួយគាត់មានការប្រជុំនិយាយជាភាសាវៀតណាម ប៉ុន្តែគាត់ប្រជុំរួចគាត់និយាយភាសាខ្មែរ ដោយគាត់មិនដឹងថាម្ដាយខ្ញុំនៅស្ដាប់ពីក្រោយខ្នងគាត់និយាយថា ពួកយើងប្រហែលមិនអាចរស់ទេ គាត់និយាយជាមួយមិត្តភក្តិគាត់ ជាខ្មែរដូចគ្នាហ្នឹងថាពួកយើងមិនអាចរស់បានទេមើលទៅ ព្រោះបើបក្ខបែកជាពីរយើងប្រហែលជាត្រូវស្លាប់ក្រោមទង់បក្ខ។

[១១:២៥:00]

**លោក អាឡាំង វែនណឺ៖**

**ស៖** នៅពេលនេះ តើវាមានរយៈពេលប៉ុន្មានក្រោយពីការចាប់ខ្លួនរបស់ឪពុករបស់លោកស្រីនោះដែលលោកស្រីចាប់កំណើត?

**ឆ៖** គេយកឪពុកៗខ្ញុំទៅ២១ថ្ងៃ ទើបខ្ញុំកើត ។

**ស៖** តាមអ្វីដែលលោកដឹងក្រោយ តើមូលហេតុអ្វីបានជាគេចាប់ឪពុកលោកស្រី តើលោកស្រីបានដឹងទេ?

**ឆ៖** ម៉ែគាត់មិនដែលដឹងថា ឪពុកខ្ញុំមានកំហុសអ្វីទេ ដែលត្រូវគេចាប់ទៅហ្នឹងនោះ ។

**ស៖** ចំពោះលិខិតកំណើតរបស់លោកស្រីថា តើវាត្រឹមត្រូវដែរឬទេ? ថាថ្ងៃខែឆ្នាំកំណើតនោះដែលចុះនៅក្នុងលិខិតកំណើត គឺខែកញ្ញា ឆ្នាំ១៩៧៦ តើវាមិនត្រឹមត្រូវ ឬក៏វាត្រឹមត្រូវ សូមឲ្យលោកស្រីបញ្ជាក់?

**ឆ៖** ចាស,នៅក្នុងសំបុត្រកំណើតហ្នឹង ខុសខែប្រាំបួន តាមពិតទៅខ្ញុំកើតនៅខែ២ នៅក្នុងប័ណ្ណបោះឆ្នោតខ្ញុំ បានបញ្ជាក់ ខ្ញុំកើតខែ២ ។ ប៉ុន្តែ វាជាលក្ខណៈខុសបច្ចេកទេសរបស់មន្ត្រីមូលដ្ឋានដែលធ្វើសំបុត្រកំណើត ។

**លោក អាឡាំង វែនណឺៈ**

លោកចៅក្រម យើងបានរកឯកសារហ្នឹង ហើយគឺជាប័ណ្ណបោះឆ្នោត ដែលប័ណ្ណបោះឆ្នោតនេះ គឺវាបញ្ជាក់ថ្ងៃខែកំណើតយ៉ាងត្រឹមត្រូវ ហើយខ្ញុំស្នើសុំកាលពីម្សិលមិញ ដែលខ្ញុំធ្វើការសម្របសម្រួលជាមួយនឹងក្រឡាបញ្ជីសុំដាក់កាលពីម្សិលមិញ ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន បានកាលពីម្សិលមិញ ។

**សៈ** សូមអរគុណលោកស្រី ។ តើលោកស្រីអាចពន្យល់ទេ តាមអ្វីដែលម្ដាយប្រាប់លោកស្រី តើមានអ្វីកើតឡើងចំពោះការបាត់ខ្លួនរបស់ឪពុករបស់លោកស្រីនោះ?

**ឆៈ** ពេលខ្ញុំធំដឹងក្ដីពេលណាមក ម្ដាយខ្ញុំតែងតែនិយាយអំពីឪពុករបស់ខ្ញុំ ប្រាប់ខ្ញុំជានិច្ច ។ តាំងពីពេលដែលគាត់រស់នៅជាមួយគ្នារហូតដល់បែកបាក់ពីគ្នាទៅជារៀងរហូត ។

**សៈ** តើលោកស្រីអាចជម្រាបៗបានដែរឬទេថា តើក្រោយពីការចាប់ខ្លួនឪពុករបស់លោកស្រីនោះតើម្ដាយរបស់លោកស្រីចាំគាត់រយៈប៉ុន្មានដែរ ពីការចាប់ខ្លួនចាំឲ្យគាត់វិលត្រឡប់មកវិញនោះ?

**ឆៈ** ម៉ែគាត់ចាំឪពុកជារៀងរហូត ។ រហូតដល់ថ្ងៃដែលគាត់ដឹងថា ឪពុកខ្ញុំស្លាប់នៅទួលស្លែងនៅឆ្នាំ២០០៦ *(ស៊ិក)* ។

[១១:២៩:០២]

**សៈ** ថាតើនៅពេលណាដែរ តាមអ្វីដែលលោកស្រីចាំនោះ?

**ឆៈ** គាត់ចាំឪពុកតាំងពីឆ្នាំ៧៦ រហូតដល់ពេលគាត់សម្រាលខ្ញុំរួច ។ គាត់ចាំរហូតដល់ពេលគាត់ទៅរស់នៅក្បាលជ្រោយ ។ រស់នៅក្បាលជ្រោយ គាត់តែងទៅលួចបីកូនឈរចាំប្ដីនៅមាត់ទន្លេ ។ ខ្ញុំកើតបានប្រាំបួនខែ អង្គការនិយាយថា គ្រួសារមិត្តត្រូវគេកម្ទេចហើយ ។ គាត់ចាំៗតាំងពីឆ្នាំ៧៦ ដល់ថ្ងៃរំដោះឆ្នាំ៧៩ គាត់ពរខ្ញុំដើររកឪពុកខ្ញុំទៀត រហូតដល់ឆ្នាំ៨១ មានការធ្វើមាតុភូមិនិវត្តន៍ ម្ដាយខ្ញុំចាំឪពុកខ្ញុំទៀត ។ គាត់ចាំដំណើរនៃការវិលវិញរបស់ឪពុកខ្ញុំ តែគ្មានឃើញៗស្រមោលគាត់ទេ ។ មានតែញាតិគេ ប្ដីគាត់បាត់ទៅជារៀងរហូត ។ ទោះគាត់ដឹងថា គេសម្លាប់ប្ដីគាត់ហើយ តែចិត្តមួយគាត់នៅតែសង្ឃឹមថ្ងៃណាមួយឪពុកខ្ញុំនឹងវិលមកវិញ វិលមកជុំជាមួយគ្រួសារ ជាមួយកូន ជាប្រពន្ធ ផ្ដល់ភាពកក់ក្ដៅឲ្យគ្រួសារ ។ តែការសង្ឃឹម និងការរង់ចាំវាមិនបានដូចបំណងយើងទេ ។ រហូតដល់ឆ្នាំ២០០៦ ទើបខ្ញុំដឹងដំណឹងថា ឪពុកខ្ញុំបាត់បង់ជីវិតនៅកន្លែង ដែលសាហាវបំផុតនៅគុកទួលស្លែង ។

**លោក អាឡាំង វែនណឺ៖**

បាទ, សុំអនុញ្ញាតពីលោកប្រធាន មីក្រូហ្វូនអត់បើកទេបាទ ។ មីក្រូហ្វូនដែលកូនក្ដីខ្ញុំនិយាយអត់បានបើកទេ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការមើលមីក្រូហ្វូនដើមបណ្ដឹងរដ្ឋប្បវេណី នៅមុខគាត់ហ្នឹង មើលឲ្យស្រួលបួលមើល។ ឮដាច់ៗ ។

**លោក អាឡាំង វែនណឺ៖**

**ស៖** លោកស្រី សូមឲ្យលោកស្រីរៀបរាប់ឡើងវិញនូវប្រយោគចុងក្រោយ ប៉ុន្មានប្រយោគអំម្បាញ់មិញជូនអង្គសវនាការជ្រាប ។

**លោកស្រី ហាវ សោភា៖**

**ឆ៖** ម៉ែចាំឪពុក ចាំពីឆ្នាំ៧៦ ដល់ឆ្នាំ៧៩ គាត់បន្តចាំរហូតដល់ឆ្នាំ៨១ ចាំមើលការវិលត្រឡប់មកវិញរបស់គាត់ពេលគេធ្វើមាតុភូមិនិវត្តន៍ ។ ប៉ុន្តែទីបំផុត គ្មានការវិលមកវិញរបស់ឪពុកខ្ញុំទេ ។ នៅឆ្នាំ២០០៦ ទើបខ្ញុំដឹងថា ឪពុកខ្ញុំបាត់បង់ជីវិតនៅគុកទួលស្លែង ។ ខ្ញុំមិនដែលនឹកស្មានសោះ ថាគាត់ត្រូវបាត់បង់ជីវិតនៅកន្លែងដែលពិឃាដមនុស្សដ៏សាហាវបំផុតនៅក្នុងរបបខ្មៅងងឹតនោះ ។

**ស៖** លោកស្រីបានរៀបរាប់ គឺចាប់ពីឆ្នាំ១៩៨០ ដែលវាជាការធ្វើមាតុភូមិនិវត្តន៍ តើក្រោយពីឆ្នាំ១៩៨០, ៨១, ៨២ និង៨៣ នោះ ម្ដាយលោកស្រីនៅតែសង្ឃឹមដដែលថានឹងបានជួបឪពុករបស់លោកស្រីឬយ៉ាងម៉េច?

**ឆ៖** ចាស, គាត់នៅតែបន្តនូវការរង់ចាំរបស់គាត់ជារៀងរហូត គាត់មិនដែលភ្លេចការព្យាយាមរង់ចាំប្ដីគាត់ទេ ។ គាត់ចាំៗរហូតដល់ថ្ងៃដែលគាត់ដឹងដំណឹង ទើបគាត់អស់សង្ឃឹម ។ គាត់អស់សង្ឃឹមហើយគាត់ធ្លាក់ចិត្ត ធ្លាក់ទៅជាជំងឺផ្លូវចិត្តធ្ងន់ធ្ងរនៅពេលដែលគាត់បានមកកាន់សារៈមន្ទីរទួលស្លែង គាត់បានឃើញបន្ទប់ឃុំឃាំងប្ដីគាត់មុនដែលគាត់បាត់បង់ជីវិតទៅ ។ គាត់ស្ទើរតែស្រែកយំៗនៅទីនោះ ប៉ុន្តែគាត់ខំទប់អារម្មណ៍ ទប់ចិត្តគាត់ ។ គាត់ទប់នូវការរំជួលចិត្តរបស់គាត់ គាត់ត្រឡប់ទៅវិញទាំងអារម្មណ៍សោកសៅ ។ គាត់ស្ដាយមនុស្សដែលជាទីស្រឡាញ់របស់គាត់ ហើយជាមនុស្សដែលល្អដែលមនុស្សគាត់សង្ឃឹមថា នឹងផ្ដល់ក្ដីសង្ឃឹមឲ្យកូននិងប្រពន្ធ ។ ទីបំផុតគាត់ត្រូវបញ្ចប់ជីវិតដែលមិនដឹងគាត់ត្រូវមានកំហុសអ្វីផង ។

**ស៖** តើលោកស្រីអាចបញ្ជាក់ជូនតុលាការដែរឬទេ នៅក្នុងឆ្នាំ២០០៦ នៅពេលនោះដែលលោកបានឃើញចម្លើយសារភាពរបស់ឪពុកលោកស្រីតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជានៅមន្ទីរស-២១ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស, ត្រឹមត្រូវ ។

[១១:៣៥:៤៦]

**ស៖** តើលោកស្រីអាចជម្រាបតុលាការនេះបានដែរឬទេ? ហេតុអ្វីបានជាម្តាយរបស់លោកស្រីមិនតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ?

**ឆ៖** មូលដ្ឋានដែលធំបំផុតដែលគាត់មិនដាក់ពាក្យបណ្តឹងមិនចូលរួមនៅក្នុងសាលាក្តី ព្រោះគាត់មិនចង់ប្រឈមមុខនឹងជនជាប់ចោទ ។

**ស៖** តើលោកស្រីអាចជម្រាបតុលាការនេះបានដែរឬទេ? ម្តាយរបស់លោកស្រីបានរៀបអាពាហ៍ពិពាហ៍សាជាថ្មី?

**ឆ៖** គាត់មិនបានរៀបអាពាហ៍ពិពាហ៍សាជាថ្មីទេ ព្រោះគាត់នៅតែរង់ចាំឪពុករបស់ខ្ញុំរហូតដល់ថ្ងៃដែលគាត់ដឹងដំណឹងថា ឪពុករបស់ខ្ញុំបាត់ជីវិតពិតប្រាកដនៅទួលស្លែង ។ ហើយក៏គាត់គ្មានបំណងរៀបការជាមួយបុរសណាទៀតដែរ ។

[១១:៣៦:៥០]

**ស៖** ប្រសិនបើខ្ញុំអាចធ្វើទៅបាននោះ ខ្ញុំសូមសួរលោកស្រីអំពីសំណួរផ្ទាល់ខ្លួនមួយចំនួនចំពោះលោកស្រី តើលោកស្រីអាចជម្រាបជូនតុលាការនេះដែរឬទេ? ថាតើវាមានការប៉ះពាល់ដល់លោកស្រីយ៉ាងម៉េច នៅពេលដែលលោកស្រីបាត់បង់ឪពុករបស់លោកស្រីនោះ?

**ឆ៖** នៅពេលដែលខ្ញុំក្លាយជាក្មេងកំព្រាខ្ញុំគ្មានឪពុក ជីវភាពវាមិនបានធូរធាដូចគេអ្នកដែលមានគ្រួសារ គេមានឪពុកមានទាំងម្តាយទេ ។ ជីវិតក្រលំបាកនៅពេលប្រទេសទើបងើបផុតពីសង្គ្រាម ជាប្រទេសក្រីក្រណាស់ ។ ជីវិតប្រជាជនទាំងអស់សុទ្ធតែជួបនឹងការលំបាកដូចគ្នា តែចំណែកគ្រួសារខ្ញុំជាគ្រួសារដែលលំបាកបំផុត ។ ខ្ញុំនៅជួបនូវការលំបាកទាំងផ្នែកការសិក្សា ទាំងផ្នែកសេដ្ឋកិច្ច ទាំងផ្នែកផ្លូវចិត្ត ។ ខ្ញុំខំរៀន ម៉ែធ្លាប់និយាយថា ឲ្យខ្ញុំរៀនទៅថ្ងៃណាឪពុកត្រឡប់មកវិញ យើងនឹងរៀនបន្ត ។ ខ្ញុំប្រាប់ម៉ែថា បើខ្ញុំរៀន ខ្ញុំនឹងធ្វើជាគ្រូបង្រៀន តែក្តីបំណងរបស់ខ្ញុំវាមិនបានសម្រេច ព្រោះយើងគ្មានថវិកាត្រូវបន្តការសិក្សាទៀត ។ ដូច្នេះ វាធ្វើឲ្យជីវិតខ្ញុំធ្លាក់នៅក្នុងអន្លង់មួយ អន្លង់ដ៏ជ្រៅ ។ ជីវភាព

លំបាក ក្ដីបំណងរបស់ខ្ញុំមិនបានសម្រេច សព្វថ្ងៃខ្ញុំរស់បានដោយសារតែប្រកបរបរតិចតួចប៉ុណ្ណោះ ។

**ស៖** តើវាត្រឹមត្រូវទេ ដែលថាលោកស្រីបញ្ឈប់ការសិក្សាតាំងពីអាយុ១៧ឆ្នាំនោះ គឺនៅថ្នាក់ទី៧ ឈប់រៀន?

**ឆ៖** ចាស ត្រឹមត្រូវ ។

**ស៖** តើអាចជម្រាបតុលាការទេ ហេតុអ្វីបានជាលោកស្រីបញ្ឈប់ការសិក្សានៅពេលនោះ? ហើយពេលនោះលោកស្រីអាយុប៉ុន្មានដែរ ពេលឈប់រៀននោះ?

**ឆ៖** មូលហេតុដែលខ្ញុំបញ្ឈប់ការសិក្សា ព្រោះខ្ញុំគ្មានថវិកាបន្តការសិក្សាទៀតបានទេ ព្រោះម្ដាយខ្ញុំគាត់ក្រណាស់ពេលនោះ ។ នៅក្នុងផ្ទះ នៅឆ្នាំ៨០ ក្នុងផ្ទះគាត់ទាំងមូលគាត់ប្រាក់ដល់១000រៀលផង មានរឿងអីដែលគាត់ឲ្យខ្ញុំរៀនសូត្របាន ។

ខ្ញុំត្រូវបញ្ឈប់ការសិក្សា ខ្ញុំដេកយំ ខ្ញុំស្រមៃមកន្លែងខ្ញុំធ្លាប់អង្គុយរៀន ស្រមៃមកន្លែងដែលខ្ញុំធ្លាប់ប្រឡែងលេងជាមួយមិត្តភក្ដិ ខ្ញុំស្រមៃឃើញគ្រូបង្រៀន បង្រៀនអក្សរសាស្ត្រខ្មែរដល់ខ្ញុំ ។ ពេលនោះ ខ្ញុំអាយុទើបតែ១៦,១៧ ឆ្នាំប៉ុណ្ណឹងឯង តែដោយក្ដីព្យាយាមខ្ញុំនៅតែចង់រៀន ។ ខ្ញុំធ្លាប់ឈប់សិក្សាម្ដងនៅថ្នាក់ទីបួន ប៉ុន្តែដោយគ្រូប្រចាំថ្នាក់គាត់ស្រឡាញ់រាប់អានខ្ញុំ គាត់បានមកសុំម្ដាយខ្ញុំ សុំឲ្យខ្ញុំរៀនៗដោយមិនបាច់បង់គួរដល់គ្រូទេ ។ ខ្ញុំទៅរៀងម្ដង ម្ល៉េះបើកុំតែមានគ្រូប្រចាំថ្នាក់ទីបួនឲ្យខ្ញុំរៀនបន្តម្ល៉េះខ្ញុំឈប់តាំងពីថ្នាក់ទីបួន ព្រោះខ្ញុំគ្មានថវិកា តែខ្ញុំទៅសាលាខ្ញុំត្រូវបង់ប្រាក់បណ្ដាក់ ខ្ញុំគ្មានថ្លៃបង់សាលាគ្រប់គ្រាន់ទេ ។ ខ្ញុំបង់បណ្ដាក់ពាក់កណ្ដាលឆ្នាំទើបខ្ញុំបង់ចប់ ។

**ស៖** តើលោកស្រីអាច តើត្រូវការសុំពេលសម្រាកបន្តិចដែរឬទេ?

**ឆ៖** ទេ, អត់អីទេបន្តទៀតចុះ ។

**ស៖** តើលោកស្រីប្រាប់តុលាការបានទេ ថាតើការប្រាថ្នារបស់លោកស្រីគឺចង់ធ្វើជាគ្រូបង្រៀននោះ?

**ឆ៖** ចាស, នាងខ្ញុំធ្លាប់ប្រាថ្នាធ្វើជាគ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ព្រោះខ្ញុំស្រលាញ់មុខវិជ្ជានេះណាស់ ។ ប៉ុន្តែ ការប្រាថ្នារបស់យើងវាបានត្រឹមតែគិតនៅក្នុងចិត្ត ការស្រមៃតែប៉ុណ្ណឹងឯង ព្រោះតាំងពីពេលនោះរហូតមកខ្ញុំមិនដែលបានចូលសាលារៀនទៀតទេ ។

**ស៖** ឥឡូវនេះលោកស្រីអាចប្រាប់តុលាការបានទេ អំពីហេតុការណ៍នៅក្នុងឆ្នាំ២០០៦ លោកស្រីដឹងថា ឪពុករបស់លោកស្រីត្រូវបានគេឃុំខ្លួន ហើយត្រូវបានគេសម្លាប់នៅស-២១ គឺនៅស-២១ មិន

មែនកន្លែងផ្សេងទេ? តើការដឹងដំណឹងនោះមានន័យដូចម្តេចដែរពេលនោះ? តើលោកស្រីអាចជម្រាបតុលាការបានទេ?

**ឆ៖** ចាស, នៅពេលដែលនាងខ្ញុំទទួលដំណឹងថា ឪពុកខ្ញុំជាប់ឃុំឃាំងនៅមន្ទីរស-២១ ខ្ញុំមានអារម្មណ៍ក្តុកក្តួល ខ្ញុំស្ទើរតែស្រែកយំៗឲ្យឆ្អែត ប៉ុន្តែខ្ញុំខំទប់អារម្មណ៍ ។ ខ្ញុំនឹកស្រណោះ ខ្ញុំនឹកអាណិតគាត់ ដែលគាត់ជាមនុស្សល្អទោះខ្ញុំមិនធ្លាប់ជួបគាត់ មិនធ្លាប់ហៅគាត់បានពាក្យពុកមួយម៉ាត់ក៏ដោយ តែខ្ញុំធ្លាប់ដឹងពីគុណសម្បត្តិ និងភាពល្អប្រពៃរបស់គាត់ ម៉ែគាត់ធ្លាប់និយាយប្រាប់ខ្ញុំជារឿយៗតាំងពីពេលដែលខ្ញុំចេះចងចាំមក ម៉ែនិយាយប្រាប់ខ្ញុំ ធ្វើឲ្យខ្ញុំនឹកអាណិតគាត់ ដែលគាត់ត្រូវបាត់បង់ជីវិតនៅកន្លែងមួយដែលសាហាវបំផុត ។

[១១:៤៤:០៧]

**ស៖** តើត្រូវដែរទេ? ដែលថាលោកស្រី ហើយនិងម្តាយបានមកភ្នំពេញហើយក៏បានទៅមើលទួលស្លែង តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** ចាស, ថ្ងៃទី៩ មករា ២០០៧ ម្តាយខ្ញុំពេលក្រោយពីគាត់ដឹងដំណឹងថាឪពុកខ្ញុំជាប់ឃុំឃាំងនៅស-២១ គាត់បានធ្វើដំណើរមកភ្នំពេញ ហើយគាត់ឲ្យឪពុកមាខ្ញុំជូនគាត់ទៅកន្លែងឃុំឃាំងគាត់នៅស-២១ ។ នៅពេលដែលគាត់ទៅដល់គាត់ឃើញមន្ទីរឃុំឃាំងតាមក្រដាសដែលគាត់បានទៅហ្នឹង គឺអគារ “គ” បន្ទប់ធំ៥ បន្ទប់តូច៤ ពេលគាត់ទៅដល់គាត់ឃើញស្ថានភាពនៅពេលនោះ ម្តាយខ្ញុំធ្លាក់ទឹកចិត្តជាខ្លាំង គាត់ឈរសម្រក់ទឹកភ្នែកតែម្នាក់ឯង ។ ខ្ញុំខ្លោចចិត្តនឹងការឈឺចាប់របស់ម្តាយខ្ញុំណាស់ ។ ពួកយើងបានត្រឹមឱបគ្នាយំនៅពេលឃើញកន្លែងឪពុកខ្ញុំរស់នៅមុនពេលគាត់ស្លាប់ ។

**ស៖** តើលោកស្រីមិនមានការលំបាកខ្លាំងដែរឬទេ? តើអាចជម្រាបតុលាការបានទេ តើអ្វីកើតឡើងនៅស-២១ នៅពេលដែលម្តាយរបស់លោកស្រីបានឃើញទីកន្លែង ដែលឃើញមានគំនរខោអាវមួយនៅមួយកន្លែង ថាតើនៅពេលនោះមានហេតុការណ៍ដូចម្តេចកើតឡើង ចំពោះម្តាយលោកស្រី និងលោកស្រី?

**ឆ៖** ចាស, នៅពេលដែលគាត់ដើរទៅ គាត់ឃើញមានអគារមួយគេដាក់សម្លៀកបំពាក់អ្នកទោស ម្តាយខ្ញុំគាត់មានចិត្តមួយគិតថា បើសិនបើផ្នែកខាងរដ្ឋបាលនៅសារមន្ទីរហ្នឹងគេអនុញ្ញាតឲ្យគាត់មើលខោអាវដែលដាក់ទុកនៅគរនោះ គាត់នឹងរើមើល គាត់ស្គាល់សម្លៀកបំពាក់ប្តីគាត់មុនពេលគាត់ចេញទៅ ប៉ុន្តែគាត់មិនហ៊ានសុំទេ ពីព្រោះថានេះជាច្បាប់របស់សារមន្ទីរ ។

**សះ** តើលោកស្រីអាចជម្រាបតុលាការបានទេ អំពីក្តីស្រមៃដែលលោកស្រីមានបន្ទាប់ពីទស្សនៈកិច្ចទួលស្លែងពីរខែរួចមកនោះតើក្តីប្រាថ្នាដូចម្តេចដែរ?

**ឆះ** នៅពេលដែលខ្ញុំបានទៅមើលទិដ្ឋភាពនៅគុកទួលស្លែង ខ្ញុំត្រឡប់មកវិញ ខ្ញុំមានចិត្តចង់ដាក់ពាក្យបណ្តឹង ។ ខ្ញុំបានទៅអង្គការមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានទៅសុំឱ្យគេថតរូបថតច្បាប់ដើមឪពុករបស់ខ្ញុំបានពីរសន្លឹក ។ ពេលនោះខ្ញុំត្រឡប់ទៅកំពង់ធំវិញ ហើយខ្ញុំមានបំណងដាក់ពាក្យបណ្តឹងនៅពេលដែលខ្ញុំដឹងថាមានសាលាក្តីកើតឡើង ។ ដោយសារខ្ញុំស្រមៃឃើញថា ទិដ្ឋភាពនៅទួលស្លែងវាសាហាវបំផុត ខ្ញុំមិនអាចឈរឱបដៃមិនដាក់ពាក្យបណ្តឹងទេ ដោយខ្ញុំដឹងថាឪពុកខ្ញុំស្លាប់នៅទីនោះខ្ញុំត្រូវតែដាក់ពាក្យបណ្តឹង ។

[១១:៤៨:១៦]

**សះ** សូមអរគុណដែលលោកស្រីបានឆ្លើយ ។ តទៅទៀត តើត្រឹមត្រូវទេក្រោយពីទៅមើលទួលស្លែងហើយនៅពេលមួយនោះ គឺថាពេលយប់ លោកស្រីបានយល់សប្តិឃើញឪពុករបស់លោកស្រី តើលោកអាចរៀបរាប់អំពីការយល់សប្តិហ្នឹងបានដែរឬទេ?

**ឆះ** ចាស, ពេលខ្ញុំទៅទួលស្លែង ពេលខ្ញុំត្រឡប់មកវិញដោយអារម្មណ៍រន្ធត់និងការឈឺចាប់ ខ្ញុំដេកពេលយប់ទៅខ្ញុំមានអារម្មណ៍ដូចជាយល់សប្តិបន្តិច ដូចជាស្រមៃបន្តិចឃើញ ខ្ញុំមិនដែលស្គាល់មុខឪពុកខ្ញុំទេ ខ្ញុំស្គាល់តែតាមរយៈរូបថត ប៉ុន្តែពេលដែលខ្ញុំទៅអ៊ីចឹងខ្ញុំស្រមៃឃើញផង ដូចយល់សប្តិផងឃើញគាត់ដឹកដៃខ្ញុំរត់ រត់កាត់បន្លាលួសហ្នឹង រត់នៅលើដំបូលអគារដែលជាមន្ទីរឃុំឃាំងនោះ ។ ពេលខ្ញុំភ្ញាក់ដឹងខ្លួន បានខ្ញុំដឹងថានេះជាការយល់សប្តិរបស់ខ្ញុំទេ ។

**សះ** តើត្រឹមត្រូវទេលោកស្រីដែលថា រូបភាពដែលបានបញ្ចាំងនោះ គឺថាជារូបភាព រូបថតតែមួយគត់ដែលម្តាយ ហើយនិងលោកស្រីមានរូបថតឪពុកហ្នឹងតែមួយហ្នឹងអត់មានផ្សេងទៀតទេ តើពិតទេ?

**ឆះ** ចាស, ពិត ។

**សះ** តើត្រឹមត្រូវដែរទេលោកស្រី បើសិនជារឿងក្តីនេះដែលថាខ្មែរក្រហមបានបង្គាប់ឱ្យម្តាយរបស់លោកស្រីហ្នឹង ដុតរូបថតចោលទាំងអស់ តើអ៊ីចឹងមែនឬទេ?

**ឆះ** ចាស, ពួកខ្មែរក្រហមនៅពេលដែលប្រទេសជិតបានរំដោះ ម្តាយខ្ញុំរត់ពីស្រុកស្ទឹងត្រង់ហ្នឹងទៅកាន់ស្រុកកំណើតពួកទ័ព កងទ័ពរបស់ពួកគេហ្នឹងបានបង្ខំឱ្យម្តាយខ្ញុំដុតរូបថត និងប្រវត្តិរូបដែលជា

ឯកសារអីទាំងអស់ទាក់ទងនឹងឪពុកខ្ញុំបើគាត់មិនដុតចោលទេ គេនឹងបាញ់គាត់-- គេមិនប្រាប់ថា បាញ់ទេ ប៉ុន្តែគេប្រាប់យើងដោយចុងកាំភ្លើង ។

**ស៖** លោកស្រីនេះជាសំណួរចុងក្រោយរបស់ខ្ញុំ តើលោកស្រីអាចបញ្ជាក់ប្រាប់តុលាការបានទេ? ហើយថាតើលោកស្រីប្រគល់សិទ្ធិឲ្យធ្វើការទាមទារទៅមេធាវី ឬក៏លោកស្រីចង់ធ្វើខ្លួនឯង?

**ឆ៖** ចាស, នាងខ្ញុំប្រគល់សិទ្ធិនេះទៅឲ្យមេធាវីជាអ្នកដោះស្រាយ ។

**លោក អាឡាំង វ៉ែនណឺ៖**

លោក លោកស្រីចៅក្រម យើងមិនមានសំណួរអ្វីតទៀតចំពោះកូនក្តីរបស់ខ្ញុំទេ ។ ដូចដែលខ្ញុំបញ្ជាក់ខាងដើម គឺកូនក្តីរបស់ខ្ញុំនឹងសុំការអនុញ្ញាតពីតុលាការ ដើម្បីសួរសំណួរបីទៅជនជាប់ចោទនៅពេលបន្តិចទៀតនេះ ។ សូមអរគុណ ។

[១១:៥១:៥៧]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា តើមានសំណួរអ្វីត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ?

**លោក សេង ប៊ុនឃាង៖**

តំណាងអយ្យការមិនមានសំណួរអ្វីសួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តីតើមានសំណួរអ្វីត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ?

បើមានសូមអញ្ជើញ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

យើងខ្ញុំមិនមានសំណួរអ្វីទេ ទៅដើមបណ្តឹងរដ្ឋប្បវេណី លោកប្រធានសូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោកស្រី ហាវ សោភា លោកស្រីនៅតែមានបំណងតាំងសំណួរចំនួនបីសំណួរតាមរយៈយើងដែលជាប្រធានអង្គជំនុំជម្រះសាលាដំបូងចំពោះជនជាប់ចោទដែរទេ?

**លោកស្រី ហាវ សោភា៖**

ចាស, នាងខ្ញុំនៅតែចង់តាំងសំណួរ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីតាំងសំណួរមួយម្តងដើម្បីជាការងាយក្នុងការឆ្លើយ ឆ្លើយរួចសឹមសួរបន្តទៀត ។ សូមអញ្ជើញ ។

**លោកស្រី ហារ សោភា៖**

សំណួរទីមួយដែលនាងខ្ញុំចង់សួរចង់សួរថា អ្នកណាជាមេក្លោងដែលចាប់បញ្ជូនឪពុកខ្ញុំទៅកាន់មន្ទីរស-២១ ព្រមទាំងមិត្តភក្តិរបស់គាត់?

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទ តើលោកអាចឆ្លើយនឹងសំណួរនេះបានទេ យើងសូមបញ្ជូនសំណួរនេះដើម្បីទៅលោកដើម្បីឱ្យលោកឆ្លើយ ។ សូមអញ្ជើញ ។

[១១:៥៣:៥៨]

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! បឹងត្របែកវាស្ថិតនៅក្រោមការគ្រប់គ្រងគណៈកម្មាធិការស-៧១ ។ ស-៧១ នេះក៏ស្ថិតនៅក្រោមអចិន្ត្រៃយ៍មជ្ឈិមដែរ ដូច្នេះការសម្រេចបញ្ជូនលោក ចិន សៀ អតីតកម្មា-ភិបាលមកពីហាណូយ និងជាអតីតកម្មាភិបាលនៅសាលា គ-៩២ ទៅស-២១ គឺអចិន្ត្រៃយ៍អ្នកសម្រេចមិនមែនស-២១ ទៅសុំយកមកទេ ។ នេះសូមគោរពរាយការណ៍ជូនប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

លោកស្រីសូមលោកស្រីតាំងសំណួរទីពីររបស់លោកស្រី ចំពោះជនជាប់ចោទតាមរយៈយើង ។ សូមអញ្ជើញ ។

[១១:៥៥:០០]

**លោកស្រី ហារ សោភា៖**

ចាស, សំណួរទីពីរ ចង់សួរថា តើជីវិតចុងក្រោយរបស់ឪពុកខ្ញុំ គាត់បញ្ចប់នៅបរិវេណទួលស្លែង ឬនៅបឹងជើងឯក?

**ប្រធានអង្គជំនុំ៖**

យើងបញ្ជូនសំណួរនេះទៅជនជាប់ចោទ ដើម្បីឆ្លើយតបនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! លោក ចិន សៀ ពិតជាត្រូវសម្លាប់ ។ ខ្ញុំមិនដឹងច្បាស់ថា តើគាត់ត្រូវសម្លាប់នៅបឹងជើងឯក ឬនៅស-២១ នៅភ្នំពេញទេ ។ សូមគោរព ។

**ប្រធានអង្គជំនុំ៖**

លោកស្រី សូមអញ្ជើញតាំងសំណួរទីបីរបស់លោកស្រី ។

**លោកស្រី ហាវ សោភា៖**

ចាស, សំណួរទីបី ជនជាប់ចោទធ្លាប់និយាយថា គាត់នឹងទទួលខុសត្រូវចំពោះមុខច្បាប់ និងទទួលខុសត្រូវទាំងផ្នែកផ្លូវចិត្តនិងផ្លូវច្បាប់ ។ ប៉ុន្តែ នាងខ្ញុំចង់សួរគាត់ថា តើការទទួលខុសត្រូវរបស់គាត់ផ្នែកផ្លូវចិត្តនោះ តើគាត់ធ្វើអ្វីខ្លះ ដើម្បីឲ្យផ្លូវចិត្តជនរងគ្រោះបានរសាយពីការឈឺចាប់?

**ប្រធានអង្គជំនុំ៖**

តើជនជាប់ចោទអាចឆ្លើយនឹងសំណួរនេះបានដែរឬទេ?

សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ការទទួលខុសត្រូវខាងផ្លូវចិត្តដែលយើងខ្ញុំធ្វើទៅបានយ៉ាងម៉េចធ្វើទាំងអស់ ។ ទីមួយ គឺមិនក្បត់នឹងវិញ្ញាណក្ខន្ធអ្នកដែលស្លាប់ទេ ។ អ្នកណាដែលស្លាប់ទៅនៅស-២១ ទទួលទាំងអស់ថា គេពិតជាស្លាប់នៅទីនោះមែន ។ គេស្លាប់ដោយទារុណកម្មមុននឹងទៅស្លាប់ ក៏យើងខ្ញុំទទួល ហើយទទួលរាយការណ៍ជូនជាតិប្រជាជនកម្ពុជាទាំងអស់ ថារឿងនេះវាសាហាវ គឺទទួលបែបនេះ ។ ហើយថ្មីៗនេះ អង្គសវនាការឃើញហើយ ដើមបណ្តឹងរដ្ឋប្បវេណីតាំងពីអ្នកស្រី ប៊ូ ថុន រហូតមកដល់ពេលនេះ ខ្ញុំទទួលឲ្យគេបន្ទោស ឲ្យគេថ្កោលទោស ហើយទទួលស្គាល់នូវទុក្ខវេទនារបស់គេទុកជាព្រឹត្តការណ៍ប្រវត្តិសាស្ត្រ ។ ទាំងអស់នេះហើយ ដែលយើងខ្ញុំយល់ថា ជាការទទួលខុសត្រូវខាងផ្លូវចិត្តដែលត្រូវតែធ្វើជាដំបូង ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះផ្តល់ឱកាសដល់ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់លើខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហាវ សោភា ដែលបានធ្វើអម្បាញ់មិញនេះ ។ សូមអញ្ជើញ ។

[១១:៥៨:៥១]

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ជនរងគ្រោះឈ្មោះ ចិន សៀ អតីតកម្មាភិបាលមកពីហាណូយ ហើយជាអតីតកម្មាភិបាលដែលជួយការងារនៅសាលាគ-៩២ ក្រោយមកមកជាប់នៅបឹងត្របែក ហើយត្រូវគេចាប់បញ្ជូនមក ស-២១ យើងខ្ញុំទទួលស្គាល់ ។ ឯកសារ ស-២១ នៅទីនេះ ជាភស្តុតាងស្រាប់ យើងខ្ញុំអត់ប្រកែកទេ ។ គ្រាន់តែសូមបញ្ជាក់បន្តិចថា ប្រវត្តិសាលាគ-៩២ នេះ ខ្ញុំដឹង ជាសាលាដែលលោកគ្រូ សុន សេន មេខ្ញុំគាត់ធ្វើ កាលគាត់នៅជាសហប្រធានភូមិភាគឧត្តរ ។

ដូច្នេះ ព្រឹត្តការណ៍ប្រវត្តិសាស្ត្រ ដែលខ្ញុំសូមបញ្ជាក់បន្ថែមប៉ុណ្ណឹង ដើម្បីបញ្ជាក់ថា វិញ្ញាណក្ខន្ធលោក ចិន សៀ ហៅ ហាន ពិតជាទៅស្លាប់នៅមន្ទីរស-២១ មែន ។ នេះគឺបញ្ជាក់ ហើយទទួលស្គាល់ និងទទួលខុសត្រូវចំពោះមុខច្បាប់ និងខាងផ្លូវចិត្តក្នុងមរណភាពរបស់លោក ចិន សៀ ។

ដោយឡែក តើកញ្ញា ហាវ សោភា ពិតជាកូនរបស់លោក ចិន សៀ ហៅ ហាន មែន ឬមិនមែន? ខ្ញុំទុកជូនអង្គជំនុំជម្រះលោកវិនិច្ឆ័យដោយគោរពប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះនីតិវិធីនៃការស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហាវ សោភា ឃើញថាដល់ទីបញ្ចប់ហើយ ហើយស្របគ្នានឹងពេលវេលាក៏ដល់ត្រូវសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ផង ។

ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ។ លោកស្រី ហាវ សោភា អង្គជំនុំជម្រះស្តាប់សេចក្តីការណ៍របស់លោកស្រីបានចប់សព្វគ្រប់ហើយ ។ ហើយចាប់ពីរសៀលនេះទៅ លោកស្រីអាចនៅស្តាប់ដំណើរការសវនាការក៏បាន ឬក៏លោកអាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោកស្រីក៏បាន ឬក៏ទីណាដែលលោកស្រីចង់ទៅក៏បាន នេះជាសិទ្ធិរបស់លោកស្រី ។ ហើយអនុរក្សមន្ទីរឃុំឃាំងឲ្យជនជាប់ចោទទៅកាន់បន្ទប់រងចាំ ហើយឲ្យនាំជនជាប់ចោទមកកាន់សាលសវនាការវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១២:០២នាទី ដល់ម៉ោង១៣:៣៥នាទី ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សេចក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណី ។ សូមអញ្ជើញ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ។

**លោកស្រី ស៊ីលឃី ស្នូតហ្សីនស្តី៖**

សូមអរគុណលោកប្រធាន ។ ដោយហេតុថាសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមកដល់ពេលនេះនោះ នៅពេលដែលយើងរំពឹងថានឹងស្តាប់សក្ខីកម្មហ្នឹង ខ្ញុំសូមជូនដំណឹងដល់អង្គជំនុំជម្រះថា ដើមបណ្តឹងរដ្ឋប្បវេណីរបស់យើងខ្ញុំ គាត់មានស្ថានភាពថា ពេលណា ហើយក្នុងករណីណាដែលគាត់ផ្តល់សក្ខីកម្ម ថ្ងៃស្អែកព្រឹក លោក ស៊ាង វ៉ាន់ឌី អាច ហើយនិងមានលទ្ធភាពមកផ្តល់សក្ខីកម្មបាន ។ នេះជាកាលវិភាគចុងក្រោយនៅលេខ១៨ D25/13 ។ កញ្ញា ឈិន ណារី ខណៈពេលនេះ គាត់នៅមានជំងឺ ហើយអាចនឹងចំណាយពេលថ្ងៃនេះ ថ្ងៃស្អែកទៀត ដើម្បីយើងពិនិត្យលើស្ថានភាពរបស់គាត់ ហើយយើងរំពឹងថា គាត់អាចមានលទ្ធភាពនឹងផ្តល់សក្ខីកម្មនៅថ្ងៃព្រហស្បតិ៍អាទិត្យនេះ ។ ប៉ុន្តែ តាមពិតគឺវាអាស្រ័យទៅលើស្ថានភាពសុខភាពរបស់គាត់ ។ ពេលឥឡូវនេះគាត់សុខភាពមិនល្អ ព្រឹកនេះនៅក្នុងតុលាការព្រឹកមិញនេះ ប៉ុន្តែ គាត់មិនស្រួលខ្លួននៅក្នុងពេលបាយថ្ងៃត្រង់នេះ គាត់មានអាការវិលមុខ ហើយគាត់មិនអាចចូលរួមវគ្គសវនាការល្ងាចនេះបានទេ ។

ចំពោះកញ្ញា អ៊ឹម ស៊ុន្ធី ហើយនិង ភឹង ហ្គុតស៊ុនថារី ខ្ញុំមិនទាន់បានដឹងអំពីសេចក្តីសម្រេចចុងក្រោយថា គាត់បានរៀបចំសេចក្តីថ្លែងការណ៍ខ្លួនគាត់ ដែលថាអាចនឹងគាត់ធ្វើបាននៅថ្ងៃទី២៤ សីហា ដែរឬអត់ទេនោះ បើសិនជាមិនបានមុននោះទេ ខ្ញុំនឹងជូនដំណឹង ។

លោក ជុំ ស៊ីរ៉ាត់ មិននៅក្នុងភ្នំពេញទេ មុនថ្ងៃច័ន្ទ ប៉ុន្តែអាច-- បើអាចបានថ្ងៃច័ន្ទ អង្គារ៍ អាទិត្យក្រោយ ។ ប៉ុន្តែ យើងនឹងចាប់ផ្តើមស្តាប់សក្ខីកម្មរបស់គាត់នៅពេលព្រឹក ប៉ុន្តែដល់ពេលនេះដើមបណ្តឹងរដ្ឋប្បវេណីរបស់យើងដែលមានវត្តមាន ហើយនិងភាពអាចចូលរួមបាននោះ ខ្ញុំសូមបន្ថែមសេចក្តីពន្យល់ចំពោះកូនក្តីរបស់យើងខ្ញុំថា នេះគឺជាខណៈពេលដែលគួរចាប់អារម្មណ៍សម្រាប់ពួកគាត់ ដើម្បីផ្តល់សក្ខីភាពចំពោះតុលាការនេះ ។ ហើយតាមពិត វាក៏ជាមានការលំបាកសម្រាប់ពួកគាត់ដែរ ក្នុងការរៀបចំសេចក្តីថ្លែងការណ៍ ហើយនៅពេលដែលគាត់រំឭកអតីតកាលរបស់គាត់វិញ ដែលគាត់មិនអាចនឹងធ្វើការបាន រៀបចំឲ្យបានក្បោះក្បាយនៅក្នុងសេចក្តីថ្លែងការណ៍ ដែលគាត់ចង់ថ្លែងនោះដែរ ដើម្បីឲ្យត្រូវទៅតាមអ្វីដែលគាត់ចង់បាននោះ ជាពិសេសតម្រូវទៅតាមកាលវិភាគរបស់តុលាការផងដែរ ។

[១៣:៣៩:៤៤]

អ៊ីចឹងហើយ គេត្រូវចំណាយពេលរៀបចំសេចក្ដីថ្លែងការណ៍របស់គេ គាត់មិនអាចបន្តឲ្យតាមពេលដែលគេចង់នោះទេ ដោយថាមានពេលកំណត់ ។ ហើយផលវិបាកនៃការឈឺចាប់ ហើយនិងទុក្ខសោករបស់គេហ្នឹង ក៏ជាកត្តាមួយធ្វើឲ្យលទ្ធភាពរបស់គេហ្នឹង អាចនឹងបន្តតាមការវិភាគធម្មតាបាននោះដែរ កាលណាគេនឹកឃើញរឿងទុក្ខសោកនៅក្នុងអតីតកាលរបស់គេនោះ ។

អ៊ីចឹង កាលវិភាគចុងក្រោយមួយដែលនៅពេលដែលយើងសង្ឃឹមថា នឹងស្ដាប់សក្ខីភាពនោះ គឺសាក្សីមួយនៅអាទិត្យក្រោយនោះ គឺដែលយើងបានរៀបចំ ។ ដូច្នេះ ហើយព័ត៌មាននេះ យើងនឹងជូនដំណឹងទៅពួកគាត់វិញ ដើម្បីរកដំណោះស្រាយមួយផ្សេងទៀត ។ នេះជាអ្វីដែលខ្ញុំអាចជម្រាបជូនអង្គជំនុំជម្រះឲ្យបានជ្រាប ។

ជាបន្តទៅទៀត ខ្ញុំគិតថា បែបនេះធ្វើមិនមានការប៉ះពាល់ទៅដល់កូនក្ដីរបស់ខ្ញុំនៅក្រុមទីពីរទេ ដូចដែលលោក ហុង គីមសួន បានទទួលការវះកាត់ធ្មេញ ដកធ្មេញ ប៉ុន្តែមិនដឹងថ្ងៃណាមួយគាត់បានជាធូរស្រាលមកវិញទេ ប្រហែលជាច្រើនថ្ងៃ ឬក៏ពីរសប្ដាហ៍ឬក៏មិនដឹង ។ ប៉ុន្តែ គាត់បានប្រាប់មកខ្ញុំថាឥឡូវនេះគាត់បានមានជំងឺធ្មេញហ្នឹង អ៊ីចឹង គឺថាអាចថ្ងៃនេះ ឬក៏ថ្ងៃស្អែក គាត់មិនអាចមកធ្វើការបានទេ ហើយក៏មិនអាចស្មានថាពេលណាជាពិតប្រាកដនោះទេ ។ ហើយគាត់អវត្តមាននោះ មានន័យថាក្រុមទីបួន ការជួយដល់ដើមបណ្ដឹងរដ្ឋប្បវេណីនោះ គឺ ហ្វីណែល គាត់នឹងជួលតំណាងឲ្យក្រុមទីបួនតាមរយៈការផ្ដល់សក្ខីភាពតាមវីដេអូ*ខនហ្វើរិន* នៅក្នុងពេលល្ងាចនៅថ្ងៃទី២៤ មកពីបន្តមកពីប៉ារីស ក្រុងប៉ារីសហ្នឹង ។ ហើយក៏ដោយសារកាលវិភាគនេះក៏ ដែលមានន័យថា ដោយសារតែបញ្ហានេះសម្រាប់មេធាវីហើយនិងអ្នកជំនួយការរបស់ក្រុមទីបួននោះ យើងមានមូលហេតុបែបនេះ ។ ខ្ញុំមិនអាច ហើយខ្ញុំមិនអាចប្រមើលមើលឲ្យច្បាស់ថា ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងក្រុមទីបួន អាចនឹងផ្ដល់សក្ខីភាពបាននៅអាទិត្យនេះបានទេ ដោយមិនមានមេធាវីតំណាងរបស់ពួកគេបានទេ ។ ហើយខ្ញុំសូមស្នើសុំនឹងបង្ហាញជូននៅពេលដែលធ្វើសក្ខីភាពត្រូវតែមានមេធាវី ។ អ៊ីចឹងហើយយើងបានទទួលព័ត៌មានពីក្រុមទីពីរ ហើយនិងក្រុមទីបួន ដែលជម្រាបជូនអង្គជំនុំជម្រះសាលាដំបូង លើកមកពិចារណា ។ តាមពិតខ្ញុំ គិតថានៅក្នុងដើម្បីផ្អែកទៅលើស្ថានភាពសុខភាពរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវផ្ដល់សក្ខីកម្មផង ហើយដើម្បីនឹងដោះស្រាយបញ្ហារៀបចំហ្នឹង ដោយសារវាមានលក្ខណៈតានតឹងផ្លូវអារម្មណ៍ដោយស្ថានភាពបច្ចុប្បន្នហ្នឹង គប្បីត្រូវតែពិចារណានិងសម្រេចទៅតាមនោះ ។

ហើយសូមអរគុណ ខ្ញុំរៀបចំនឹងឆ្លើយបំភ្លឺបន្ថែម បើអង្គជំនុំជម្រះត្រូវការ ។

[១៣:៤៣:៥៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ខាតវ៉ាយថ៍ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ សូមអរគុណចំពោះការពន្យល់ដ៏វែងអំពីការបញ្ហាដែលមេធាវីប្រឈមមុខ ជាពិសេសដើមបណ្ដឹងរដ្ឋប្បវេណីនៅក្រុមទីពីរ ។ ហើយតាមពិតនោះ ខ្ញុំមានការព្រួយបារម្ភដោយថាមានការលំបាកដូចនេះ ប៉ុន្តែ ខ្ញុំមិនប្រាកដថាតើលោកស្រីមេធាវីស្នើឲ្យមានដំណោះស្រាយយ៉ាងម៉េចលើបញ្ហាហ្នឹង? តើអាចបញ្ជាក់ឲ្យខ្លីអំពីដំណោះស្រាយដែលត្រូវអនុវត្តទៅមុខចំពោះបញ្ហាមួយចំនួនដែលកំពុងតែប្រឈមនឹងបានទេ កញ្ញាមេធាវី ស្ទួតហ្វ៊ីនស្តិ?

**លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្តិ៖**

ដូចដែលខ្ញុំជម្រាបហើយ គឺថាស្អែក ស៊ាង វ៉ាន់ឌី យើងបានរៀបចំដើម្បីផ្ដល់សក្ខីភាពនៅតុលាការនៅម៉ោងប្រាំបួន គឺមិនមានអ្វីទៀតទេនៅក្នុងកាលវិភាគ ។ ខ្ញុំមិនដឹងច្បាស់ថា ដើមបណ្ដឹងរដ្ឋប្បវេណីថ្ងៃនេះ អាចនឹងបញ្ចប់ថ្ងៃនេះ ឬក៏អត់ទេ ។ បន្ទាប់មកដល់វេន ស៊ាង វ៉ាន់ឌី ដូចដែលយើងបានរៀបចំដែលអាចមានបញ្ហាតូចមួយដែលយើងបានដាក់ជូនកាលពីម្សិលមិញ នូវឯកសារគាំទ្រនៅក្នុងពេលអាហារថ្ងៃត្រង់ ប៉ុន្តែយើងមិនទាន់បានពិនិត្យឡើងវិញ ។ ហើយគេអាចពន្យល់ ហើយការបកប្រែនូវចម្លើយសារភាព ប៉ុន្តែជារឿងផ្ទៃក្នុង គឺថាអាចនឹងរួចរាល់ថ្ងៃស្អែក យើងនឹងជម្រាបជូនអង្គជំនុំជម្រះពីលទ្ធផល។ ប៉ុន្តែ ខ្ញុំគិតថាពេលផ្សេងទៀតដែលអាចនឹងប្រើសម្រាប់ការតវ៉ាដោយមេធាវីការពារ ឬក៏ព័ត៌មានបន្ថែមដែលជម្រាបជូនអង្គជំនុំជម្រះថា កូនក្ដីរបស់ខ្ញុំ ណាំ ម៉ុន នឹងប្រើពេលវេលាដែលនៅសេសសល់ចំពោះបញ្ហាផ្សេងទៀត ។ ហើយគប្បីតែគ្របដណ្ដប់ និង/ឬ ការពិភាក្សាដែលបានលើកឡើងចំពោះមុខអង្គជំនុំជម្រះ ។ ខ្ញុំគិតថា យើងទទួលសេចក្ដីថ្លែងការណ៍ ឬក៏ចម្លើយរបស់សាក្សីដែលត្រូវដាក់មកដេញដោលចំពោះមុខអង្គជំនុំជម្រះនៅក្នុងសប្ដាហ៍នេះ ។

ខ្ញុំមិនមានដំណោះស្រាយ ឬក៏សំណើអ្វីជាក់លាក់នឹងដាក់បន្ថែមទេ ។ ខ្ញុំសូមគិតថា ឈិន ណារីដូចដែលខ្ញុំបានជម្រាបនោះ ខណៈពេលនេះ គឺសុខភាពគាត់មិនល្អទេ ប៉ុន្តែ យើងបានត្រៀមសម្រាប់ព្រឹកថ្ងៃព្រហស្បតិ៍ ។ ប៉ុន្តែ បើមិនបានទេ យើងនឹងសង្ឃឹមថា ថ្ងៃណាមួយនៅអាទិត្យក្រោយ ។ ប៉ុន្តែ យើង

ព្យាយាមស្តាប់សក្ខីកម្មការបំភ្លឺរបស់គាត់នៅអាទិត្យនេះ ។

[១៣:៤៧:៣២]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អ៊ីចឹង និយាយដោយសង្ខេប គឺចង់ ស៊ាង វ៉ាន់ឌី D25 ហ្នឹងសម្រាប់ថ្ងៃស្អែក ហើយប្រសិនបើអាចនោះ ឈិន ណាវី នៅថ្ងៃព្រហស្បតិ៍ពេលព្រឹក ។ អ៊ីចឹងហើយប្រើពេលដែលនៅសល់សម្រាប់ប្រធានបទដែលមិនច្បាស់ តើមានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីណាទេ ដែលអាចបញ្ជាក់ឲ្យច្បាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីណា ដែលប្រើសម្រាប់ពេលនោះ?

**លោក អាឡាំង វ៉ែនណឺ៖**

សូមគោរពលោកចៅក្រម! ក្រុមទីមួយ យើងមានតែដើមបណ្តឹងរដ្ឋប្បវេណីបួន ដែលយើងរំពឹងថា នឹងអ្នកទីបីត្រូវបង្ហាញខ្លួនថ្ងៃនេះ ហើយចុងក្រោយនោះ គឺE2/86 ហើយគាត់ជាជនជាតិអាមេរិកាំង។ ហើយយើងបានរៀបចំការធ្វើដំណើររបស់គាត់ ដោយខាងអង្គភាពសាក្សីនិងអ្នកជំនាញ ដូចដែលយើងយល់ហើយ ដែលថាយើងខ្ញុំមិនទាន់បានជួបគាត់មុនទេ ។ យ៉ាងហោចណាស់ខ្ញុំជួបគាត់មួយថ្ងៃមុន ។ ប្រសិនបើមានការរៀបចំឲ្យគាត់មកបានមុន នោះយើងនឹងអាចមានលទ្ធភាពរួចរាល់ ដើម្បីឲ្យបានរួចរាល់ស្រេច ។ ប៉ុន្តែ នេះជាការលំបាក ដែលយើងប្រឈមនៅពេលនេះ ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវការដែលផ្តល់ព័ត៌មានអំពីបញ្ហានានានៃលទ្ធភាពក្នុងការចូលរួមរបស់ដើមបណ្តឹងរដ្ឋ-ប្បវេណី ដែលត្រូវធ្វើសេចក្តីថ្លែងការណ៍ចំពោះមុខអង្គជំនុំជម្រះដោយមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋ-ប្បវេណី ជាពិសេស គឺមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ហើយនិងបញ្ហាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួននោះ ។ ប៉ុន្តែ ដោយសារគោលបំណងនៃអង្គជំនុំជម្រះឃើញថា ការដែលយើងស្តាប់សេចក្តីថ្លែងការណ៍របស់អ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីពីថ្ងៃម្សិលមិញ ហើយនិងព្រឹកមិញនេះ គឺនាំឲ្យយើងមានមូលដ្ឋានសមល្មមដែលអាចគណនាឡើងវិញ អំពីពេលវេលាដែលត្រូវធ្វើសេចក្តីថ្លែងការណ៍របស់អ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសេសសល់ ។ ហើយនៅក្នុងនោះទៀត គឺមានអ្នកដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលបានបង្ហាញដោយមេធាវីតំណាងរបស់ខ្លួន គឺលះបង់ថា មិនមកធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះទេ ។ ហេតុទាំងអស់នេះ គឺនាំឲ្យកាលវិភាគដែលអង្គជំនុំជម្រះបានដាក់ចេញតាមសំណើសុំ និងបែបផែននៃការគណនារបស់ភាគីតំណាងឲ្យ

ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ ឃើញថាមិនត្រឹមត្រូវទេ ។ ឃើញថា ការដែលយើងធ្វើសវនាការនេះ បានលឿនហួសពីអ្វីដែលមេធាវីទាំងអស់បានគណនាពេលវេលា ហើយបានគ្រោងទុកបញ្ជូនមកឲ្យអង្គជំនុំជម្រះ ។ ហេតុផលនេះទេ ដែលអង្គជំនុំជម្រះធ្វើការសម្របសម្រួលមួយ ដើម្បីប្រឹងប្រែងឲ្យអស់លទ្ធភាពនៅក្នុងការពន្លឿននូវកិច្ចប្រឹងប្រែងរបស់យើង ដើម្បីឲ្យដំណើរការសវនាការហ្នឹងបានប្រកបដោយភាពឆាប់រហ័ស ។ ម៉្យាងទៀត ដោយសារហេតុផលនៃពេលវេលានេះកន្លងមក គឺកាលពីព្រឹកមិញ ព្រឹកម្សិលមិញ គឺអង្គជំនុំជម្រះបានធ្វើការប្រកាសនូវសេចក្តីសម្រេចរបស់ខ្លួនមួយថា ការពិភាក្សាដេញដោលចំពោះពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដែលនឹងមានការជំទាស់ពីមេធាវីការពារក្តី ។ អ៊ីចឹង យើងមិនទាន់មានពេលវេលាណាមួយច្បាស់លាស់ សម្រាប់ធ្វើកាលវិភាគសម្រាប់ដំណើរការសវនាការនោះទេ ។

ការប៉ុនប៉ងរបស់អង្គជំនុំជម្រះគឺថា ប្រសិនបើល្បឿននៃដំណើរការស្តាប់សេចក្តីថ្លែងការណ៍របស់អ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរៀបចំទុកនេះលឿន ដែលជាងកាលវេលាដែលបានកំណត់នោះអង្គជំនុំជម្រះនឹងមានផែនការថា នឹងជម្រាបជូនដល់ភាគីនៅថ្ងៃស្អែក ឬក៏ថ្ងៃខានស្អែក ដើម្បីបញ្ជាក់អំពីកំណត់មានការប្រែប្រួលនៅក្នុងកាលវិភាគ ដើម្បីពិភាក្សាដេញដោលចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលមានការជំទាស់ពីមេធាវីការពារក្តី ក្នុងបំណងមិនឲ្យមានឱកាសទំនេរឥតប្រយោជន៍នៅក្នុងពេលវេលាធ្វើការងារ សម្រាប់គម្រោងផែនការសវនាការទេ ។

ហើយអង្គជំនុំជម្រះសង្ឃឹមជឿជាក់លើមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងយល់អំពីបញ្ហានេះ ហើយនិងសម្របសម្រួលជាមួយនឹងកូនក្តីរបស់ខ្លួន ដើម្បីមានឱកាសនៅក្នុងការចូលរួមដើម្បីធ្វើសេចក្តីថ្លែងការណ៍នេះ ។

[១៣:៥៣:១២]

អង្គជំនុំជម្រះសង្ឃឹមថា នេះជាឱកាសនៃការទន្ទឹងរង់ចាំរបស់អ្នកដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ ដើម្បីមកថ្លែងការណ៍អំពីទុក្ខសោករបស់គាត់ ដែលគាត់នៅក្នុងទ្រូង នៅក្នុងចិត្តរបស់គាត់ហ្នឹងច្រើនឆ្នាំច្រើនទសវត្សរ៍មកហើយនោះ។ អង្គជំនុំជម្រះនៅតែសង្ឃឹមថា មេធាវីអាចប្រឹងប្រែង ហើយនិងសម្របសម្រួលដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ ដើម្បីគាត់មានលទ្ធភាពអាចមកថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះតាមកាលវិភាគ ដែលនឹងមានការប្រែប្រួលដោយហេតុផលដូចយើងបានបង្ហាញជូនអម្បាញ់មិញនេះ ។

ជាកិច្ចបន្ត គឺអង្គជំនុំជម្រះទុកបញ្ហានេះមួយអន្លើ ហើយសង្ឃឹមថានៅក្នុងអំឡុងពេលសម្រាករសៀលនេះ ឬក៏ថ្ងៃស្អែក អង្គជំនុំជម្រះនឹងទទួលបានព័ត៌មានអំពីការប្រែប្រួល និងការចូលរួមពីមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្របសម្រួលដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន ដើម្បីមកធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះតាមកាលវិភាគដែលមានការប្រែប្រួលចុងក្រោយនេះ ។

ជាកិច្ចបន្ត គឺដល់កាលវិភាគដែលត្រូវស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី សូ សូង ។ មន្ត្រីតុលាការ សូមអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី សូ សូង មកកាន់តុដែលរៀបចំសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះ ។

*(ដើមបណ្តឹងរដ្ឋប្បវេណីមកកាន់បន្ទប់សវនាការ)*

**តាំងសំណួរដោយចៅក្រម៖**

**ប្រធានអង្គជំនុំ៖**

**ស៖** ដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះ សូ សូង ឬក៏ឈ្មោះ សូ សួង? តើលោកស្រីមានឈ្មោះអ្វី?

**លោកស្រី សូ សូង៖**

**ឆ៖** ចាស, ខ្ញុំឈ្មោះ សូ សូង ។

**ស៖** លោកស្រីមានអាយុប៉ុន្មានហើយ?

**ឆ៖** ខ្ញុំអាយុ៥៥ឆ្នាំហើយ ។

**ស៖** លោកស្រីមានសញ្ជាតិអ្វីដែរ?

**ឆ៖** ចាស, ខ្ញុំសញ្ជាតិខ្មែរ ។

[១៣:៥៦:៤៥]

**ស៖** លោកស្រីមានទីកន្លែងកំណើតនៅទីកន្លែងណាដែរ?

**ឆ៖** ចាស, ខ្ញុំនៅកំណើតនៅភូមិចាំងចើក ឃុំចក្រីទីង ស្រុកកំពត ខេត្តកំពត ។

**ស៖** សព្វថ្ងៃនេះតើលោកស្រីមានទីលំនៅ នៅទីកន្លែងណា?

**ឆ៖** ចាស, ខ្ញុំសព្វថ្ងៃនេះ ខ្ញុំនៅភូមិ២ សង្កាត់១ ខណ្ឌមិត្តភាព ខេត្តព្រះសីហនុ ។

**ស៖** លោកស្រីប្រកបមុខរបរអ្វីដែរ?

**ឆ៖** ចាស, ខ្ញុំមុខរបរខ្ញុំ គឺធ្វើ-- គ្រួសារខ្ញុំធ្វើសំណង់ ។ ខ្ញុំនៅផ្ទះ ។

**ស៖** ឪពុកបង្កើតរបស់លោកស្រីឈ្មោះអ្វី? ហើយសព្វថ្ងៃហ្នឹងគាត់នៅរស់ ឬគាត់ទទួលមរណ-ភាពហើយ?

**ឆ៖** ចាស, ឪពុកខ្ញុំ ឪពុកម្ដាយរបស់ខ្ញុំស្លាប់អស់ហើយ ។

**ស៖** លោកស្រីមានបងប្អូនបង្កើតប៉ុន្មាននាក់? ហើយបងប្អូនបង្កើតរបស់លោកស្រីហ្នឹង មានឈ្មោះអ្វីខ្លះ? ចូររៀបរាប់ ។

**ឆ៖** ចាស, បងប្អូនខ្ញុំមានពីរនាក់ ។ បងស្រីខ្ញុំហើយនិងខ្ញុំ ។ ហើយបងស្រីនិងខ្ញុំរស់នៅជាមួយគ្នា និយាយតាំងពីខ្ញុំបានអាយុ៧ឆ្នាំមក ឪពុកម្ដាយរបស់ខ្ញុំគាត់បានលែងលះគ្នាអ៊ីចឹងទៅ គាត់ក៏ឪពុកខ្ញុំក៏ឲ្យខ្ញុំមកនៅជាមួយអ៊ំ ។ ហើយលុះត្រាដល់រស់នៅជាមួយគាត់ លុះត្រាដល់បងស្រីខ្ញុំហើយនិងបងថ្លៃខ្ញុំនិងគាត់បានគ្នាជាប្ដីប្រពន្ធមក ខ្ញុំតាំងពីឆ្នាំ៦៧ ។ អ៊ីចឹងខ្ញុំរស់នៅជាមួយគាត់រហូត ជាប់រហូតលុះដល់តែឆ្នាំ៧០ មានទាហានលន់នល់ និងទាហានខ្មែរក្រហមហ្នឹង ជាមួយហ្នឹងគាត់-- ទាហានទាំងពីរហ្នឹងបាញ់គ្នាខ្លាំងពេក ។ អ៊ីចឹងបងថ្លៃខ្ញុំ គាត់ឲ្យខ្ញុំទៅនៅជាមួយម្ដាយខ្ញុំ នៅឯជីវំដោះ ។

**ស៖** បានហើយ ហើយបងស្រីរបស់លោកស្រីហ្នឹង គាត់មានឈ្មោះអ្វីដែរ?

**ឆ៖** បងស្រីខ្ញុំហ្នឹងឈ្មោះ ឯម ស៊ួន ។

**ស៖** អម្បាញ់មិញនេះ លោកស្រីបាននិយាយថា បងស្រីរបស់លោកស្រីហ្នឹងមានប្ដី តើប្ដីរបស់គាត់ របស់បងស្រីរបស់លោកស្រីហ្នឹងឈ្មោះអ្វី?

**ឆ៖** ចាស, ប្ដីរបស់បងស្រីខ្ញុំឈ្មោះ មាស ស៊ុន ។

[១៤:00:00]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមប្រគល់ឱកាសទៅមេធាវីអ្នកតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ដើម្បីឡើងធ្វើសេចក្ដីថ្លែងការណ៍សង្ខេប អំពីអត្តសញ្ញាណដើមបណ្ដឹងរដ្ឋប្បវេណី អំពីហេតុ អំពីទំនាក់ទំនងនៃការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងបទឧក្រិដ្ឋដែលបានចោទប្រកាន់ចំពោះជនជាប់ចោទ អំពីស្ថានភាពព្យសនកម្មនៃដើមបណ្ដឹងរដ្ឋប្បវេណីនិងភស្តុតាងនានា ដែលមានក្នុងការគាំទ្រនៃការប្ដឹងទាមទារសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ។ សូមអញ្ជើញ ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សូណាព្រូស៖**

សូមអរគុណលោកប្រធាន ។ ជាការពិតណាស់ យើងនៅទីនេះកំពុងតែពិចារណានិងដេញដោល

ទៅលើរឿងក្តីជាក់លាក់មួយ គឺរឿងក្តីសំណុំរឿង E2/34 ទាក់ទងទៅនឹង សូ សូង ដែលគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះការបាត់ខ្លួនបងថ្លៃរបស់គាត់ បានន័យថា បងថ្លៃរបស់គាត់ គឺជាប្តីរបស់បងស្រីរបស់គាត់ដែលបាត់ខ្លួននៅទួលស្លែង ។ ហើយគាត់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ ។ ដោយសារតែបងស្រីរបស់គាត់ពុំអាចមានលទ្ធភាពប្រឈមមុខទៅនឹងស្ថានភាពនេះដោយសារតែជំងឺរបស់គាត់ ។ ហើយលោកស្រី សូ សូង គឺគាត់អាចចេះដឹង ហើយមានចំណេះដឹងឲ្យចូលខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ហើយលោកស្រីបានរស់នៅជាមួយនឹងបងស្រីតាំងពីអាយុ៧ឆ្នាំ ហើយបងស្រីរបស់គាត់ការពារនិងថែទាំគាត់ ។ ហើយគាត់បន្តរស់នៅជាមួយនឹងបងស្រីរបស់គាត់រហូតដល់គាត់រៀបអាពាហ៍ពិពាហ៍។ ហើយបងស្រីរបស់គាត់ ដូចជាម្តាយរបស់គាត់អ៊ីចឹង ហើយបងថ្លៃដូចជាឪពុក។ ដូច្នេះហើយ លោកស្រីគាត់បានរស់នៅជាមួយនឹងបងស្រី ហើយលោកស្រីនឹងពន្យល់អំពីព្រឹត្តិការណ៍ផ្សេងៗក្រោយឆ្នាំ១៩៧៩ ។ ហើយលោកស្រីនៅតែបន្តជួយគាំទ្រទៅដល់បងស្រីរបស់លោកស្រីទៀត ។

ឯកសារដែលយើងមាននៅទីនេះ គឺឯកសារតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយឯកសារទាំងអស់ត្រូវបានទទួលយក ចូលទៅក្នុងសំណុំរឿងតាមសេចក្តីបង្គាប់នៅក្នុងឆ្នាំ២០០៧ ស្តីពីការដាក់ឯកសារ ។ ហើយនៅក្នុងមាត្រា៣នៃសេចក្តីណែនាំអំពីដាក់ឯកសារមាត្រា៣.២ នៅក្នុងចំណុច (ក) គឺវាទាល់តែពាក់ព័ន្ធទៅនឹងព្យសនកម្មផ្លូវចិត្ត ។ ហើយវាពាក់ព័ន្ធទៅនឹងជនរងគ្រោះនៅក្នុងរឿងក្តីនេះ ។ ហើយលោកស្រី សូ សូង គាត់បានបាត់នូវបងថ្លៃរបស់គាត់នៅស-២១ ហើយគាត់ លោកស្រីគាត់បានរកឃើញរូបថត មាស ស៊ុន នៅស-២១ ។ រូបថតនេះ គឺបានដាក់ចូលទៅក្នុងសំណុំរឿងហើយ គឺលេខ ERN 00282315 ។ ហើយចំណុចចុងក្រោយ គឺយើងខ្ញុំបានដាក់នៅពេលថ្មីៗនេះ នូវឯកសារថ្មីមួយដែលឯកសារនេះ មិនទាន់បានជូនដំណឹងទៅដល់ភាគីនៅឡើយទេ ។ ប៉ុន្តែ យើងបានសម្រេចដាក់ជូនឯកសារនេះទៅកាន់មេធាវីការពារក្តីដើម្បីឲ្យយើងគោរពទៅតាមនីតិវិធីតទល់គ្នា ។ ហើយយើងនឹងបញ្ជូនឯកសារនេះ ជូនអង្គជំនុំជម្រះ ។ ឯកសារមួយនេះជាឯកសារថ្មី គឺជាលិខិតរបស់អភិបាលឃុំ គឺមេឃុំដែលគាត់រស់នៅ នៅក្នុងឃុំដែលគាត់រស់នៅ ។ ហើយលិខិតរបស់មេឃុំនេះ គឺបានបញ្ជាក់អំពីចំណងលោហិតរវាងលោកស្រី សូ សុង និងបងស្រីរបស់គាត់ ។ ហើយនិងទំនាក់ទំនងរវាងគាត់ និងបងថ្លៃរបស់គាត់ មាស ស៊ុន ។

[១៤:០៥:00]

ហើយមេឃុំនៅក្នុងឃុំនោះ គាត់បានដាក់ជូននៅសាក្សីមួយចំនួនដែលបញ្ជាក់ថាវាជារូបថតរបស់

មាស ស៊ុន ដែលជាប់នៅស-២១ ហើយមេឃុំក៏បានបោះត្រានៅលើរូបថតនេះដើម្បីបញ្ជាក់ ។ ហើយដូច្នេះហើយ គឺលោកស្រី និងនិយាយអំពីទុក្ខសោកទាំងឡាយ ហើយឯកសារមួយចំនួនលោកស្រីមិនទាន់បានចុះនៅឡើយ ដោយសារតែមិនមានប្រព័ន្ធចុះត្រានូវឯកសារត្រឹមត្រូវ ហើយយើងក៏មិនទាន់មានឯកសារបញ្ជាក់លិខិតអាពាហ៍ពិពាហ៍ពីភូមិឃុំផងដែរ ។ ប៉ុន្តែ យ៉ាងណាក៏ដោយ មេឃុំបានស្គាល់គ្រួសារនេះជាច្រើនឆ្នាំ ដូច្នេះមេភូមិអាចបញ្ជាក់ផ្លូវការទៅលើសក្ខីភាពនេះ ហើយមេភូមិបានបោះត្រាទៅលើឯកសារបញ្ជាក់អំពីភាពត្រឹមត្រូវ ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដោយសារតែលោកប្រធានមិនទាន់បានទទួលនូវសេចក្តីជូនដំណឹងអំពីឯកសារនៅឡើយទេ ។

យើងខ្ញុំសូមដាក់ឯកសារនេះនៅពេលនេះតែម្តង នៅចំពោះមុខអេក្រង់បញ្ជាក់ដើម្បីឲ្យអង្គសវនាការបានជ្រាបទៅលើបញ្ហានេះ ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតធ្វើការដាក់បញ្ចាំងនូវឯកសារថ្មី និងលិខិតបញ្ជាក់ទាំងអស់ជូនអង្គសវនាការនិងភាគីជ្រាប ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារពីមេធាវី ហើយដាក់បញ្ចាំងនៅស្លាយនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ដើម្បីជូនភាគី ជាពិសេសគឺមេធាវីការពារក្តី ដើម្បីពិនិត្យនិងធ្វើការកត់សម្គាល់ ឬក៏ជំទាស់ទៅលើឯកសារដែលស្នើសុំដាក់ដោយមេធាវី តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។

មេធាវីការពារក្តី សូមធ្វើការពិនិត្យនូវឯកសារនេះ ដែលជាឯកសារថ្មីដែលមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី សូ សូង បានស្នើសុំដាក់ ហើយលោកមន្ត្រីតុលាការអាចទៅយកឯកសារមួយដែលជាឯកសាររឹងយកជូនទៅមេធាវីការពារក្តីដើម្បីពិនិត្យ ពីព្រោះការពិនិត្យនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ហាក់ដូចជាមានការលំបាកមិនច្បាស់ ។

សូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ។

[១៤:០៩:៤៦]

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សូណាព្រូស៖**

នេះគឺជាឯកសារដែលខ្ញុំបានផ្តល់កាលពីម្សិលមិញពេលព្រឹក ក្នុងពីរភាសា គឺឯកសារនេះមានរៀបចំជាពីរភាសា ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្តី ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

សូមអរគុណលោកប្រធាន ។

ជាការពិតឯកសារនេះ បានផ្តល់ជូនយើងខ្ញុំកាលពីម្សិលមិញ ដើម្បីគោរពទៅតាមនីតិវិធីនៃការតទល់គ្នា ។ មេធាវីការពារក្តីបានបញ្ជាក់កាលពីម្សិលមិញថា ចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ វាមិនមានទំនាក់ទំនងចំណងលោហិតធ្វើឲ្យយើងភ្ជាប់ទំនាក់ទំនងទៅនឹងជនរងគ្រោះនោះទេ ហើយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺមិនបានបញ្ជាក់ និងបង្ហាញអំពីលិខិតកំណើត ហើយមិនបានដាក់ឯកសារទាំងអស់នោះនៅចំពោះមុខអង្គសវនាការ ។ ហើយអ្វីដែលយើងឃើញនេះ គឺគ្រាន់តែជាលិខិតបញ្ជាក់ពីមេឃុំតែប៉ុណ្ណោះ ។ ហើយចំពោះបង្ហាញអង្គហេតុ វាកើតឡើងតាំងពីសាមសិបឆ្នាំមុន ហើយមេធាវីការពារក្តីមិនមានការសង្កេតជាក់លាក់ដើម្បីគិតនិងពិចារណាអំពីតម្លៃនៃឯកសារមួយនេះ ដែលទើបតែបានបង្កើតនោះទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនសូវយល់អំពីប្រព័ន្ធនៃការចុះឈ្មោះនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងប្រទេសបារាំង គឺមេឃុំជាមន្ត្រីរាជការមួយរូប ។ ដូច្នេះហើយ គឺគាត់ទទួលបន្ទុកចុះនិងចុះបញ្ជីអាត្រានុកូលដ្ឋាន ហើយគាត់នឹងផ្តល់លិខិតអាត្រានុកូលដ្ឋានបញ្ជាក់ជូន ។ ដូច្នេះហើយតើយើងមានឯកសារណាបញ្ជាក់ឲ្យបានត្រឹមត្រូវដែរឬទេ? ហើយយើងជាបញ្ជាក់អំពីអំណាចរបស់មេឃុំបញ្ជាក់ទៅលើឯកសារណាមួយដែរឬទេ? ហើយដូចដែលយើងបានដឹងហើយ គឺនៅក្នុងប្រព័ន្ធបារាំង គឺមេឃុំ ឬក៏អភិបាលស្រុក-ក្រុង គឺជាមន្ត្រីមានអំណាច និងសិទ្ធិក្នុងការចុះបញ្ជីទៅលើឯកសារផ្សេងៗ ។

[១៤:១២:២៧]

**លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស៖**

យើងមិនបានពិចារណាបញ្ហានេះថា វាជាលិខិតសាក្សីសាមញ្ញនោះទេ ។ ប៉ុន្តែ វាជាលិខិតមានលក្ខណៈយតិភាពតាមផ្លូវច្បាប់ ហើយមេឃុំ គឺជាបុគ្គលិករបស់-- គឺជាមន្ត្រីរាជការ ។ ហើយយើងគ្រាន់តែសុំមេឃុំឲ្យបញ្ជាក់ឯកសារនេះជូនយើងខ្ញុំ ហើយគឺមេឃុំគាត់បានបញ្ចូលរួមលិខិតធានា ដែល

ក្នុងលិខិតធានានេះ គឺមានសាក្សីចំនួនបីរូបបានបញ្ជាក់នៅអ្វីដែលមេឃុំ គាត់បានលើកឡើងនិងអ្វីដែលភាគីគាត់បានបញ្ជាក់ជូនទៅដល់មេឃុំ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតំណាងក្រុមដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ក្រោកឈរ តើមានបំណងនិយាយបញ្ហាអ្វី បើមានបំណងនិយាយ អង្គជំនុំជម្រះអនុញ្ញាតឲ្យនិយាយនាពេលនេះដើម្បីអង្គជំនុំជម្រះមានលទ្ធភាពក្នុងការគ្រប់គ្រងសវនាការបន្តទៀត ដើម្បីជជែកដេញដោលពីបញ្ហានេះ ហើយបញ្ចប់បញ្ហានេះទៅតាមកាលវិភាគដែលបានគ្រោងទុក មិនឲ្យបញ្ហានេះនៅតែជាបញ្ហាដូច្នេះទេ ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្ស ណាព្រូស៖**

ជាការពិត ខ្ញុំគិតថាចំណុចនេះ វាសំខាន់ណាស់ទាក់ទងទៅនឹងការបញ្ហានេះ ដោយសារតែយើងជាភាគីនៅក្នុងដំណើរការក្តី ហើយនិងការលំបាកដែលយើងជួបប្រទះនៅពេលនេះ ។ ដើម្បីទទួលនូវឯកសារអាត្រានុកូលដ្ឋាន និងឯកសារចុះឈ្មោះផ្សេងៗសម្រាប់ជនរងគ្រោះនៅស-២១ គឺវាជាការសំខាន់ដែលថា ត្រូវតែមានការធ្វើសេចក្តីសម្រេចនៅក្នុងវិធីមួយសមស្រប ហើយវាជាភាពចាំបាច់ ។

យើងបានសុំការសម្រេចពីមេឃុំដែលមានអំណាចក្នុងការធានាទៅលើឯកសារនេះ ។ ហើយនៅក្នុងប្រទេសបារាំង ក៏ដូចនៅក្នុងប្រទេសកម្ពុជាផងដែរ ។ សហមេធាវីទទួលបានការបញ្ជាក់ថា យើងអាចធ្វើបានដូច្នេះនៅក្នុងប្រទេសកម្ពុជា ហើយនៅក្នុងស្ថានភាពមួយចំនួនគឺអង្គជំនុំជម្រះអាចឲ្យយើងខ្ញុំបានដឹង ថាតើយើងអាចធ្វើទៅតាមរបៀបនេះដែរឬទេ ដែលមានការសុំបញ្ជាក់ដូច្នេះ ។ ដើម្បីឲ្យមានការសុំបញ្ជាក់ជាផ្លូវការទៅលើឯកសារនេះ ដូចដែលខ្ញុំបានធ្វើ ។ ហើយឯកសារនេះ គឺបានបញ្ជាក់អំពីចំណងលោហិតរវាងដើមបណ្តឹងរដ្ឋប្បវេណីនិងជនរងគ្រោះ ។ ហើយពេលខ្លះទៅ ប្រជាជនមួយចំនួនគាត់មិនមានមធ្យោបាយក្នុងការទទួលបានឯកសារទាំងអស់នេះ ដោយសារតែគាត់មានភាពក្រីក្រ ។ ហើយពេលខ្លះទៅ ធ្វើឲ្យគាត់មិនអាចទទួលនៅការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងតុលាការនេះ ដូចដែលយើងបានដឹង ។ ដូច្នេះហើយ ទើបយើងស្នើសុំឲ្យធ្វើការស្តាប់នូវសេចក្តីថ្លែងការណ៍របស់លោកស្រីសូ សុង នៅក្នុងថ្ងៃនេះ តាមលិខិតបញ្ជាក់ត្រឹមត្រូវរបស់យើង ដែលបានស្នើសុំនោះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ការ សាវុត្ថ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណនិងសូមគោរពលោកប្រធាន សូមគោរពអង្គសវនាការទាំងមូល ។ ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ យើងខ្ញុំជាមេធាវីការពារ យើងខ្ញុំមានការពិបាក ពីព្រោះក្នុងឯកសារតែមួយគាត់ឆ្លើយខុសគ្នាទាំងបីដង ថាលោក មាស ស៊ុន ជាសមាជិកស្រុកបាកាន យកមកចាប់ដាក់គុក ។ ឯកសារERN E2/34 និងឯកសារERN00274461 ហើយក្នុងឯកសារដដែលនេះទៀត គាត់ថា មាស ស៊ុន ជាសមាជិកស្រុកពួក បានគេចាប់យកដាក់ស-២១ ។ ខាងលើណោះ គេថាសមាជិកស្រុកបាកានយកមកចាប់ចូលស-២១ ហើយអាស្រុកបាកាន គឺនៅក្នុងខេត្តពោធិ៍សាត់ បើស្រុកពួក នៅក្នុងខេត្តបាត់ដំបង ។ ដូច្នេះឃើញថា ពិបាកណាស់ ពិបាកទទួលស្គាល់ ហើយនៅក្នុងអង្គសវនាការនេះ គាត់បានឆ្លើយថា មាស ស៊ុន នេះនៅក្នុងភូមិត្រពាំងច្រាប ឃុំថ្មី ស្រុកទឹកឈូ ខេត្តកំពត ។

ដូច្នេះឃើញថា វាមានខុសគ្នាហូរហែរអ៊ីចឹងទៅ ជាហេតុនាំឲ្យមេធាវីការពារក្ដីមិនអាចនឹងទទួលយកបាន ដូច្នេះខ្ញុំសូមអរគុណតែប៉ុណ្ណឹងទេ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ យើងដូចជាមិនទាន់ស្ដាប់នូវសេចក្ដីថ្លែងការណ៍របស់អ្នកដើមបណ្ដឹងរដ្ឋប្បវេណីនោះផង ហើយយើងបានធ្វើសន្និដ្ឋានមុនពេលស្ដាប់សេចក្ដីថ្លែងការណ៍របស់គាត់ ។ វាគួរតែត្រូវបានស្ដាប់នូវសេចក្ដីថ្លែងការណ៍របស់គាត់ជាមុន ហើយការបង្ហាញហេតុទាំងឡាយរបស់ភាគី នោះជាការជជែកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះនឹងយកមូលដ្ឋាននៃការបង្ហាញរបស់ភាគី ដើម្បីយកទៅធ្វើការពិចារណា ។

ចំណែកឯភាគី ក្រោយពីបានធ្វើសវនាការស្ដាប់សេចក្ដីថ្លែងការណ៍ និងស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នោះនឹងធ្វើការសេចក្ដីសន្និដ្ឋានសរុបនៅពេលដែលធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ នោះនឹងមានព័ត៌មានសព្វគ្រប់ ។

ឥឡូវនេះ អង្គជំនុំជម្រះសម្រេចស្ដាប់នៅសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកស្រី សូ សូង តើលោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីហេតុ អំពីទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅចំពោះជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅឌុចដែលនាំឲ្យលោកស្រីសម្រេចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងទាមទារសំណងពីជនជាប់ចោទរូប

នេះ និងអំពីស្ថានភាពព្យសនកម្មដែលមានចំពោះលោកស្រីជាអាទិ៍ ការខូចខាតផ្នែកខាងរាងកាយសម្ភារៈ ឬផ្លូវចិត្ត និងផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋជាព្យសនកម្មផ្ទាល់ខ្លួន និងដែលបានកើតពិតប្រាកដរហូតដល់ពេលបច្ចុប្បន្ន ។ ដោយបទឧក្រិដ្ឋដែលបានចោទប្រកាន់ចំពោះជនជាប់ចោទដូចយើងបានប្រាប់លោកស្រីខាងលើ ដែលបានប៉ះពាល់ដល់លោកស្រីនៅក្នុងអំឡុងពេលនៃការបង្កើតនិងប្រតិបត្តិការនៃមន្ទីរសន្តិសុខស-២១ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ បានឬទេ? បើសិនជាអាចថ្លែងការណ៍បានសូមអញ្ជើញ ។

**ឆះ** អង្កាល់ពីឆ្នាំ៧៥ហ្នឹង គាត់ទៅនៅឃុំចក្រីទីង ហើយនាងខ្ញុំក៏ ខ្ញុំនៅស្រែអំបិល ហើយទាល់៧៦ ខ្ញុំបានទៅលេងផ្ទះ ទៅផឹកថ្នាំនៅផ្ទះ អ៊ីចឹងខ្ញុំក៏បានទៅរកនៅជាមួយគាត់ដែរ គាត់នៅឃុំចក្រីទីង គាត់ធ្វើប្រធានឃុំចក្រីទីង ។ ហើយមកដល់-- រួចអ៊ីចឹងដល់ឆ្នាំ៧០ គាត់ក៏គេឲ្យគាត់ផ្លាស់ទៅភូមិភាគឧត្តរទៅខាងខេត្តសៀមរាបទៅនៅស្រុកពួក ។ ហើយខ្ញុំក៏គ្មានរហូតអ៊ីចឹង ដល់ទាល់ឆ្នាំ៧៩ បានត្រលប់មកវិញហ្នឹង៧៩ អ៊ីចឹងបានបងស្រីខ្ញុំ គាត់ប្រាប់ថាប្ដីគាត់ត្រូវគេសម្លាប់ហើយ ហើយឮសួរពេទ្យនៅកន្លែង តាម៉ុក ប្រាប់ថាប្ដីគាត់ស្លាប់ហ្នឹង-- មុននឹងស្លាប់ហ្នឹងជាប់គុកនៅសៀមរាបហ្នឹងដប់ថ្ងៃ ហើយជាប់គុកនៅបាត់ដំបងដប់ថ្ងៃ ហើយមកជាប់គុកនៅទួលស្លែងដប់ថ្ងៃត្រូវស្លាប់ហើយ ។

ហើយតែគាត់ក៏នៅមិនច្បាស់ទៀត ។ ទាល់តែឆ្នាំ៨០ បាន ពូនី មួយគាត់ស្លាប់បាត់ហើយ គាត់មកមើលរូបថត មកមើលក្រុមគ្រួសាររបស់គាត់ហ្នឹង ក៏ឃើញរូបថត បងស៊ុន ហ្នឹង ឃើញហើយគាត់ប្រាប់ថា ហ្ន៎! ខ្ញុំឃើញរូបថត ស៊ុន នៅគុកទួលស្លែង នាំគ្នាទៅមើលទៅ! ដល់អ៊ីចឹងឪពុកម្ដាយខ្ញុំគាត់ថាមិនបាច់ទៅទេ តែទៅហ្នឹងរវៗឆ្កួតអត់អ្នកណាចិញ្ចឹមកូនទេ ។ ហើយខ្ញុំនិយាយទៅតាំងពី៧៩មក ដោយត្រលប់មកទៀតខ្ញុំក៏រស់នៅជាមួយគ្នាពីរបីនាក់បងប្អូន ពីរនាក់បងប្អូនហ្នឹងរកស៊ីចិញ្ចឹមក្មួយចិញ្ចឹមទាំងឪពុកម្ដាយទាំងអស់គ្នាហ្នឹងទៅ ។

រកស៊ីរហូតទាល់ៗឆ្នាំ៨៧ ខ្ញុំក៏បានការមានប្ដីអ៊ីចឹងទៅ ខ្ញុំក៏នៅកំពង់សោមទៅ ។ ហើយខ្ញុំទៅនៅកំពង់សោម ខ្ញុំក៏បានរកស៊ីបានបន្តិចតួចអ៊ីចឹងទៅ ខ្ញុំផ្ដល់មកជូនបងខ្ញុំដើម្បីចិញ្ចឹមកូនគាត់ដែរ ។ ចិញ្ចឹមកូនគាត់រហូត ទាល់រាល់ថ្ងៃខ្ញុំនៅជួយគាត់ ជួយគាត់ដែរ ហើយខ្ញុំក៏ក្រីក្រ គាត់ក៏ក្រីក្រ ។ ហើយនិយាយទៅកូន បងស៊ុន ហ្នឹងតាំងពី៧៩មក មកទាល់ឥឡូវនេះគាត់ ដូចថាភាពក្រីក្ររបស់គាត់ខ្លាំងពេកគាត់អត់មានបានរៀនបានសូត្រ កូនអត់មានបានរៀនសូត្រទេ ។ ហើយបងស្រីខ្ញុំគាត់ថារៀនក៏គង់ស្លាប់

មិនរៀនក៏គង់តែស្លាប់ដែរ អ៊ីចឹងមិនបាច់ឲ្យរៀនទេ ចេះច្រើននាំតែស្លាប់ដូចឪពុកដែរ ។ អ៊ីចឹងគាត់ក៏អត់ឲ្យកូនរៀន ។ គាត់ក៏អត់ឲ្យរៀនរហូតទៅ ។

ហើយក្នុងការដាក់ពាក្យបណ្ដឹងហ្នឹងទៀត អត់ចង់ឲ្យខ្ញុំដាក់ពាក្យបណ្ដឹងទេ ព្រោះអីគាត់ថា ដាក់ពាក្យបណ្ដឹងទៅគាត់ខ្លាចស្លាប់ទៀត ។ ហើយខ្ញុំតាំងចិត្តថា ខ្ញុំបើស្លាប់ ក៏ខ្ញុំក៏ស្លាប់ចុះ ឲ្យតែបានខ្ញុំជួយរកយុត្តិធម៌ជូនគាត់ថ្ងៃហ្នឹង ។ ខ្ញុំថាខ្ញុំអត់ខ្លាចទេ ខ្ញុំសុខចិត្តស្លាប់ ក៏ស្លាប់ចុះ បើស្លាប់ខ្ញុំមួយទៀតក៏ស្លាប់ចុះ ខ្ញុំថាអ៊ីចឹង ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី តើមានអ្វីត្រូវសួរបញ្ជាក់បន្ថែមដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទេ? ដើម្បីគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់នៅក្នុងរឿងក្ដីនេះ ។ សូមអញ្ជើញ ។

[១៤:២៤:៤៥]

**ការតាំងសំណួរដោយចៅក្រម៖**

**សួរដោយកញ្ញា ម៉ុច សុវណ្ណារី៖**

ជាដំបូង នាងខ្ញុំសូមអរគុណដល់លោកប្រធាននិងអង្គជំនុំជម្រះ ដែលបានផ្ដល់ឱកាសឲ្យនាងខ្ញុំសួរសំណួរទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណីដែលជាកូនក្ដីរបស់នាងខ្ញុំ ។

ជម្រាបសួរអ្នកមីង សូ សួង ខ្ញុំមានសំណួរមួយចំនួន ដើម្បីសួរបញ្ជាក់បន្ថែមទៅនឹងអ្វីដែលអ្នកមីងបានថ្លែងអម្បាញ់មិញទៅដល់អង្គសវនាការ ទាក់ទងជាមួយនឹងជីវិតរបស់អ្នកមីង ការស្លាប់របស់បងថ្លៃរបស់អ្នកមីងនៅមន្ទីរស-២១ ។

**ស៖** ការកត់សម្គាល់របស់នាងខ្ញុំ ជាដំបូងនាងខ្ញុំសង្កេតឃើញថា នៅក្នុងសំណុំរឿងហាក់ដូចជាមានឈ្មោះពីរទៅលើបងថ្លៃរបស់អ្នកមីង ។ តើបងថ្លៃរបស់អ្នកមីង គាត់មានឈ្មោះ មាស ស៊ុន ហ្នឹងតែមួយ ឬក៏គាត់មានឈ្មោះអ្វីផ្សេងពីហ្នឹងទៀត ដែលគាត់ប្រើប្រាស់ដូចគ្នាដែរ?

**ឆ៖** ចាស, ឈ្មោះពីរហ្នឹងមកពីខ្ញុំឮគេប្រាប់មានរូបថតនៅគុកទួលស្លែង អ៊ីចឹងហើយដល់ពេលឮសួរខាងអង្គការអាដហុកថា មានអ្នកណាមានបងប្អូនស្លាប់នៅគុកទួលស្លែង ឲ្យសុំឲ្យដាក់ពាក្យទៅដល់អ៊ីចឹង ។ ហើយខ្ញុំក៏នឹកឃើញថា អ៊ីចឹងខ្ញុំក៏ដាក់ពាក្យ ហើយតែឈ្មោះ-- ខ្ញុំដឹងថាគាត់ពីមុនមក កាលពីខ្ញុំរស់នៅជាមួយ គាត់ដាក់ មាស ស៊ុន។ តែក្រែងខ្លាចគាត់ពេលមកដល់គុកទួលស្លែងហ្នឹង ខ្លាចគាត់ដូរ

ខ្លាចគាត់ដូរដាក់ តេង ស៊ុន ព្រោះអីឪពុកគាត់ឈ្មោះ តេង ស៊ុន ហើយអ៊ីចឹងខ្ញុំក៏ដូចដាក់ឈ្មោះ តេង ស៊ុន អ៊ីចឹងដែរទៅ ។ ប៉ុន្តែ បើថាបើសិនថា ឃើញនៅគុកទួលស្លែងហ្នឹង តេង ស៊ុន ក៏ត្រូវ មាស ស៊ុន ក៏ត្រូវ ។ អ៊ីចឹងបានខ្ញុំដាក់ឈ្មោះពីរមក ។

**ស៖** សូមអរគុណអ្នកមីងដែលបានផ្តល់ចម្លើយនេះដល់អង្គសវនាការ ។ អម្បាញ់មិញនៅពេលដែលលោកប្រធានចាប់ផ្តើមសួរសំណួរដល់អ្នកមីង អ្នកមីងហាក់ដូចជាបានរៀបរាប់បន្តិចអំពីជីវិតរបស់អ្នកមីង នៅតាំងពីមីងអាយុបានប្រាំពីរឆ្នាំ ហើយមីងរស់នៅជាប់ជាមួយនឹងបងស្រីអ្នកមីង ក្រុមគ្រួសារហ្នឹង ។ តើអ្នកមីងអាចរៀបរាប់បញ្ជាក់បន្ថែមម្តងទៀតបានទេ ទាក់ទងជាមួយនឹងជីវិតផ្ទាល់ខ្លួនរបស់អ្នកមីងជាមួយនឹងបងស្រីរបស់មីង ដែលឈ្មោះ ឯម ស៊ន នោះ ។ ហើយក្រោយមកទៀតហេតុបានជាអ្នកមីងបន្តរស់នៅជាមួយនឹងបងស្រីទៀត នៅពេលដែលគាត់បានរៀបការជាមួយនឹងស្វាមីរបស់គាត់ លោក មាស ស៊ុន នៅឆ្នាំ១៩៦៧? អ្នកមីងអាចរៀបរាប់បញ្ជាក់បន្ថែមឲ្យបានលំអិតពីទំនាក់ទំនងនឹងបានទេ?

**ឆ៖** ចាស, ខ្ញុំរស់នៅហ្នឹងជាមួយគាត់តាំងពីអាយុប្រាំពីរឆ្នាំមក។ ឪពុកខ្ញុំគាត់ឲ្យខ្ញុំមកនៅជាមួយម៉ាក់អ៊ំ អ៊ំហ្នឹងពីរនាក់បងស្រីខ្ញុំនឹងនៅរហូតទាល់តែគាត់មានប្តីហ្នឹង គាត់ខ្ញុំយកបងស៊ុន ខ្ញុំហ្នឹង បានបងស៊ុន ហ្នឹងធ្វើជាប្តីរបស់គាត់ ។ អ៊ីចឹង ខ្ញុំក៏រស់នៅជាមួយគាត់ ខ្ញុំក៏ស្រឡាញ់គាត់ គាត់ក៏មាន-- និយាយថាចិត្តរបស់គាត់ហ្នឹងក៏ស្លូតបូត ចង់និយាយថា ក្រុមគ្រួសាររបស់គាត់ គាត់ជាមេគ្រួសារ គាត់ជាអ្នកគ្រប់គ្រងខ្ញុំទាំងអស់តាំងពីការស្លៀកពាក់ ស៊ីចុកអី តាំងពីសៀវភៅរៀន តាំងពីលុយអីទាំងអស់ គឺគាត់អ្នកគ្រប់គ្រងទាំងអស់ ។ អ៊ីចឹង គាត់ចាត់ទុកជាឪពុករបស់ខ្ញុំ បងស្រីខ្ញុំ ខ្ញុំចាត់ទុកជាម្តាយរបស់ខ្ញុំដែរ ។ អ៊ីចឹង ខ្ញុំស្រឡាញ់បងខ្ញុំ ដូចជាបងខ្ញុំបង្កើតអ៊ីចឹង មិនមែនចាត់ទុកថាបងថ្លៃហ្នឹង ជាបង-- ខ្ញុំចាត់ទុកបងថ្លៃហ្នឹងជាបងរបស់ខ្ញុំ មិនមែនចាត់ទុកជាសាច់ដទៃទេ ។ សូម្បីក្រុមគ្រួសារបងប្អូនគាត់ ក៏ខ្ញុំចាត់ទុកថាបងប្អូនខ្ញុំបង្កើត ព្រោះគ្មានមានបងប្អូនអីណាច្រើន ។ អ៊ីចឹង ខ្ញុំក៏ចាត់ទុកបងប្អូនគាត់ ក៏ដូចជាបងប្អូនខ្ញុំដែរ ។ រាល់ថ្ងៃក៏អ៊ីចឹងដែរ បងប្អូនគាត់នៅរស់ ក៏ដូចជាបងប្អូនខ្ញុំអ៊ីចឹងដែរ អ្នកណាដែលនៅរស់ ។

ហើយរហូតមកដល់តែបែកហ្នឹងទៀត មកដល់៧៩ ទៀត ខ្ញុំអះអាងថា ខ្ញុំនឹងដាក់ពាក្យបណ្តឹងហ្នឹងមកពីខ្ញុំនឹង ៧៩ ហ្នឹងខ្ញុំនាំគ្នាពីរនាក់បងខ្ញុំនឹង ខំរកស៊ីចិញ្ចឹមក្មួយៗ រកស៊ី រកតាំងពីជីកក្តួច ជីកដំឡូង ជីកគល់ចេក ជីកគល់ល្ហុង ដើម្បីចិញ្ចឹកក្មួយ ក្មួយៗដែលនៅតូច ទាំងជីវិតខ្លួន ទាំងក្មួយៗទាំងអស់ ។

[១៤:២៩:០០]

ហើយអ៊ីចឹងហើយ រហូតមកដល់សព្វថ្ងៃនេះ រហូតមកទាល់តែខ្ញុំ-- និយាយមកដល់ទៅនៅធ្វើការនៅស្រែអំបិលទៀត ខ្ញុំខំធ្វើការដើម្បីយកលុយយកកាក់មកចិញ្ចឹមក្មួយៗខ្ញុំទៀត ឲ្យបានរស់រៀនមានជីវិត ។ តែខ្ញុំស្តាយក្មួយៗខ្ញុំដែលនៅ-- ស្តាយមួយជីវិតត្រង់ថា ក្មួយៗខ្ញុំអត់បានចេះអក្សរ ព្រោះអីបងខ្ញុំក៏គាត់មិនឲ្យរៀនអ៊ីចឹង ហើយខ្ញុំក៏ខ្ញុំអត់ទាន់ថា ខ្ញុំនឹងបើ-- មិនប៉ានបង្ខំបងខ្ញុំ ព្រោះអីយើងសុទ្ធតែក្រៗដូចគ្នា មិនដឹងជារកណាឲ្យទៅរៀនហ្នឹងអ៊ីចឹង សាលារៀនក៏ឆ្ងាយ អីក៏ឆ្ងាយ ។ អ៊ីចឹងខ្ញុំក៏អត់បាននឹកគិតដល់ថា ឲ្យតែរៀនហ្នឹង វាបានតម្រិះអីតទៅមុខទៀតក៏អត់បានដឹង ។ អ៊ីចឹងក្មួយខ្ញុំទាំងអស់ ត្រូវអត់ចេះអក្សរទាំងអស់ ។ អ៊ីចឹងខ្ញុំនឹងនៅស្តាយក្មួយៗខ្ញុំមួយជីវិតខ្ញុំ ។ ឃើញក្មួយៗខ្ញុំកាលណា ខ្ញុំចង់តែស្រែកយំ ដោយសារតែបាត់ឪពុកហើយ ក្មួយៗខ្ញុំក៏អត់ចេះ ល្ងង់ទាំងអស់ ហើយក្នុងជីវភាពរស់នៅរាល់ថ្ងៃក៏អ៊ីចឹងទៀត សុទ្ធតែក្រៗទាំងអស់គ្នា ។ ពេលដន្លងបងខ្ញុំទៀត សុទ្ធតែអ្នកស្លាប់ប្តីដូចគ្នា ស្លាប់ប្តីនៅសល់តែម៉ែៗដូចគ្នាទៀត ។

ហើយរាល់ថ្ងៃនេះបងខ្ញុំគាត់មានធ្វើខ្ទមមួយនៅជិតក្មួយៗខ្ញុំនេះ ខ្ញុំផ្តល់នូវ-- ផ្តល់លុយ-- ខ្ញុំរកបានបន្តិចបន្តួចមកផ្តល់លុយផ្តល់កាកឲ្យបងខ្ញុំ រហូត-- សឹងតែនិយាយថា រាល់តែខែ ដូចជាខ្ញុំមកសាលាក្តីហ្នឹងអ៊ីចឹងទៅ បានលុយបានកាក់អ៊ីចឹងបន្តិចបន្តួច ខ្ញុំផ្តល់ទៅឲ្យគាត់ សល់ប៉ុន្មានខ្ញុំឲ្យគាត់ចាយ ។ ព្រោះអីខ្ញុំដូចជាជួយចិញ្ចឹមគាត់អ៊ីចឹង ។ ប៉ុន្តែ ខ្ញុំក្រដែរ ខ្ញុំមិនអាចបានជួយបានគាត់ធូរធារទេ ព្រោះខ្ញុំក្រដែរ ។

ចាស, ហើយខ្ញុំនិយាយទៅ ទាំងក្មួយក៏ដោយទាំងខ្ញុំក៏ដោយ បងស្រីគាត់បានឃើញរូបថតហ្នឹងហើយ បានឃើញរូបថតបងថ្លៃហ្នឹងហើយ ខ្ញុំយកទៅឲ្យឃើញហ្នឹង ។ បងស្រីគាត់ខ្ញុំដឹងតែពីស្រែកយំគ្មានស្អី ដឹងតែពីស្រែកយំ រកនិយាយអី ក៏និយាយមិនកើតដែរ ។ ហើយអង្គាល់ពីខ្ញុំដាក់ពាក្យទៀត ខ្ញុំដាក់ពាក្យគាត់ក៏ឈឺទៀត រកដាក់មិនកើត ដាក់ឲ្យគាត់ឈឺហ្នឹង ឈឺរហូតដល់តែមួយឆ្នាំ-- ដល់តែផុតពេល បានខ្ញុំថានឹងដាក់ឲ្យបងថ្លៃខ្ញុំដែរ តែដល់ពេលគាត់ឈឺហួសពេលអ៊ីចឹងទៅ ខ្ញុំក៏តំណាងឲ្យគាត់ហួសទៅ ហួសមក ។ ហើយខ្ញុំៗនិយាយទៅរស់នៅរាល់ថ្ងៃនេះ និយាយដូចថា ទាំងក្មួយ ទាំងបងស្រីខ្ញុំហ្នឹង ក៏មិនមែនថា ចាត់ទុកថាឆ្នាំងផ្សេងដែរ គឺដូចជាឆ្នាំងជាមួយគ្នាហ្នឹង ។ ក្មួយៗ ខ្ញុំបានការបានមានប្តីមានប្រពន្ធហើយ --មែន តែដូចថា យើងនៃការសាច់ឈាមក៏នៅតែរាប់រកគ្នារហូត ទាំងបងខ្ញុំក៏អ៊ីចឹងដូចគ្នា អត់មានទៅណាឆ្ងាយពីគ្នាទេ ។

[១៤:៣១:៥៤]

**ស៖** អរគុណច្រើនអ្នកមីង ដែលបានផ្ដល់ព័ត៌មានទាំងអស់នេះដល់អង្គសវនាការ ។ អ៊ីចឹងនាងខ្ញុំសូមត្រឡប់ទៅបន្តិចនៅក្នុងរយៈពេលដែលអ្នកមីងរស់នៅជាមួយនឹងស្រី និងបងថ្លៃរបស់អ្នកមីង ។ អ្វីដែលអ្នកមីងរៀបរាប់មក ធ្វើឱ្យលេចរូបភាពមួយនៅក្នុងខួរក្បាលរបស់ខ្ញុំ ហើយរូបភាពហ្នឹងបង្ហាញអំពីទំនាក់ទំនងដ៏ជិតស្និតមួយរវាងអ្នកមីងជាមួយនឹងបងស្រីរបស់អ្នកមីង ហើយនិងបងថ្លៃរបស់មីង គឺរវាងអ្នកមីងជាមួយនឹងគ្រួសាររបស់គាត់ទាំងមូលតែម្ដង ។ អ្នកមីងបានរៀបរាប់ប្រាប់សវនាការថា អ្នកមីងមានឪពុកម្ដាយ ក៏ប៉ុន្តែនៅពេលដែលអ្នកមីងអាយុបានប្រាំពីរឆ្នាំ ឪពុកម្ដាយអ្នកមីងបានលែងលះគ្នា ហើយបានបញ្ជូនអ្នកមីង និងបងស្រីអ្នកមីងទៅរស់នៅជាមួយអ៊ំ ។ ពេលហ្នឹងអ្នកមីងហាក់ដូចជាមិនបានទទួលនូវអារម្មណ៍កក់ក្ដៅអំពីឪពុករបស់អ្នកមីងទេ ។ ពីព្រោះគាត់អត់បានបំពេញតួនាទីមួយថាចិញ្ចឹមអ្នកមីង ។ ក្រោយមកទៀត នៅពេលដែលអ្នកមីងរស់នៅជាមួយនឹងបង ហើយនៅពេលដែលគាត់រៀបការ គាត់មានស្វាមីទៅ អ្នកមីងរស់នៅជាមួយគាត់ ហើយស្វាមីរបស់គាត់ហ្នឹងបានប្រព្រឹត្តចំពោះអ្នកមីង ផ្គត់ផ្គង់ថែរក្សាអ្នកមីង ។ អ៊ីចឹងហាក់ដូចជា គាត់ហ្នឹងបាននាំមកនូវភាពកក់ក្ដៅភាពជាឪពុកលក្ខណៈ ក្នុងលក្ខណៈជាឪពុកដល់អ្នកមីង ។ តើអ្នកមីងពិតជាមានអារម្មណ៍បែបហ្នឹងទេ អ្នកមីងអាច-- តើការសន្និដ្ឋានរបស់ខ្ញុំហ្នឹង គឺត្រឹមត្រូវទេ អារម្មណ៍ដែលអ្នកមីងមានចំពោះគាត់?

**ឆ៖** ចាស, អូនៗ បើខ្ញុំនិយាយទៅថា ខ្ញុំបងថ្លៃខ្ញុំក៏ដូចជាបងខ្ញុំបង្កើតដែរ ហើយបងប្អូនគាត់ក៏ដូចជាបងប្អូនខ្ញុំអ៊ីចឹង ។ ខ្ញុំស្រឡាញ់ហាក់ដូចជាឪពុកខ្ញុំអ៊ីចឹង ដូចជាបងប្រុសខ្ញុំបង្កើតអ៊ីចឹង ។ បានថាអ៊ីចឹងគាត់និយាយទៅថា តាំងពីជីវភាព តាំងពីខោអាវ តាំងពីសៀវភៅរៀនអីមួយចប់ ។ និយាយទៅគាត់អ្នកគ្រប់គ្រងទាំងអស់ មិនមែនថាគាត់ហ្នឹង ខ្ញុំជាប្អូនថ្លៃគាត់ គាត់មិនគិតគួរ អត់ទេ គាត់ គឺគិតគួររហូត លុះដល់ទៅ-- ឆ្នាំ៧០ហ្នឹង ពាក់កណ្ដាលឆ្នាំ៧០ហ្នឹង ពិបាកពេកៗ អ៊ីចឹងថា ពិបាកពេក រវល់រត់ចុះរត់ឡើងនៅម្ខាង-- ដីនៅព្រំប្រទល់គ្នាហ្នឹងដីរំដោះ ហើយនិងដី-- តទល់គ្នាអ៊ីចឹង អ៊ីចឹងមានតែខាងខ្មែរក្រហម ហើយខាង លន់ នល់ ផ្សេងអ៊ីចឹងទៅ ដល់អ៊ីចឹងពិបាកចុះរត់ចុះរត់ឡើងអ៊ីចឹង ខ្លាច ។ គាត់ខ្លាចក្រែងទាហាន លន់ នល់ នឹងចាប់ខ្ញុំបាន អ៊ីចឹងគាត់បានបញ្ជូនខ្ញុំឱ្យទៅជាមួយម៉ែ ។ អ៊ីចឹងបានថា ខ្ញុំថាស្រឡាញ់គាត់ដូចជាឪពុករបស់ខ្ញុំ ឬក៏ដូចជាបងរបស់ខ្ញុំបង្កើតអ៊ីចឹង មិនមែនថា ចាត់ទុកគាត់ជា បងថ្លៃទេ ។

**ស៖** ចាស, សូមអរគុណអ្នកមីង ។ អ៊ំមិញអ្នកមីងថា នៅឆ្នាំ៧០ គាត់បានបញ្ជូនអ្នកមីងចេញពីផ្ទះរបស់គាត់ដែលគាត់ខ្លាចទាហានចាប់អ្នកមីង ។ អ្នកមីងអាចបញ្ជាក់បានទេថា នៅសម័យបើសិន

ជាអ្នកមីងត្រូវទាហាន លន់ នល់ ចាប់បាន តើគេនឹងធ្វើអ្វីចំពោះអ្នកមីង បានជាគាត់ខ្លាចបែបហ្នឹង? ហើយគាត់ការពារអ្នកមីងបែបហ្នឹង?

**ឆ៖** ចាស, អង្កាល់ពីឆ្នាំ៧០ហ្នឹងមានឃើញគំរូសម្រាប់ហើយ តែអ្នកអស់នោះស្លាប់អស់ហើយ ដូចថាកាលជំនាន់នោះ ខាងម្ខាងដីរំដោះ ម្ខាងដីខាង លន់ នល់ អ៊ីចឹង ។ ដល់ពេលអ៊ីចឹងទាហាន លន់ នល់ គាត់ឡើងទៅអ៊ីចឹងជួបប្រទះនឹងក្មេងស្រីក៏ដោយ ឬក៏ក្រមុំ-- នៅក្រមុំក៏ដោយ ក៏ចាប់រំលោភ ។ ដល់អ៊ីចឹងហើយមានការចាប់រំលោភនោះមានទាល់តែស្លាប់ខ្លួនទៅទៀត ។ អ៊ីចឹងហើយបានបងខ្ញុំគាត់ភ័យគាត់ៗភ័យខ្លាចចាប់ខ្ញុំបានអ៊ីចឹងទៅ ព្រោះអីខ្ញុំវានៅចង្រ្កានជើងឆ្នាំង អ៊ីចឹងគាត់ខ្លាចក្រែងលោពេលណាដែលវាឡើង ទាហានឡើងទៅអ៊ីចឹង អ៊ីចឹងក្រែងលោខ្លាចខ្ញុំអត់ដឹងគេចាប់ខ្ញុំបាន ។ អ៊ីចឹងខ្លាចទាហានចាប់ខ្ញុំ គាត់ក៏បញ្ជូនខ្ញុំឲ្យទៅនៅនោះ ខ្លាចខ្ញុំពិបាកនឹងដើររត់ចុះរត់ឡើង ។ បើទៅនៅជាមួយម៉ែខ្ញុំទៅអាហ្នឹងគាត់នៅដីរំដោះពេញហឹងតែម្តង ។ អ៊ីចឹងមិនអាចនឹងទាហាន លន់ នល់ ទៅបានទេ ។ អរគុណ ។

**ស៖** អរគុណអ្នកមីង ។ បន្ទាប់ពីអ្នកមីងបានចាកចេញពីគ្រួសាររបស់គាត់នៅឆ្នាំ៧០ ក្រោយមកតើជីវិតរបស់អ្នកមីងរស់នៅយ៉ាងម៉េចទៀត? អ្នកមីងអាចរៀបរាប់បានទេ តាំងពីពេលដែលបែកហ្នឹងគ្នាហ្នឹងមករហូតមកដល់ថ្ងៃរំដោះថ្ងៃ ៧ មករា ឆ្នាំ១៩៧៩ ។ តើនៅក្នុងអំឡុងពេលហ្នឹងអ្នកមីងនៅតែរក្សាទំនាក់ទំនងជាមួយនឹងគ្រួសារគាត់តទៅទៀត ឬក៏ដាច់ទំនាក់ទំនងគ្នាហើយ ឬក៏យ៉ាងម៉េច? សូមអ្នកមីងជួយរៀបរាប់បញ្ជាក់បន្តិច ។

[១៤:៣៦:២១]

**ឆ៖** ចាស, ខ្ញុំគ្រាន់តែខ្ញុំទៅនៅៗជាមួយម៉ែឆ្នាំ៧០ ហ្នឹងហើយក៏ខ្ញុំអត់មានចោលគាត់ដែរ ទៅមកៗតែជាមួយគាត់ហ្នឹង ។ នៅនោះដី-- ពិតមែនថា អត់ពាក់ព័ន្ធជាមួយនឹងជាហាន លន់ នល់ ដែរ តែគាត់នៅពាក់ព័ន្ធដីព្រំទល់ តែខ្ញុំនៅតែទៅមកៗជាមួយគាត់ហ្នឹងរហូត ។ និយាយទៅនៅរហូតដល់តែបងខ្ញុំឲ្យខ្ញុំនៅឃុំពពើលពក ឲ្យនៅមន្ទីរឃុំពពើលពក ដល់អ៊ីចឹងនៅរហូតទាល់តែដល់ឆ្នាំ-- ខែ១១ ពាក់កណ្តាលខែ១១ហ្នឹង ឆ្នាំ៧៤ ហ្នឹងបានខ្ញុំ-- បានអង្គការឲ្យខ្ញុំទៅនៅស្រែអំបិល ។ ស្រែអំបិល ភូមិកោះស្វាំង ឃុំស្វាយទង ស្រុកកំពង់ត្រាច ឲ្យខ្ញុំទៅនៅហ្នឹងបានគ្រាន់ដាច់រយៈបន្តិច ។ តែដល់ឆ្នាំ៧៦ ខ្ញុំក៏នៅស្រែអំបិលដែរ តែដល់ពេលអ៊ីចឹងខ្ញុំក៏មានជំងឺកើតម្រេញ អ៊ីចឹងក៏ខ្ញុំសូមអង្គការឲ្យមកផឹងថ្នាំនៅផ្ទះ ខ្ញុំក៏បាន នៅជាមួយគាត់រយៈកាលជាងពីរខែទៀត ។

លុះដល់ឆ្នាំ៧៧ ហ្នឹងបានអង្គការផ្លាស់គាត់ទៅសៀមរាប ទៅនឹងស្រុកពួក ខេត្តសៀមរាបហ្នឹង

ទៅ ក៏ដាច់រយៈរហូត ។ ដល់តែពេលឆ្នាំ៧៩ ហ្នឹងបានៗជួបគាត់ជួបប្រពន្ធគាត់ម្តងទៀតថា ប្រពន្ធគាត់ថាប្តីគាត់បានស្លាប់បាត់ទៅហើយហ្នឹង ។ ហ្នឹងគិត យើងមិនគិតអីទេ គិតតែនាំគ្នាយំរហូត អត់មានគិតអីទេ ។ ហើយអ៊ីចឹងក៏នាំគ្នាខំប្រឹងរកស៊ីចិញ្ចឹមក្មួយរហូតទៅ ។ រហូតទាល់តែខ្ញុំហ្នឹង មានប្តីឆ្នាំ៨៧ នឹងខ្ញុំទៅនៅកំពង់សោម ៨៧តែម្តង ។

[១៤:៣៨:០៦]

**ស៖** អរគុណអ្នកមីង ។ អំមិញអ្នកមីងបានមានប្រសាសន៍ថា នៅពេលដែលអ្នកមីងមកជួបជុំគ្រួសារបងស្រីរបស់អ្នកមីងវិញហ្នឹង អ្នកមីងក៏ព្យាយាមរកស៊ីចិញ្ចឹមក្មួយៗ ចិញ្ចឹមគ្រួសារទាំងមូលជាមួយនឹងបងស្រី ។ អ្នកមីងអាចជម្រាបជូនអង្គសវនាការបានទេថា នៅពេលនោះតើអ្នកមីងរកស៊ីអ្វី? ប្រកបមុខរបរអ្វីដើម្បីចិញ្ចឹមមនុស្សជាច្រើននៅក្នុងគ្រួសារ បូកទាំងក្មួយៗ ដែលត្រូវជាកូនរបស់បងស្រីអ្នកមីងទៀតនោះ?

ខ្ញុំសូមសួរសំណួរអ្នកមីងម្តងទៀត--

**ឆ៖** ចាស--

**ស៖** តើហ្នឹង នៅអ្នកមីងរកស៊ីចិញ្ចឹមគ្រួសារទាំងមូលហ្នឹង? តើអ្នកមីងប្រកបរបរអីដែរ អាចជម្រាបជូនអង្គសវនាការបានទេអ្នកមីង?

**ឆ៖** ចាស, ខ្ញុំ-- មុខរបររបស់ខ្ញុំកាលមកពីព្រៃមកអត់មានមុខរបរអីទេ នាំគ្នាទៅជីកដំឡូង ជីកក្តួច ជីក-- មានគល់ល្ហុងអី ជីកគល់ល្ហុង មានគល់ចេកជីកគល់ចេក អាជំនាន់នុ៎ង គឺនិយាយថា ដែលជីកគល់ចេក គល់ល្ហុងហ្នឹង ដែលចម្ការជំនាន់ខ្មែរក្រហម ដែលវាដាំ ។ ហើយអ៊ីចឹង ទៅប្រទះរកដំឡូងមិនបានអ៊ីចឹងនាំគ្នាទៅជីកអាគល់ចេក គល់ល្ហុងហ្នឹងមកហាន់ចិញ្ច្រាំបបរដើម្បីចិញ្ចឹមក្មួយ ។ ហើយដល់ទៅឆ្នាំ៨០ មានខាងធ្វើស្រែអំបិលគេប្រកាសថា អ្នកណាចង់ធ្វើស្រែអំបិលឲ្យដាក់ឈ្មោះ ឲ្យដាក់--សរសេរប្រវត្តិរូបដើម្បីចូលធ្វើស្រែអំបិល ។ ហើយអ៊ីចឹងខ្ញុំក៏នាំគ្នា មកស្នាក់នៅកន្លែងភូមិតាអេងហ្នឹងដូចថា គេមកប្រកាសប្រាប់ឲ្យ-- ចង់ធ្វើស្រែអំបិលឲ្យដាក់ប្រវត្តិរូបទៅធ្វើស្រែអំបិល ខ្ញុំក៏ដាក់ទៅពីរនាក់បងប្អូនហ្នឹងមកធ្វើស្រែអំបិលទៅ ទាំងពីរមកដើម្បីយកលុយយកកាក់អីទៅ-- ។

យកមុនដំបូងគេអត់ទាន់ចេកលុយទេ ហ្នឹងហើយគេអត់ទាន់បើកលុយទេ បើកជាអង្ករ ដើម្បីយកទៅចិញ្ចឹមក្មួយៗនិងឪពុកម្តាយ ។ ឪពុកម្តាយគាត់នៅផ្សេងមែន ប៉ុន្តែ ខ្ញុំនៅតែឲ្យ ខ្ញុំពីរនាក់បងប្អូនខ្ញុំរកស៊ីចិញ្ចឹមក្មួយផង ក្មួយៗផងជួយឪពុកម្តាយផង ។

[១៤:៤០:១៥]

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តី គឺនៅសល់ពីរមីនុតទៀតទេ ហើយមេធាវីគប្បីរកសំណួរឯណាដែលឲ្យចំដើម្បីឲ្យគាត់ឆ្លើយមានប្រយោជន៍សម្រាប់សម្តែងការពិត នៅក្នុងរឿងទំនាក់ទំនងនៃសិទ្ធិនៅក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងទំនាក់ទំនងទៅនឹងទាយាទ ដែលជាជនរងគ្រោះនៅក្នុងអង្គហេតុដែលបានចោទប្រកាន់ចំពោះជនជាប់ចោទ ។ ការតាំងសំណួរឃ្លាតឆ្ងាយអំពីអង្គហេតុពេក ហើយពេលវេលាដូចអស់ហើយនៅសល់តែពីរមីនុតទៀតទេ ។

**សួរដោយកញ្ញា ម៉ុច សុវណ្ណារី៖**

អរគុណច្រើនលោកប្រធាន ។ នាងខ្ញុំនឹងប្រើពីរនាទីនេះ សួរសំណួរចុងក្រោយរបស់នាងខ្ញុំ ។

**ស៖** អ្នកមីងខ្ញុំចង់សួរសំណួរចុងក្រោយថា បន្ទាប់ពីមានការស្លាប់ទៅលើ-- បន្ទាប់ពីបងថ្លៃរបស់អ្នកមីងស្លាប់ហើយរហូតមកដល់បច្ចុប្បន្ននេះ ។ តើស្ថានភាពគ្រួសារបងស្រីអ្នកមីង ស្ថានភាពរបស់អ្នកមីងយ៉ាងម៉េចដែរ? តើការឈឺចាប់ហ្នឹងនៅតែបន្តរហូតមកដល់បច្ចុប្បន្ន ហើយការស្លាប់ហ្នឹងវាបានជះឥទ្ធិពលអ្វីខ្លះ ទៅដល់បងស្រីអ្នកមីង? ទៅដល់រូបអ្នកមីងផ្ទាល់? ម្តាយអ្នកមីង? ហើយនិងកូនៗទាំងបីរបស់ពួកគាត់?

**ឆ៖** ចាស, ព្រោះបានថាគាត់ស្លាប់ហើយហ្នឹង ដល់ពេលខ្ញុំបានដឹងហើយនិងឃើញរូបថតហ្នឹងទៅបងស្រី-- និយាយទៅតាំងពី៧៩ មក និយាយទៅថា គាត់ជីវភាពរបស់គាត់ហ្នឹង គឺវាជុនដាបខ្លាំងៗមែនទែន ដែលថានិយាយទៅបើដល់ពីកូនរបស់ទៀតដល់ថ្នាក់អត់បានរៀនទៀត ខុសគ្មានអ្នកថា អត់ឪពុកចិញ្ចឹមអ៊ីចឹងទៅ មានតែខ្ញុំ ហើយនិងបងខ្ញុំហ្នឹង ។ អ៊ីចឹង រកស៊ីក៏មិនបានដូចឪពុកចិញ្ចឹមដែរ អ៊ីចឹងនិយាយថា រាល់ថ្ងៃហ្នឹងនៃការទុក្ខសោករបស់គាត់ ទាំងកូន ទាំងកូនៗ ទាំងគាត់ ទាំងខ្ញុំអីក៏ដោយ ក៏មានការទុក្ខសោករហូត ។ ហើយកូនៗក៏និយាយទៅថា បើសិនជាឪពុកវានៅមិនដឹងជាវាសប្បាយចិត្តយ៉ាងណាទេ ហើយដល់ពេលឥឡូវនេះ គឺវានិយាយថា វានឹងគ្មានឪពុកអ៊ីចឹង វាថា វាស្តាយណាស់ ស្តាយមិនដឹងធ្វើម៉េចបានឪពុកវាបានត្រឡប់មកវិញ ។ វានិយាយអ៊ីចឹង វាស្តាយខ្លាំងណាស់ ។

អ៊ីចឹងបានថា អ៊ីចឹងនិយាយទៅថា ទាំងអស់គ្នាមិនមែនគិតអី គិតតែស្តាយមួយជីវិតអ៊ីចឹងតែម្តង ។ ហើយថា មិនដឹងថា ទៅរកអីបានដែលជំនួសនឹងឪពុករបស់វា ។ មានតែនិយាយថា ការស្តាយហ្នឹង ។ ហើយថា ក្នុងពេលៗនោះមិនដឹងធ្វើបានបាបឪពុកវាយ៉ាងម៉េចខ្លះកាលពីជំនាន់ដែលយកឪពុក

វាមកសម្លាប់នេះ មិនដឹងគេធ្វើបាបគាត់យ៉ាងម៉េច? វានៅនិយាយថា កាលដែលមិនទាន់មកឃើញរូបថតយំល្មមទេ ទាល់តែពេលឃើញរូបថតវាកាន់តែនាំគ្នាយំទាំងអស់គ្នា ។ បីនាក់បងប្អូន ទាំងម្តាយ ទាំងប្អូនៗ ហើយនិយាយទាំងបងប្អូន និយាយទាំងអ្នកស្រុកថែមទៀតឲ្យតែឃើញរូបថតហ្នឹង គឺនាំគ្នាយំទាំងអស់គ្នា ។ ស្តាយស្រណោះទាំងអស់ និយាយទៅទាំង តាឆយ ជាប្រធានឃុំ ត្រូវជាពួកម៉ាក់របស់គាត់ក៏គាត់ស្តាយ ក៏យំស្តាយដែរ ។ ថ្ងៃមុនហ្នឹង ខ្ញុំទៅជួបគាត់ហ្នឹង គាត់យំស្តាយស្រណោះណាស់ ។ គាត់ថា មិនគួរណាគេយកមកសម្លាប់គាត់ទេ ព្រោះមនុស្សគាត់ស្លូតថាអ៊ីចឹង ។ គាត់ស្លូត រាល់ថ្ងៃមិនដែលនិយាយអីសម្តីដាក់ធ្ងន់ដាក់ទៅលើអ្នកណាម្នាក់ ។ ហើយអ៊ីចឹងអ្នកទាំងអស់គ្នា ក៏ស្តាយទាំងកូនៗក៏ស្តាយ ហើយទាំងនិយាយថា បើវេទនានោះ វារាល់ហ្នឹង គឺវេទនាមហាសែនវេទនាហើយ ។ ខ្ញុំនិយាយទៅ មិនដឹងនិយាយថាម៉េច បើវាអត់ៗវេទនាពេក និយាយរាល់ថ្ងៃក៏គ្មានផ្ទះនៅ ក៏គាត់នៅខ្ទម ជាខ្ទមរបស់គាត់ ។

**កញ្ញា ម៉ុច សុវណ្ណារី៖**

អរគុណអ្នកមីង ។

លោកប្រធានខ្ញុំសូមបញ្ចប់សំណួរត្រឹមនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ម៉ោងត្រូវសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ពេលនេះ ទៅរហូតដល់ម៉ោងបី អញ្ជើញចូលវិញដើម្បីបន្តដំណើរការសវនាការ ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីអាចរកកន្លែងសម្រាកនៅទីកន្លែងដើម ហើយដល់ពេលម៉ោងកំណត់ចូលមកអង្គុយទីនេះវិញ ដើម្បីបន្តការពិភាក្សាដេញដោលបន្តទៀត ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១៤:៤៥នាទីដល់ម៉ោង ១៥:០០នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

ជាបន្តនេះ អង្គជំនុំជម្រះប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ប្រសិនបើជាមានសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ សូមអញ្ជើញ ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា៖**

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន សូមអរគុណលោក លោកស្រីចៅក្រម ។ យើងខ្ញុំមានសំណួរពីរ ឬក៏បីចង់សួរលោកស្រី សូ សូង ហើយខ្ញុំជឿថា ខ្ញុំបានស្តាប់បាននិងយល់ថា ដើមបណ្តឹងរដ្ឋប្បវេណីមួយនេះមានរូបថតរបស់បងថ្លៃដែលបានថតនៅស-២១ ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះធ្វើការបញ្ចាំងរូបថតនេះ ដើម្បីយើងអាចមានគោលគំនិតយល់ថា តើនរណាគេជាបងប្រុសថ្លៃរបស់គាត់?

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោកឲ្យនូវលេខ ERN ឬក៏លេខឯកសារជាក់លាក់ដើម្បីឲ្យយើងអាចបញ្ជាទៅមន្ត្រីផ្នែកខាងសោតទស្សន៍ ដែលអាចមានលទ្ធភាពបង្ហាញនូវឯកសារដែលលោកតំណាងសហព្រះរាជអាជ្ញាប៉ុនប៉ងឲ្យបង្ហាញនេះ ។ បើមិនផ្តល់អត្តសញ្ញាណនៃឯកសារទេ អង្គជំនុំជម្រះមិនអាចធ្វើបានទេ ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន បាទខ្ញុំនឹងផ្តល់ជូន ។ ឧបសម្ព័ន្ធនៃរូបថត គឺមានលេខ ERN 00282 315 ។ ដោយសារតែខ្ញុំមានឯកសាររូបថត ថតចម្លងនេះ ថាតើវាជាគំនិតល្អទេ យើងបញ្ចាំងតាមរយៈម៉ាស៊ីនបញ្ចាំងធម្មតារបស់យើងទៅ ដោយប្រើឯកសារមួយនេះ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយករូបថតនេះទៅដាក់បញ្ចាំងនូវម៉ាស៊ីនស្កាយ ដើម្បីបង្ហាញរូបភាពនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមសួរលោកប្រធាន ។

**ស៖** ថាតើដើមបណ្តឹងរដ្ឋប្បវេណីអាចស្គាល់រូបថតនេះដែរឬទេ គឺរូបថតរបស់ មាស ស៊ុន?

**ឆ៖** ចាស, ខ្ញុំស្គាល់រូបថតរបស់បងថ្លៃខ្ញុំ ។

**ស៖** សូមអរគុណច្រើន ។ ខ្ញុំចង់សួរសំណួរចំនួនពីរផ្សេងទៀត ចង់សួរលោកស្រី គឺមិនពាក់ព័ន្ធទៅនឹងរូបថតនេះទេ ។ ដូច្នេះ ហើយយើងអាចដករូបថតនេះចេញវិញបាន ។ សូមការអនុញ្ញាតពីលោកប្រធានធ្វើការដករូបថតនេះ ។

លោកស្រី សូ សូង ថាតើលោកស្រីទទួលបានព័ត៌មានផ្សេងៗដែរឬទេ មូលហេតុអ្វីបានជាបងថ្លៃរបស់លោកស្រីត្រូវបានចាប់ខ្លួន? លោកស្រីបានលើកឡើងថា គាត់ធ្វើការនៅស្រុក តើលោកស្រីទទួលបានព័ត៌មានផ្សេងដែរឬទេ? ទាក់ទងទៅនឹងមូលហេតុអ្វីបានជាគេចាប់ខ្លួនបងថ្លៃរបស់លោកស្រី?

**ឆៈ** ចាស, ខ្ញុំអត់ដឹងថា គេចាប់ខ្លួនគាត់មកៗគុកទួលស្លែងនេះ ខ្ញុំអត់បានដឹងដែរ ។ កាលពី-- ដល់ពេលឆ្នាំ៧៩ហ្នឹង បានបងស្រីខ្ញុំគាត់រត់មកពីស្រុកពួកមកវិញមក ខ្ញុំក៏ខ្ញុំរត់ពីស្រុក-- កាលពីជំនាន់រត់យួនហ្នឹង ខ្ញុំក៏រត់ទៅដល់ស្រុកបាកាន អ៊ីចឹងក៏រត់មកវិញត្រឡប់មកវិញ ក៏ជួបគ្នានៅស្រុកកំណើតហ្នឹងវិញមក ។ អ៊ីចឹងបងស្រីខ្ញុំគាត់ថា “បងអ្អែងស្លាប់ហើយ អ៊ីចឹងបងអ្អែងស្លាប់ហើយ គេយកទៅសម្លាប់នៅគុកទួលស្លែង ឮតែថាពេទ្យ តាម៉ុក គាត់និយាយថាអ៊ីចឹង” ។ អ៊ីចឹងក៏ខ្ញុំនឹកឃើញថា រូបថតគាត់ពិតជានៅគុកទួលស្លែងមែន ហើយទៅដល់ឆ្នាំ៨០ បានពូនី គាត់ក៏មកឃើញថា រូបថតហ្នឹងពិតជារូបថតបង ស៊ុន ហ្នឹងហើយ ។ ហើយខ្ញុំក៏ដល់តែឆ្នាំយើង២០០៧ហ្នឹង ២០០៧-២០០៨ ហ្នឹង បានឮស្គរអង្គការអាដហុកហ្នឹង ប្រកាសប្រាប់អ៊ីចឹងមក ខ្ញុំក៏ដាក់ពាក្យមក ។ ហើយខ្ញុំដាក់មកអ៊ីចឹងបានអង្គការ *ធីភីអូ*(TPO)ហ្នឹង អង្គការជំងឺផ្លូវចិត្តហ្នឹង ហើយបានអង្គសិទ្ធិមនុស្សអាដហុកហ្នឹង ហើយខាងមេធាវីហ្នឹងគាត់នាំ ពួកខ្ញុំហ្នឹង ពួកអ្នកដាក់ពាក្យបណ្តឹងទាំងប៉ុន្មានហ្នឹង បានប្អូនប្រាំនាក់ហ្នឹង មកនៅឃើញ-- មកគុកទួលស្លែងហ្នឹង ខ្ញុំក៏ឃើញរូបថតហ្នឹង ។ ខ្ញុំឃើញរូបថតហ្នឹង ក៏ខ្ញុំស្រឡាំងកាំង ខ្ញុំរន្ធត់ចិត្ត ខ្ញុំចង់សន្លប់នៅកន្លែងហ្នឹងទៀត តែតាំងស្មារតីថា ខ្ញុំនឹងត្រូវតែតាំងកុំឲ្យខ្ញុំដួលខ្ញុំខ្មាសគេ ។ អ៊ីចឹង ខ្ញុំតាំងចិត្តទម្រាំនឹងបានប៉ានមើលរូបថតបងថ្លៃខ្ញុំហ្នឹង ។

ហើយខ្ញុំតាំងពីដើមកាលណាមក ខ្ញុំស្រឡាញ់បងថ្លៃខ្ញុំ ហាក់ដូចជាឪពុករបស់ខ្ញុំ មិនថាគាត់ហ្នឹងជាថ្លៃទេ ខ្ញុំថាចាត់ទុកគាត់ជាឪពុករបស់ខ្ញុំ ខ្ញុំស្រឡាញ់គាត់រហូត និយាយទៅនៅដល់ណាក៏ដោយក៏ខ្ញុំនៅតែអារម្មណ៍នឹកគាត់រហូត ទោះបីគាត់បែកទៅសៀមរាបហើយក៏ដោយ ខ្ញុំនៅតែស្រមៃថាបងខ្ញុំនៅជាមួយខ្ញុំរហូត ។ ព្រោះអី ខ្ញុំប៉ានថាអ៊ីចឹង ខ្ញុំស្រឡាញ់ចិត្តគាត់ណាស់ ព្រោះគាត់មិនដែលសម្តីអាក្រក់ដាក់ខ្ញុំណាមួយម៉ាត់សោះ ។

[១៥:១៧:១១]

**សៈ** ថាតើលោកស្រីដឹងដែរឬទេ គេចាប់បងថ្លៃរបស់លោកស្រីនៅពេលណា? ថាតើលោកស្រីបានដឹងទេថាពេលដាក់លាក់នោះ គឺពេលណាដែលគេចាប់បងថ្លៃរបស់លោកស្រីនោះ?

**ឆ៖** ពេលដែលគេចាប់បងស្រីខ្ញុំមកនោះ-- បងថ្លៃខ្ញុំមកនោះ បងស្រីខ្ញុំគាត់ថា គាត់មកពីធ្វើការមក គាត់បាត់ប្ដីគាត់ ដល់ពេលបាត់ប្ដីគាត់អ៊ីចឹង គាត់ក៏សួរនីរសារថា "គ្រួសារខ្ញុំទៅណាហើយ?" គាត់ថា នីរសារថា "បងទៅយកទៅរៀនសូត្រហើយ" យករៀនសូត្រអ៊ីចឹង គាត់ក៏សួរទៅថា "ថ្ងៃហ្នឹង ត្រូវថ្ងៃអីគេ? ថ្ងៃទីប៉ុន្មាន?" ។ អ៊ីចឹង ក៏គាត់ទាញធ្យូងយកមកសរសេរនៅជញ្ជាំងផ្ទះថា ថ្ងៃទី២៨ ខែ១១ ឆ្នាំ១៩៧៨ ។ អ៊ីចឹង ក៏គាត់បានកត់ទុកអ៊ីចឹងទៅក៏ចាំៗនៅក្នុងចិត្តគាត់ ហើយគាត់ក៏មកដល់ស្រុកភូមិវិញ គាត់ក៏ប្រាប់ខ្ញុំថាអ៊ីចឹង ។ គាត់ប្រាប់ថា ស្ដាប់គេចាប់យកមកថ្ងៃទី២៨ ខែ១១ ឆ្នាំ៧៨ បានគាត់ប្រាប់អ៊ីចឹង ។

**ស៖** លោកស្រី សូ សួង ខ្ញុំមានសំណួរចុងក្រោយមួយ ។ បន្ទាប់ពីការប្រកាសការស្លាប់របស់ប្ដីបងស្រីរបស់លោកស្រី តើបងស្រីរបស់លោកស្រី គឺនៅក្នុងស្ថានភាពដដែល ឬក៏គាត់អាចប្រឈមទៅនឹងស្ថានភាពនោះដែរឬទេ? និយាយឲ្យចំទៅថាតើបងស្រីរបស់លោកស្រីហ្នឹងមានទុក្ខសោកយ៉ាងណា? ហើយមានការឈឺចាប់យ៉ាងណា នៅពេលដែលបានដឹងការស្លាប់របស់បងថ្លៃរបស់លោកស្រីនោះ?

**ឆ៖** ចាស, បងស្រីខ្ញុំគាត់គ្រាន់តែឮសូរដំណឹងថា គេយកមករៀនសូត្រអ៊ីចឹង គាត់និយាយថា គាត់ដឹងតែពីយំ គាត់អត់មាននិយាយថា កូនគាត់នៅជាមួយនឹងនេះ តែគាត់ដឹងតែពីយំ ។ ហើយតែគាត់លួចយំហ្នឹង យំអត់ឃើញទេ ខ្លាចគេយកគាត់រំលែចោលអត់មានអ្នកចិញ្ចឹមកូនគាត់ទៀត ។ អ៊ីចឹង គាត់លួចយំ អត់ឲ្យគេឃើញទេ ហើយគាត់ទៅរែងអាចម៍ជ្រូកដូចពីមុនដែលគាត់កាលបងថ្លៃខ្ញុំ គេអត់ទាន់យកមកអ៊ីចឹង គេដាក់-- គាត់កូនង៉ែតហើយបានជាងកន្លះខែ គេឲ្យទៅរែងអាចម៍ជ្រូករហូតទាល់ហ្នឹង និយាយទាល់រែងអាចម៍ជ្រូករហូតតែរំដោះបាន ដល់តែ៧ មករា មុននឹងរត់នឹងតែម្ដង ។ គាត់ថា ។

[១៥:២០:១២]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្ដី ដើម្បីមានឱកាសក្នុងការសួរសំណួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមានសំណួរ ។ សូមអញ្ជើញ ។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី៖**

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។

**ស៖** សូមលោកស្រីបញ្ជាក់ឲ្យបានច្បាស់ តើបងថ្លៃលោកស្រីហ្នឹងគាត់ជាសមាជិកស្រុកបាកាននៅឆ្នាំណា? ហើយឆ្នាំណាបានមកជាសមាជិកស្រុកថ្មពួក? សូមលោកស្រីបញ្ជាក់កន្លែងហ្នឹង ។

**ឆ៖** ចាស, គាត់នៅស្រុកបាកានទេ-- គាត់នៅស្រុកនេះ គាត់នៅស្រុកពួក គាត់នៅខេត្តសៀមរាប ស្រុកពួក តែបាកាននោះ ខ្ញុំនឹងរត់ទៅដល់ហ្នឹង កាលពីជំនាន់ហ្នឹង ។ កាលពីឆ្នាំជំនាន់ឆ្នាំ៧៩ហ្នឹង ខ្ញុំរត់ទៅដល់ហ្នឹង ដល់ពេលហ្នឹងហើយបាននាំគ្នារត់មកវិញ ។ ខ្ញុំទេដែលខ្ញុំរត់ទៅដល់ស្រុកបាកាន គាត់អត់មានរត់ទេ គាត់ហ្នឹងផ្លាស់ទៅនៅខេត្តសៀមរាប ស្រុកពួក ។ តែគ្រាន់ច្រឡំគ្នា បើខ្ញុំនិយាយទៅច្រឡំក៏មិនដឹង ខ្ញុំសូមទោសកន្លែងហ្នឹងដែរ ព្រោះខ្ញុំច្រើនតែនិយាយច្រឡំមាត់ ។

**ស៖** សូមអរគុណ ពីព្រោះក្នុងពាក្យបណ្ដឹងរបស់លោកស្រី លោកស្រីដាក់ថា មាស ស៊ុន សមាជិកស្រុកបាកាន ។ ហើយដល់ក្រោយមកទៀត ថា មាស ស៊ុន ធ្វើជាសមាជិកស្រុកពួក ។ អ៊ីចឹងហើយបានខ្ញុំចង់ដឹងថា តើគាត់ធ្វើសមាជិកស្រុកបាកានឆ្នាំណាដល់ឆ្នាំណា? ហើយសមាជិកស្រុកពួកនេះពីឆ្នាំណាដល់ឆ្នាំណា? ឥឡូវលោកស្រីបានបញ្ជាក់ច្បាស់ហើយ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ ។ សូមអរគុណលោកប្រធាន សូមឲ្យមេធាវីអន្តរជាតិគាត់សួរបន្ត ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្ដីអន្តរជាតិ ។

**សួរដោយលោកស្រី ម៉ារីប៉ូល កានីហ្សអេស៖**

សូមអរគុណលោកប្រធាន ។

**ស៖** អម្បាញ់មិញនេះតាមសំណើរបស់សហព្រះរាជអាជ្ញា យើងបានឃើញរូបថតរបស់បុគ្គលមួយរូបដែលលោកស្រីបានបញ្ជាក់ថា ជាបងថ្លៃរបស់លោកស្រី តើលោកស្រីអាចជម្រាបបានដែរឬទេថាតើលោកស្រីបានទទួលរូបថតនេះនៅក្នុងកាលៈទេសៈបែបណាទើបទៅយករូបថតអ៊ីចឹងមកបានហ្នឹង?

[១៥:២២:៥៦]

**ឆ៖** ចាស, រូបថតនេះ ខ្ញុំយកបានហ្នឹង កាលឆ្នាំ៩៩ហ្នឹង ។ ចាស, បានខ្ញុំដាក់ពាក្យហ្នឹងហើយបានអង្គការសិទ្ធិមនុស្សខាងអាដហុក ហើយនិងខាងមេធាវីខាងអង្គការជំងឺផ្លូវចិត្ត ជំនួយផ្លូវចិត្តហ្នឹងគាត់នាំពួកខ្ញុំប៉ុន្មានហ្នឹង មកគុកទួលស្លែងហ្នឹង ខ្ញុំក៏ឃើញរូបថតហ្នឹង ។

**ស៖** សូមអភ័យទោសលោកស្រី។ លោកស្រីទទួលរូបថតនេះ នៅក្នុងឆ្នាំ១៩៩៩ តើនរណាគេជាអ្នកប្រគល់រូបថតនេះជូនលោកស្រីនៅក្នុងឆ្នាំនុំង?

**ផ៖** ៩៩អី ឆ្នាំ២០០៩ ។ ចាស រូបថតនេះ ខ្ញុំឃើញនៅឆ្នាំ២០០៩ ខ្ញុំច្រឡំមាត់ ។ ២០០៩ ដែលខ្ញុំដាក់ពាក្យហ្នឹងហើយហ្នឹង មុននឹងបើកសវនាការហ្នឹង ហើយក៏បើកសវនាការហើយទេ ខ្ញុំភ្លេចដែរហើយ ។ តែខ្ញុំយល់-- រកឃើញនៅឆ្នាំហ្នឹង ។ មិនមែនឆ្នាំ៩៩ ទេ ។ ចាស, សូមអរគុណ ។

**ស៖** លោកស្រីបានជម្រាបថា រូបថតមួយនេះ គឺជារូបថតចេញមកពីមន្ទីរស-២១ គឺជាការឆ្លើយដែលតវ៉ាដោយជនជាប់ចោទ ។ ចាតើលោកស្រីបានធ្វើការស្វះស្វែងតាមវិធីណាផ្សេង ដែរឬទេដើម្បីរករូបថត ឬរកព័ត៌មានបងថ្លៃរបស់លោកស្រីនៅស-២១? ឬក៏រកឈ្មោះរបស់គាត់នោះ? តើមានធ្វើរកវិធីណាផ្សេង ដែរឬទេរកឈ្មោះហ្នឹង?

**ផ៖** ចាស, ខ្ញុំឲ្យតែនិយាយហ្នឹងថា ឲ្យដល់ពេលដឹងដំណឹងថាអង្គការផ្សាយមកថាឲ្យខ្ញុំឲ្យមានអ្នកណាមានបងប្អូនជាប់គុកនៅទួលស្លែងហ្នឹង ខ្ញុំក៏ស្វះស្វែងឲ្យខាងសិទ្ធិមនុស្សហ្នឹងជួយរក ។ ហើយព្រោះខ្ញុំ ខ្ញុំក៏អត់បានន័យថា ខ្ញុំខ្វះលុយខ្វះកាក់អីចឹងខ្ញុំអត់បានមកភ្នំពេញមកគុកទួលស្លែងហ្នឹងរករូបថតគាត់ហ្នឹងទេ ។ តែដោយបានខ្ញុំឲ្យអង្គការជួយរកឲ្យ ឲ្យអង្គការនៅសិទ្ធិមនុស្សនៅភ្នំពេញហ្នឹងក៏ឲ្យជួយរកតាំងពីអង្គការអាដហុកនៅកំពង់សោម ឲ្យគាត់ប្រសិនជាបានមកនៅភ្នំពេញក៏ជួយរកឲ្យខ្ញុំផង ព្រោះបងខ្ញុំពិតជាស្លាប់នៅហ្នឹងហើយ ព្រោះគេប្រាប់ថានៅហ្នឹង ខ្ញុំថាអីចឹង ។ ហើយខ្ញុំក៏ឲ្យគាត់ជួយរកទាំងអស់គ្នាហ្នឹងមក ។

ហើយដល់ពេលឆ្នាំហ្នឹងបានអង្គការអាដហុកខាងភ្នំពេញហ្នឹង ហើយនិងខាងអង្គការជំងឺ ផ្លូវចិត្តហ្នឹង ហើយមេធាវីជួយរកអីចឹងទៅក៏ខ្ញុំបានឃើញរូបថតហ្នឹងដូចបំណងរបស់ខ្ញុំអីចឹងមែន ។ នាងខ្ញុំក៏បានឃើញអីចឹងក៏ខ្ញុំបាននិយាយថា បើបានឃើញអីចឹងហើយខ្ញុំក៏សប្បាយចិត្តដែរហ្នឹងយកទៅឲ្យបងស្រីខ្ញុំឲ្យក្មួយៗខ្ញុំបានឃើញ ខ្ញុំក៏អស់ចិត្ត ហើយបើសិនជាមិនបានឃើញរូបថតហ្នឹងក៏ខ្ញុំមិនអស់ចិត្តដែរ ។ តែបានឃើញអីចឹងខ្ញុំក៏អស់ចិត្ត។ ចាស ខ្ញុំអរគុណ ។

**ស៖** សំណួរនេះគឺជាសំណួរចុងក្រោយរបស់ខ្ញុំ ។ ខ្ញុំអាចសរុបមកវិញថា ពីអ្វីដែលលោកស្រីបានជម្រាបនោះ គឺមានតែរូបថតតែប៉ុណ្ណោះដែលលោកស្រីអាចកំណត់ថាបងថ្លៃរបស់លោកស្រីហ្នឹងពិតជាជាប់នៅស-២១ ពិតមែន?

**ឆ៖** ខ្ញុំពិតតែរូបថតហ្នឹងហើយព្រោះអីបានថា ខ្ញុំឃើញៗរូបថតហ្នឹងហើយខ្ញុំក៏កាន់រូបថតហ្នឹងយកទៅសួរដល់អ្នកស្រុកភូមិដល់សួរទៅប្រពន្ធកូនរបស់គាត់ ហើយអ្នកស្រុករបស់គាត់ ហើយពួកម៉ាក់របស់គាត់ជាប្រធានឃុំនៅហ្នឹងទៀត គាត់ក៏ថាពិត ហ្នឹងហើយរូបថតគាត់ហើយ រូបថត បង ស៊ុន ហើយ ។ ខ្ញុំក៏បាន ខ្ញុំក៏អះអាងថាអ៊ីចឹងខ្ញុំក៏ត្រូវបានដាក់ពាក្យបណ្ដឹងមកវាត្រូវអ៊ីចឹងមែនហើយ ។ អ៊ីចឹងខ្ញុំឲ្យឃុំហ្នឹងក៏គាត់ជួយធ្វើឲ្យលិខិតមក ខ្ញុំថាបើអ៊ីចឹងទេ សូមឲ្យជួយបញ្ជាក់មកឲ្យខ្ញុំដើម្បីឲ្យខ្ញុំយកទៅជូនមេធាវី ។ ខ្ញុំថាអ៊ីចឹង ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

ខ្ញុំពុំមានសំណួរផ្សេងទៀតទេ លោកប្រធាន ។ សូមអរគុណ ។

[១៥:២៧:៤៩]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះផ្តល់ឱកាសដល់ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់នូវសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន ។ ដំបូងខ្ញុំសូមនិយាយអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ។ ក្នុងឆ្នាំ១៩៧៧ មានការសម្រិតសម្រាំងកម្មាភិបាលខាងភូមិភាគកណ្ដាល ហើយនិងតំបន់ពិសេស តំបន់ឯករាជ្យសៀមរាបអង្គរ ។ ពេលនោះអចិន្ត្រៃយ៍បញ្ជាឲ្យ តាម៉ុក បញ្ជូនកម្មាភិបាលពីនិរតីទៅគ្រប់គ្រងនៅខាងណោះមែន ។ នេះវាមានព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រមួយគួរឲ្យជឿទុកចិត្ត ។

ទីពីរ ខ្ញុំសូមបញ្ជាក់ពីបញ្ហារូបថត ។ ក្នុងគោលជំហររបស់ខ្ញុំបាទមិនដែលទទួលស្គាល់រូបថតមុនទទួលស្គាល់ឯកសារទេ ។ ទាល់តែទទួលស្គាល់ឯកសារ ឃើញឯកសារច្បាស់ថារបស់មន្ទីរស-២១ បានខ្ញុំទទួលស្គាល់រូបថតជាក្រោយ ។ ឧទាហរណ៍ករណី E2/80 នាង ជិន ម៉េត ។

ទីបី ខ្ញុំសូមនិយាយអំពីឯកសារដែលខ្ញុំខំស្វះស្វែងរកនៅមន្ទីរស-២១ ដែលខ្ញុំសូមអនុញ្ញាតបញ្ចាំងនៅលើអេក្រង់ជូនអង្គសវនាការដូចតទៅ គឺឯកសារលេខ ERN 00329839 សូមបញ្ចាំងជូនដូចតទៅ៖

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការដាក់បញ្ចាំងឯកសារដែលមានលេខ ERN00329839 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។ បញ្ចាំងស្តាយ? អត់ទេ បញ្ចាំងលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

[១៥:៣០:៣០]

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ឈ្មោះ មាស ស៊ុន មានដល់ទៅពីរ ។ ទីមួយ មាស ស៊ុន ឈ្មោះសៅ ហៅ សៅ យោធាវរសេនាតូចកងពល៤៥០ ។ ទីពីរ មាស ស៊ុន អនុលេខាឃុំគ្រួស ស្រុកស្វាយរៀង ភូមិភាគបូព៌ា ។

ដូច្នេះ មាស ស៊ុន ដែលអ្នកស្រី សូ សូង ប្ដឹងនេះជា មាស ស៊ុន ដែលមានស្រុកកំណើត នៅខាងចក្រីទីង ហើយទៅធ្វើជាសមាជិកគណៈកម្មាធិការស្រុកពួក ។ ដូច្នេះ មាស ស៊ុន ពីរដែលស-២១ ទទួលពីខាងលើមក ពីខាងអង្គការមកហើយធ្វើទារុណកម្ម និងកម្ទេចគឺ មាស ស៊ុន របស់កងពល ៤៥០ និង មាស ស៊ុន មកពីខាងភូមិភាគបូព៌ា ។

ដូច្នេះប្លែកអំពីករណីដែលដើមបណ្ដឹងរដ្ឋប្បវេណីលោកប្ដឹង ។ នេះខ្ញុំសូមជូនជាការសង្កេតដោយឈរលើឯកសាររបស់ស-២១ បែបនេះ ។ សូមគោរព បញ្ចប់ ។

[១៥:៣១:៤៤]

**ប្រធានអង្គជំនុំ៖**

សូ សូង ការស្ដាប់សេចក្ដីថ្លែងការណ៍របស់លោកស្រីឃើញថា ដល់ទីបញ្ចប់ហើយ ។ ហើយលោកស្រីអាចទៅកាន់ទីកន្លែងដែលបម្រុងទុកសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ។ ហើយជាបន្តបន្ទាប់គឺលោកស្រី អាចអញ្ជើញចូលរួមក្នុងដំណើរការនីតិវិធីសវនាការ ឬមួយក៏លោកស្រីវិលត្រឡប់ទៅលំនៅដ្ឋានវិញ ឬក៏លោកស្រីទៅទីកន្លែងណាដែលលោកស្រីចង់ទៅ នោះជាសិទ្ធិរបស់លោកស្រី ។

សូមអញ្ជើញទៅកាន់ កន្លែងបម្រុងទុកសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីចុះ ។

ជាកិច្ចបន្ត សូមអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី នេត ផល្លី មកកាន់តុដែលរៀបចំទុកសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះ ។

**ការតាំងសំណួរដោយចៅក្រម៖**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ដើមបណ្ដឹងរដ្ឋប្បវេណី តើលោកឈ្មោះ នេត ផល្លី អ៊ីចឹងពិតមែនដែរឬទេ?

**ឆ៖** បាទ ខ្ញុំឈ្មោះ នេត ផល្លី ពិតប្រាកដមែន ។

**ស៖** លោក នេត ផល្លី តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ធ៖** បាទ ខ្ញុំមានអាយុ ៥២ឆ្នាំហើយ ។

**ស៖** លោកមានទីកន្លែងកំណើតនៅទីកន្លែងណាដែរ?

**ធ៖** បាទ ខ្ញុំនៅភូមិទួលត្រាច ឃុំគងជ័យ ស្រុកអូររាំងឪ ខេត្តកំពង់ចាម ។

**ស៖** តើទីលំនៅសព្វថ្ងៃរបស់លោកនៅទីកន្លែងណា?ហើយលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ធ៖** បច្ចុប្បន្ននៅភូមិទួលត្រាចដដែល ឃុំគងជ័យដដែល ស្រុកអូររាំងឪដដែល មុខរបររកស៊ីធ្វើស្រែចម្ការ ។

**ស៖** តើឪពុកបង្កើតរបស់លោកឈ្មោះអ្វី? ហើយសព្វថ្ងៃនេះគាត់នៅរស់ ឬក៏គាត់ទទួលមរណ-ភាពហើយ?

**ធ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ នេត ផើត គាត់បានអនិច្ចកម្មទៅហើយ ។

**ស៖** ចុះម្តាយរបស់លោកវិញ គាត់ឈ្មោះអ្វីដែរ? ហើយសព្វថ្ងៃនេះគាត់នៅរស់ ឬក៏គាត់ទទួលមរណភាពហើយ?

[១៥:៣៥:៣៥]

**ធ៖** ម្តាយខ្ញុំឈ្មោះ ងួន ទូច គាត់នៅរស់ ។

**ស៖** តើលោកមានបងប្អូនបង្កើតប៉ុន្មាននាក់?

**ធ៖** ខ្ញុំមានបងប្អូនបង្កើតបីនាក់ ។

**ស៖** ចូរលោករៀបរាប់អំពីឈ្មោះបងប្អូនបង្កើតរបស់លោកទាំងអស់ ដើម្បីជូនដល់អង្គសវនាការឲ្យបានស្តាប់ ។

**ធ៖** ទីមួយ បងខ្ញុំឈ្មោះ នេត ប៊ុនធី ។ ទីពីរ ឈ្មោះខ្ញុំ នេត ផល្លី។ ទីបីប្អូនខ្ញុំ ឈ្មោះ នេត វ៉ាលីអូន ។

**ប្រធានអង្គជំនុំ៖**

ជាបន្តសុំផ្តល់វេទិកាទៅមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដើម្បីធ្វើសេចក្តីថ្លែងការណ៍សង្ខេបអំពីអត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណីអំពីមូលហេតុនៃការប្តឹងទាមទារ អំពីទំនាក់ទំនងនៃការប្តឹងទាមទារទៅនឹងអង្គហេតុទៅនឹងបទឧក្រិដ្ឋដែលបានចោទប្រកាន់ចំពោះជនជាប់ចោទ ហើយនិងអំពីភស្តុតាងនានា ឬក៏ទាំងស្ថានភាពនៃព្យសនកម្មដែលកើតមានចំពោះដើមបណ្តឹងរដ្ឋប្បវេណីផង ។

សូមអញ្ជើញ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! បងប្រុសរបស់កូនក្តីរបស់ខ្ញុំ គាត់ឈ្មោះ នេត ប៊ុនធី ត្រូវបានគេឃុំខ្លួន ហើយនិងសម្លាប់នៅស-២១ ។ កាលពីសប្តាហ៍មុនដោយមិនទាន់បានដាក់សំណុំឯកសារយើងបានផ្តល់ឯកសារទាំងឯកសារប្រវត្តិរូបនៅស-២១ របស់ នេត ប៊ុនធី ហើយនិងសេចក្តីប្រកាសរបស់ កែវ សុផាណាកា ជាប្រធានសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដែលបញ្ជាក់ថា ច្បាប់ដើមនៃជីវប្រវត្តិរូបរបស់ នេត ប៊ុនធី នោះនឹងរកឃើញ ត្រូវបានរកឃើញនៅស-២១ នៅក្នុងសប្តាហ៍មុន នៅក្នុងសំណុំឯកសារយើងបានផ្តល់ច្បាប់ចម្លងអំពីសៀវភៅស្នាក់នៅដែលឈ្មោះថា *កាណេឌីវេស៊ីដង់* របស់កូនក្តីរបស់ខ្ញុំ គឺសៀវភៅស្នាក់នៅ គឺឈ្មោះនៅក្នុងសៀវភៅនេះ បានហៅថា ជេត ផល្លី មិនមែន នេត ផល្លី ទេ ហៅ ជេត ផល្លី ។ ហើយខ្ញុំនឹងសួរកូនក្តីរបស់ខ្ញុំថា ហេតុអីបានជានៅក្នុងសៀវភៅស្នាក់នៅនោះ បានដាក់ឈ្មោះថា ជេត ផល្លី វិញ?

ប៉ុន្តែ ទោះជាករណីហ្នឹងក៏ដោយប្រសិនបើយើងពិនិត្យមើលនៅក្នុងសៀវភៅស្នាក់នៅដែលយើងបានដាក់ជូននោះ ។ នៅក្នុងសៀវភៅស្នាក់នៅនោះឃើញឈ្មោះឪពុករបស់គាត់ឈ្មោះ នេត ឆើត ហើយម្តាយរបស់គាត់ ឈ្មោះ នួន ធូ ។ ហើយឈ្មោះរបស់គាត់ គឺដូចគ្នាបេះបិទ ដូចនឹងឪពុកត្រកូលរបស់ឪពុក នេត ប៊ុនធី ដែរ ដែលមានកំណត់នៅក្នុងជីវប្រវត្តិ ប្រវត្តិរូបរបស់ នេត ប៊ុនធី ។ អ៊ីចឹងឯកសារនេះបើយើងមើលទៅ យើងបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណី នេត ផល្លី ឬ ជេត ផល្លី ហើយ នេត ប៊ុនធី ដែលជាជនរងគ្រោះនោះ គឺមានឪពុកម្តាយដូចគ្នាជាអ្នកក្នុងក្រុមគ្រួសារតែមួយ ។

[១៥:៤០:00]

ហើយបានពន្យល់ពីរឿងនេះ ហើយយើងជឿជាក់ថា យើងបានឆ្លើយសំណួរទៅលោកចៅក្រមប្រធាន ហើយខ្ញុំសូមអនុញ្ញាតជម្រាបថា យើងនឹងបន្តការសួរសំណួរទៅកូនក្តីរបស់ខ្ញុំ ។ បន្ទាប់មកបន្ទាប់ពីការសួរឆ្លើយចប់ទៅ កូនក្តីរបស់ខ្ញុំមានសំណើមួយដែលគាត់នឹងលើកឡើងដោយខ្លួនឯង ហើយនិងសូមអនុញ្ញាតសួរសំណួរនេះតាមរយៈលោកប្រធានទៅជនជាប់ចោទនោះ ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងបានសេចក្តីថាកូនក្តីរបស់លោក នេត ផល្លី គឺគាត់លះបង់សិទ្ធិក្នុងការធ្វើសេចក្តីថ្លែងការណ៍។ អ៊ីចឹងមែនទេ?

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធាន គាត់នឹងឆ្លើយសំណួររបស់ខ្ញុំ តាមដែលយើងខ្ញុំស្នើ ។

**ប្រធានអង្គជំនុំ៖**

លោក នេត ផល្លី គឺយល់ព្រមតាមសំណើសុំរបស់មេធាវីតំណាងរបស់លោក ដែលលើកឡើងអម្បាញ់មិញនេះដែរទេ?

**លោក នេត ផល្លី៖**

បាទ, ទទួលបាន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះអង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ដើម្បីតាំងសំណួរជាក់លាក់ចំពោះលោក នេត ផល្លី ដែលជាកូនក្តីរបស់លោក ។ សូមអញ្ជើញលោក អាឡាំង វ៉ែនណឺ ។

**ការតាំងសំណួរដោយមេធាវីដើមបណ្តឹងរដ្ឋវេណី៖**

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន ។ សូមជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី ។

**ស៖** សូមលោកពន្យល់ដោយសង្ខេបជូនតុលាការថា ហេតុអ្វីបានជាឈ្មោះរបស់លោកនៅក្នុងអត្តសញ្ញាណប័ណ្ណ ឈ្មោះថា នេត ផល្លី ប៉ុន្តែសៀវភៅស្នាក់នៅទៅជា ឆើត ផល្លី វិញ សូមលោកពន្យល់ ។

[១៥:៤២:១៧]

**ឆ៖** បាទ, ឈ្មោះដែលបានមានការពាក់ព័ន្ធនេះ គឺរយៈពេលក្នុងការពីខ្ញុំនៅរៀនរហូតដល់ឆ្នាំ១៩៧៥ ហ្នឹង គឺខ្ញុំប្រើឈ្មោះ នេត ផល្លី ដល់ក្រោយរំដោះឆ្នាំ៧៩ នេះ គឺខ្ញុំរវល់ ។ ទីមួយ រវល់ដើររកស៊ីទីពីរ នៅផ្ទះដែលជាគ្រួសារ គាត់មិនសូវបានជាយល់ ។ គាត់និងរដ្ឋអំណាចដែលធ្វើជាសៀវភៅគ្រួសារស្នាក់នៅនេះ ក៏គាត់ធ្វើតាមជាក់ស្តែងឪពុកម្តាយរស់នៅ បែរជាដាក់ឈ្មោះ ឆើត ផល្លី ទៅវិញ ។ តាមពិតពីដំបូងមក គឺឈ្មោះ នេត ផល្លី ។

**ស៖** សូមអរគុណលោក ផល្លី ។ តើលោកអាចជម្រាបប្រាប់តុលាការបានទេថាខ្លួនលោកផ្ទាល់តើលោកធ្វើអ្វីដែរ? ហើយជួបហេតុការណ៍ដូចម្តេចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅអំឡុងឆ្នាំ១៩៧៤ ខ្ញុំបានធ្វើយោធាតំបន់២២, ង១២៤ ភូមិភាគបូព៌ា ។

**ស៖** តើលោកអាចជម្រាបប្រាប់តុលាការបានតទៅទៀតទេ ថាតើបងប្រុសរបស់លោកនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ ថាតើ នេត ប៊ុនធី ជាបងរបស់លោកហ្នឹង គាត់ធ្វើអ្វីដែរ?

**ឆ៖** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បងខ្ញុំតាំងពីឆ្នាំ១៩៧0 គាត់បានចូលបម្រើនៅក្នុងអង្គភាពយោធារបស់ភូមិភាគរហូតមកដល់គាត់ស្លាប់ ឃាត់ខ្លួន ។

**ស៖** ហើយនៅក្នុងឆ្នាំ១៩៧៥ តើលោកដឹងច្បាស់ទេថា តើគេចាត់តាំងឲ្យគាត់ធ្វើអ្វីកាលនោះ?

**ឆ៖** កាលនោះនៅក្នុងឆ្នាំ១៩៧៥ ខ្ញុំ ចំពោះខ្ញុំៗក៏បាននៅភ្នំពេញ ហើយនៅក្នុងឆ្នាំ៧៥ បងខ្ញុំក៏នៅអង្គភាពយោធាដដែល ។

**ស៖** តើក្នុងប៉ុន្មានឆ្នាំចុងក្រោយបន្ទាប់ពីនោះមក គឺ១៩៧៦និង១៩៧៧ តើមានរឿងអ្វីកើតឡើង?

**ឆ៖** លុះដល់ឆ្នាំ១៩៧៨ ទើបបានខ្ញុំទទួលដំណឹងថាគាត់ធ្វើយោធាចូលសមរភូមិប្រយុទ្ធនឹងខ្មាំងត្រូវរបួស ។ ក្រោយមកគាត់ក៏បានសរសេរសំបុត្រមួយច្បាប់មកឲ្យខ្ញុំ តាមរយៈអ្នកជំងឺនៅមន្ទីរពេទ្យ ។ បន្ទាប់មក ជនរូបនេះក៏បានយកសំបុត្រមកឲ្យខ្ញុំ ហើយខ្ញុំក៏បានយកសំបុត្រនោះ ទៅសុំប្រធានកងខ្ញុំដើម្បីសុំទៅមើលរបួសគាត់។ ក្រោយមកប្រធានកងក៏បានអនុញ្ញាតឲ្យខ្ញុំទៅមើល និងសួរសុខទុក្ខគាត់។

[១៥:៤៦:៤0]

**ស៖** តើលោកអាចរៀបរាប់បានទេនៅពេលដែលលោកទៅដល់មន្ទីរពេទ្យបានជួបគាត់ តើលោកជួបគាត់នៅក្នុងសភាពបែបណា? សូមលោករៀបរាប់បន្តិច ។

**ឆ៖** ពេលដែលខ្ញុំទៅដល់ក្នុងស្ថានភាពដែលគាត់ជាអ្នករបួស ។ ទីមួយនឹងចូលទៅដល់ ខ្ញុំឃើញគាត់មានរបួសជាទម្ងន់ ដោយគាត់នឹងត្រូវរបួសបាក់ថ្គាម ហើយក៏គាត់ក៏មិនបាននិយាយអ្វីជាមួយខ្ញុំច្រើនដែរ ពីព្រោះអីខ្ញុំនឹងក៏មានការក្រេវក្រោធនឹកឃើញថា បងខំចូលសមរភូមិ គាត់របួសជាទម្ងន់ ។ ហើយគាត់បងក៏មិនអាចនិយាយមកទាក់ទងជាមួយខ្ញុំបានច្រើនដែរ ដោយគាត់មានរបួសនៅថ្គាមនឹងគាត់ហាមាត់ពុំរួច ។ ហើយក៏ខ្ញុំក៏បាននិយាយសួរសុខទុក្ខគាត់ជាធម្មតា មិនបានរៀបរាប់ច្រើនទេ និងមានការក្រេវក្រោធនៅក្នុងចិត្ត អាក់អួលដើមក ដោយឃើញបងមានរបួសជាទម្ងន់ ។ ហើយបន្ទាប់មកក៏ខ្ញុំបានប្រហែលមួយម៉ោង ក៏ខ្ញុំលាគាត់មកអង្គភាពវិញ ។

**ស៖** តើត្រូវដែរទេ ជាមន្ទីរពេទ្យ ដែលហៅថា មន្ទីរពេទ្យ១៧ មេសា នោះ គឺមន្ទីរពេទ្យរុស្ស៊ី តើមែនឬទេ?

**ឆ៖** បាទ, មន្ទីរពេទ្យហ្នឹង គឺជាមន្ទីរពេទ្យ១៧ មេសា បច្ចុប្បន្នគេហៅមន្ទីរពេទ្យ រុស្ស៊ី ពិតប្រាកដមែន ។

**ស៖** បន្ទាប់ពីទៅជួបគាត់ទីមួយនោះមក តើលោកបានជួបគាត់ទៀតទេ?

**ឆ៖** បាទ, ខ្ញុំបានជួបគាត់ជាលើកទីពីរម្តងទៀត នៅពេលដែលខ្ញុំធ្វើការនៅអង្គភាព ខ្ញុំក៏បានភូតអង្គភាព និងអង្គភាព គឺថ្ងៃ១០ ហ្នឹង គឺគេត្រូវសម្រាក ។ គេត្រូវសម្រាកហ្នឹង ទៅធ្វើពលកម្មការងារសង្គមនិយមហ្នឹង គឺគេទៅធ្វើការបង្កបង្កើនផលនៅកំបូល ។ ដូច្នេះ ខ្លួនខ្ញុំក៏មានការធ្វើពុតជាឈឺថា ខ្ញុំមិនបានទៅទេ សមមិត្តទាំងអស់ ខ្ញុំអត់ស្រួលខ្លួន ។ ហើយក៏ឆ្លៀតពេលនោះ ខ្ញុំក៏បានចេញទៅលួចលាក់ដើម្បីឆ្លៀតពេលទៅសួរសុខទុក្ខរបស់គាត់ ។ ប្រសិនបើជាខ្ញុំសុំគេត្រង់ទៅ គេនឹងមិនអាចឲ្យខ្ញុំទៅជួបទេ ពីព្រោះអីកាលមនោសញ្ចេតនាជំនាន់នោះ គេមិនអាចឲ្យខ្ញុំនឹងទំនាក់ទំនងគ្នាឲ្យបានញឹកញាប់បានឡើយ។ ហេតុដូច្នេះខ្ញុំក៏សម្រេចចិត្តមានការលួចលាក់នឹងទៅលេងគាត់ជាលើកទីពីរ ។

ក្រោយមក ដែលបានខ្ញុំទៅជួបគាត់ជាលើកទីពីរនេះ ខ្ញុំក៏បាននិយាយជាច្រើនជាមួយគាត់ ដោយនិយាយប្រាប់ហេតុផលថា បងនៅបងត្រូវរបួសជាទម្ងន់ ហើយបងត្រូវចំថ្គាម និងបងស្តាប់ខ្ញុំនិយាយមិនសូវបានទៀត ។ ហេតុដូច្នេះ ទៅសុំបងចេញពីពេទ្យទៅត្រឡប់ទៅសុំមេកងបង ឬអង្គភាពកង សុំចូលខាងពិការទៅពីព្រោះអីបងមានរបួសជាទម្ងន់ ។ ហើយបញ្ហាទីពីរ គាត់ក៏បាននិយាយមក ពោលមកខ្ញុំវិញថា លុះត្រាតែទៅដល់អង្គភាពវិញចាំស្នើតាមអូនឯងនិយាយហ្នឹង ។ ហើយក៏គាត់បាននិយាយប្រាប់ខ្ញុំពីរឿងថ្មីមួយទៀត ដែលជារឿងគាត់នឹងត្រូវរៀបគ្រួសារជាមួយនារីម្នាក់ ដែលឈ្មោះ សៀង ឡួន នៅភូមិជាប់ជាមួយនឹងភូមិខ្ញុំនេះ ។ គាត់ក៏បាននិយាយការនឹករលឹកដល់នារីនោះជាប្រចាំ គាត់បានរៀបរាប់នូវទុក្ខសោករបស់គាត់ដែលគាត់នឹងជាគូអនាគតរបស់នារីនោះ ។ ហើយគាត់ក៏បាននិយាយថាត្រឡប់ទៅវិញនឹងអាចនឹងបានរៀបគ្រួសារជាមួយនារីឈ្មោះ សៀង ឡួន ពិតប្រាកដហើយ ។ ពីព្រោះប្រវត្តិរូបដែលគាត់ធ្វើទុកឲ្យនៅម្តាយខ្ញុំ គឺនឹងអាចត្រឡប់ទៅវិញ គាត់នឹងអាច នឹងបានអង្គការត្រូវរៀបគ្រួសារឲ្យគាត់ ។ ការពោលនិយាយគ្នា សាសងគ្នាអស់រយៈប្រហែលពីរម៉ោង ទើបខ្ញុំត្រឡប់មកអង្គភាពខ្ញុំវិញ ។

**ស៖** តើក្រោយពីហ្នឹងមកទៀត តើលោកបានជួបបងប្រុសរបស់លោកទៀតដែរឬទេ?

**ឆ៖** ក្រោយមកទៀត ខ្ញុំទៅជាលើកទីបី ។ ការលួចលាក់របស់ខ្ញុំ គឺនៅមានបន្តដល់លើកទីបី ។ ដប់ថ្ងៃក្រោយមកទៀត ខ្ញុំភូតទៀត ខ្ញុំធ្វើពុតទៀត ។ ខ្ញុំថាដោយខ្ញុំអត់ស្រួលខ្លួន អត់បានទៅធ្វើការពលកម្ម១ខាងបង្កបង្កើនផលទេ ។ ខ្ញុំក៏ទៅស្វែងរកគាត់ ទៅដល់ក្នុងបន្ទប់គាត់ សួរពេទ្យដែលប្រចាំការនៅកន្លែងនោះ តើ--សួរថាតើបងខ្ញុំគាត់ទៅណាហើយ? ចេញទៅ ឬនៅ? ឬប្តូរទីកន្លែង? ពេទ្យនៅកន្លែងក៏បានឆ្លើយថា គាត់ប្តូរកន្លែងហើយ ប៉ុន្តែមិនដឹងទៅខាងណា ។ នៅពេលនោះខ្ញុំក៏មានការនឹកសង្ស័យជាច្រើនជំពូក ។ ទីមួយ ក្រែងគេដូរកន្លែងគាត់ ដោយគាត់របួសរាងធូរបន្តិច ។ ទីពីរ នឹកឃើញគាត់ចេញទៅតែម្តង ឬយ៉ាងម៉េច? ទីបីហ្នឹង នឹកឃើញថា គាត់ទៅនឹង គឺមិនដឹងជាទៅខាងណា? ហ្នឹងសូមអស់យោបល់ត្រឹមហ្នឹង ។

**ស៖** តើត្រឹមត្រូវដែរឬទេ ក្រោយពីហ្នឹងមកគឺលោកមិនដែលរកឃើញ ឬក៏ជួបបងប្រុសរបស់លោកជាថ្មីទាល់តែសោះ? តើត្រូវដែរឬទេ?

**ឆ៖** ពិតជាត្រឹមត្រូវ ។ ក្រោយមក ក៏ខ្ញុំមានការសង្កេតនិងសម្លឹងមើលក្រែងទៅជិតក្តី ឆ្ងាយក្តី តែងតែនឹកគិត ដើម្បីចង់ជួបបងប្អូន ដែលបែកគ្នាយូរ គឺពិតជាអិចឹងមែន ។

[១៥:៥៤:២០]

**ស៖** ហើយនៅដល់ចុងបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យនៅក្នុងខែមករា ឆ្នាំ១៩៧៩ តើលោកអាចជម្រាបតុលាការបានទេថា ក្រៅពីហ្នឹងមកលោកបានព្យាយាមរកបងប្រុសរបស់លោក? ហើយលទ្ធផលនៃការរកហ្នឹងយ៉ាងដូចម្តេច?

**ឆ៖** ក្រោយពីរំដោះឆ្នាំ១៩៧៩ ខ្ញុំក៏បានខឹតខំស្វែងរកបងខ្ញុំជាច្រើនកន្លែង ។ ខ្ញុំទៅរកដល់អមលាំង ។ រហូតទៅដល់ស្រុកលាច ស្រុកបាកាន ស្រុកមោង ស្រុកកោះក្រឡ ភ្នំប៉ាដេ ភ្នំវាយចាប ភ្នំសំឡូត លុះដើររកគាត់ស៊ើបសួរមិត្តជិតខាងទាំងអស់ ក៏មិនបានឃើញមិនបានដឹងឈ្មោះបងខ្ញុំ នេត ប៊ុនធី នេះឡើយ ។

**ស៖** ហើយលោកបានប្រាប់យើង អំពីទីកន្លែងដែលលោកបានទៅរកហ្នឹង ថាតើចំណាយពេលប៉ុន្មានខែ ឬក៏ប៉ុន្មានឆ្នាំដែរគ្រប់ទីកន្លែងដែលលោកបានស្វែងរកនោះ?

**ឆ៖** ស្វែងរកការស្វែងរកនេះ គឺស្វែងរកដោយការសន្សឹម១ គឺខ្ញុំទៅស្នាក់នៅត្រង់នេះបន្តិចត្រង់នោះបន្តិចគ្រប់ស្រុកហ្នឹង គឺរយៈពេលជិតដប់ខែ ដល់ខែពីរ ៧៩ ទៅដល់ខែដប់ ទើបខ្ញុំត្រឡប់មកផ្ទះវិញ ។

**ស៖** នៅពេលនោះ គឺបន្ទាប់ពីដំណើរស្វែងរកហ្នឹង តើលោកនៅសល់មានការសង្ឃឹមក្នុងជីវិត ទេថានឹងអាចជួបគាត់ថ្ងៃណាមួយ?

**ឆ៖** ក្នុងការដើររកនេះក្នុងជីវិតរបស់ខ្ញុំ គឺមានសង្ឃឹម មានសង្ឃឹមថាគាត់នៅរស់ ពីព្រោះអី កាលជំនាន់នោះ មានអ្នករត់ខ្ចាត់ខ្ចាយគ្រប់ទីកន្លែងទាំងអស់ និងគណបក្សហ្នឹងជាច្រើន ។ ខ្ញុំមានគំនិត គិតថាគាត់នៅរស់ហ្នឹង គឺគាត់នឹងចូលទៅខាងជាមួយកងទ័ពខ្មែរក្រហមហ្នឹងវិញមិនដឹង ចូលទៅខាង កងទ័ពណាទៀតសឹងមិនដឹង ពីព្រោះអីនៅខាងលិចប្រទេសមានបក្សហ្នឹងជាច្រើន។ ហើយក្រែងលោគាត់ កប់ខ្លួននៅក្នុងផ្នែកខាងណាមួយ ក៏នៅមានសង្ឃឹមដូច្នេះ ។

**ស៖** ថាតើលោកអាចជម្រាបតុលាការបានទេ នៅពេលណាដែលលោកនៅតែមានសង្ឃឹមរហូត មកនោះ គឺអស់សង្ឃឹម គឺនៅពេលណា? ឆ្នាំណា?

**ឆ៖** ការអស់សង្ឃឹមរបស់ខ្ញុំ គឺក្នុងឆ្នាំ២០០៤ ខែមិថុនា ឆ្នាំ២០០៤ ។ ដោយការអស់សង្ឃឹម នេះ ក្រោយពីអង្គភាពឯកសារកម្ពុជាយកប្រវត្តិរូបរបស់បងខ្ញុំនេះ ឈ្មោះ នេត ប៊ុនធី នេះយកទៅ ប្រគល់ឲ្យឪពុកម្ដាយខ្ញុំ ទើបខ្ញុំបានដឹងថា គាត់ស្លាប់នៅគុកទួលស្លែង ។

**ស៖** តើត្រូវទេ គឺក្នុងរយៈពេល២៥ឆ្នាំ ដែលលោកនៅតែសង្ឃឹមថា អាចនឹងបងរបស់លោកនៅ រស់ តើអ៊ីចឹងមែនទេ?

[១៥:៥៩:១៤]

**ឆ៖** សុំសំណួរម្ដងទៀត ។

**ស៖** តាមពិតខ្ញុំនឹងសួរលោក តើត្រូវទេដែលខ្ញុំអាចសួរលោកថា លោកបានបន្តការសង្ឃឹមហ្នឹង អស់រយៈពេលជាងម្ភៃប្រាំឆ្នាំ ដែលថាបង ប៊ុនធី របស់លោកហ្នឹងនៅរស់រានមានជីវិត តើអ៊ីចឹងឬទេ?

**ឆ៖** បាទ, ខ្ញុំសង្ឃឹមថា គាត់នឹងរស់រានមានជីវិតក្នុងម្ភៃប្រាំឆ្នាំហ្នឹង ។

**ស៖** តើលោកអាចជម្រាបតុលាការនេះដែរឬទេថា នៅក្នុងឆ្នាំ២០០៤ តើលោកប្រតិកម្មយ៉ាង ម៉េចនៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជា មកកន្លែងរបស់លោក ហើយប្រាប់ថាបងរបស់លោកត្រូវ បានគេសម្លាប់ចោលនៅស-២១ ។ នៅពេលនោះតើលោកតតាំងយ៉ាងម៉េច ឬប្រតិកម្មអារម្មណ៍យ៉ាង ម៉េចដែរ?

**ឆ៖** នៅពេលនោះក្រុមគ្រួសារ ឪពុកម្ដាយខ្ញុំ និងរូបខ្ញុំផ្ទាល់ មានការក្ដុកក្ដួលជាខ្លាំង ដោយមាន បងម្នាក់ជាទីស្រលាញ់ដែលត្រូវគេយកគាត់ទៅដាក់នៅស-២១ គឺគុកទួលស្លែងនេះ គឺជាកន្លែងធ្វើទារុណ

កម្មយ៉ាងសាហាវព្រៃផ្សៃបំផុត ដោយកន្លងមានគេនិយាយប្រាប់ថា នៅគុកទួលស្លែងនេះ ការធ្វើទារុណ-កម្មជាធ្ងន់ធ្ងរណាស់ ។ ទារុណកម្មមានតាំងពីដកក្រចក មានតាំងពីចាក់ម្ជុលម្រាមដៃ មានតាំងពីឆក់ខ្សែភ្លើង មានតាំងពីវ៉ៃនឹងដំបង មានទាំងជ្រលក់ទឹក មានតាំងពីច្រកស្បោងកៅស៊ូចូលឲ្យថប់ដង្ហើម ។ នេះហើយដែលធ្វើឲ្យខ្ញុំកាន់តែមានទុក្ខធ្ងន់ថែមទៀត ដោយមានបងម្នាក់ស្លាប់ដោយវេទនាជាទីបំផុត និងមានការក្តុកក្តួលជាខ្លាំងក្នុងចិត្ត ដោយការស្លាប់នេះ លំបាកវេទនាណាស់ មិនមែនដូចជាស្លាប់ធម្មតាទេ គឺស្លាប់នេះគឺស្លាប់ ដោយការធ្វើការធ្វើទារុណកម្មរួចទើបបាននឹងសម្លាប់ ។

**ស៖** តើវាត្រឹមត្រូវដែរឬទេថា លោកបានដឹងថា មិនដឹងថាមានមន្ទីរស-២១នេះតាំងពីមុន មុនពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជានោះ មកប្រាប់លោកអំពីការស្លាប់របស់បងលោក? តើអ៊ីចឹងមែនទេ?

**ឆ៖** កាលណោះខ្ញុំក៏បានដឹងតាមដំណឹង តាមការផ្សាយផ្សព្វផ្សាយតាមវិទ្យុក្តី តាមដែលបងប្អូនដែលមករករូបថតនៅទួលស្លែងក្តី ក៏គាត់បានជួបគាត់ផ្សេងៗទៀត ក៏គាត់បាននិយាយអំពីកន្លែងនេះដែលជាកន្លែងធ្វើទារុណកម្មយ៉ាងសាហាវព្រៃផ្សៃបំផុត បានជាខ្ញុំនឹកឃើញថ្ងៃណាឡើង ពេលណាឡើងនៅគុកទួលស្លែងនេះ ធ្វើឲ្យខ្ញុំអាក់អួលក្នុងចិត្តក្នុងបេះដូងគ្មានថ្ងៃណាបំភ្លេចទេ គឺក្នុងមួយថ្ងៃបើមិនបានអីក៏នឹកឃើញម្តង ឬពីរដងដែរ ដែលជាកន្លែងធ្វើទារុណកម្មនេះ ។

[១៦:០៣:១៧]

**ស៖** លោកបានប្រាប់អំពីប្រតិកម្មរបស់លោកនៅក្នុងឆ្នាំ២០០៤ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមកប្រាប់លោកអំពីព្រឹត្តិការណ៍នៃការស្លាប់របស់បងរបស់លោក។ ថាតើលោកអាចជម្រាបទេនៅពេលនោះឪពុករបស់លោកមានប្រតិកម្មយ៉ាងម៉េចដែរ នៅពេលទទួលដំណឹងពីមជ្ឈមណ្ឌលឯកសារកម្ពុជាបែបហ្នឹង?

**ឆ៖** ក្រោយពីមជ្ឈមណ្ឌលឯកសារកម្ពុជាបានយកប្រវត្តិរូបដែលបងថាស្លាប់នៅទួលស្លែងនេះ ឪពុកម្តាយខ្ញុំមានការយំ នឹករឭក ហើយឪពុកខ្ញុំក៏គាត់បានធ្លាក់ខ្លួនឈឺ ដោយគាត់សម្រានទៅគាត់តែងតែពោលពាក្យថា “អ្ហឹ! កូនប៉ានឹកកូន ប៊ុនធី ណាស់ ពីព្រោះអីនៅគុកទួលស្លែងនោះ គេធ្វើបាបទារុណ-កម្មកូន ប៊ុនធី ខ្ញុំមិនដឹងយ៉ាងណាទេ” ។ គាត់តែងតែពោលពាក្យទាំងព្រឹក និយាយប្រាប់ខ្ញុំ ។ ខ្ញុំក៏មានការក្តុកក្តួលក្នុងចិត្តរហូត នឹកឃើញរហូត ហើយគាត់តែងតែនិយាយ ពីរបីថ្ងៃគាត់និយាយប្រាប់ម្តងពីរបីថ្ងៃគាត់ប្រាប់ម្តង អ្ហឹ! កូនអើយកូន កូនមិនគួររងគ្រោះដោយសារអំពើព្រៃផ្សៃហ្នឹងសោះ ធ្វើបដិវត្តន៍

ហ្នឹងគេដែរ ខុសអីរឿងអី ដែលបានគេយកកូនគាត់ទៅដាក់គុកទួលស្លែង ហើយសម្លាប់ ។ គាត់តែងតែនិយាយហើយគាត់ក៏ធ្លាក់ខ្លួនឈឺបន្តិចម្តងៗ រហូតដល់មួយឆ្នាំក្រោយមកគាត់ក៏បានស្លាប់ចោលរូបខ្ញុំទៅទៀត ។

នេះហើយដែលអំពើព្រៃផ្សៃដ៏ខ្លាំងក្លា មកលើចំពោះរូបខ្ញុំ ធ្វើឲ្យខ្ញុំមានទុក្ខវេទនាជាខ្លាំងក្នុងឆាកជីវិតរបស់ខ្ញុំ ។ នេះហើយរបបកម្ពុជាប្រជាធិបតេយ្យ ដែលខ្លួនខ្ញុំចូលបម្រើដែរតែទីចុងបញ្ចប់បងក៏បម្រើដែរ ក៏បងបានស្លាប់ ប្អូនត្រូវបែកពីបងព្រាត់ប្រាសពីបង ។ ទុក្ខសោករបស់ខ្ញុំមានជានិច្ចចំពោះជីវិតខ្ញុំ ។

**ស៖** មិនមែនលើកទីមួយ ដែលលោកបានចូលក្នុងតុលាការនោះទេ កាលពីប៉ុន្មានខែមុនលោកបានអង្គុយប៉ុន្មានដងនៅខាងក្រោយខ្ញុំនេះ នៅកន្លែងដើមបណ្តឹងរដ្ឋប្បវេណី លោកនៅអង្គុយទីនោះដែលមានអ្នកសួរចម្លើយមកពីមន្ទីរស-២១ ថាតើមានអ្វីកើតឡើងនៅស-២១ ប្រាប់អំពីភាពអមនុស្សធម៌ និងការធ្វើទារុណកម្មផ្សេងៗដែលកើតមាននៅស-២១ ។ អ៊ីចឹងតើលោកអាចជម្រាបបានដែរឬទេ តើលោកមានអារម្មណ៍យ៉ាងម៉េចនៅពេលដែលស្តាប់ឮអ្នកដែលធ្លាប់ធ្វើទារុណកម្មបុគ្គលិកស-២១ មកទីនេះប្រាប់រឿងរ៉ាវទាំងអស់នោះ?

**ឆ៖** ក្នុងការធ្វើទារុណកម្មនៅស-២១ ដែលខ្ញុំបានចូលទៅក្នុងសវនាការហ្នឹង ដែលបានស្តាប់គឺការធ្វើទារុណកម្ម គ្រប់បែបគ្រប់យ៉ាងទាំងអស់ គឺជាការធ្វើទារុណកម្មដល់លើរូបខ្ញុំ និងបងប្អូនទាំងអស់ដែលរងគ្រោះនៅគុកទួលស្លែងនេះ ។ ការធ្វើទារុណកម្មនេះ គឺធ្ងន់ធ្ងរណាស់ ធ្វើឲ្យចិត្តខ្ញុំ អារម្មណ៍ខ្ញុំមិនស្ងប់មិនបំភ្លេចបានទេ ពីព្រោះអីគឺការធ្វើទារុណកម្មនិងការសម្លាប់នេះ ដូចបងប្អូនដែលរៀបរាប់ពីមុនរហូតមកហ្នឹង ក្នុងសវនាការគ្រប់គ្នាហ្នឹង គឺការធ្វើទារុណកម្ម មានតាំងពីដុតមនុស្សទាំងរស់ក្តី ហ្នឹងគឺសាហាវព្រៃផ្សៃជាទីបំផុត ។

[១៦:០៧:៣៧]

**ស៖** តើខ្ញុំនិយាយត្រឹមត្រូវដែរឬទេ កាលពីឆ្នាំមុនលោកខ្លួនឯងបានទៅទួលស្លែង ។ តើពិតដែរឬទេ?

**ឆ៖** បាទ, ពិតមែនខ្ញុំបានទៅទួលស្លែង ។ ខ្ញុំបានទៅទួលស្លែង ខ្ញុំដើរពីខាងឆ្វេងរហូតទៅដល់ខាងកណ្តាល ។ ខ្ញុំឃើញទិដ្ឋភាពកន្លែងធ្វើទារុណកម្មជាច្រើន ។ នៅទីនោះ ខ្ញុំរន្ធត់ក្នុងចិត្ត អាក់អួលក្នុងចិត្តដោយឃើញរបស់របរដែលជាខ្នោះ ជាការប្រដាប់វ៉ៃសួរចម្លើយ និងអ្វីៗផ្សេងៗទៀតជាច្រើន ។ នេះ

ហើយធ្វើឲ្យខ្ញុំនឹកឃើញដល់បងខ្ញុំ ដែលធ្វើទារុណកម្មក្នុងការរបស់ដែលនៅទីនោះ ដូចជាឆក់ខ្សែភ្លើង ដាក់ខ្នោះជើងទាំងពីរ ជ្រមុជទឹក ដកក្រចក ជាច្រើនទៀត ធ្វើឲ្យខ្ញុំរន្ធត់ និងមានការឈឺចាប់ចំពោះការធ្វើទារុណកម្មដ៏សាហាវព្រៃផ្សៃនេះ ហើយខ្ញុំក៏ឡើងទៅលើមើលបន្ទប់របស់បងខ្ញុំគឺបន្ទប់លេខ៣៣ ។ បន្ទប់លេខ៣៣នោះ គឺធ្វើឡើងគេរៀបឥដ្ឋ ដូចគេចិញ្ចឹមជ្រូក ហាក់ដូចជាកន្លែងនោះគឺកន្លែងគេបច្ចា គេធ្វើសម្រាប់ដុតខ្មោចអ៊ីចឹង ។ ខ្ញុំឃើញបន្ទប់គាត់តូចចង្អៀតនេះ គឺធ្វើឲ្យរូបខ្ញុំ មានការក្ដុកក្ដួលនឹកឃើញការលំបាកវេទនារបស់គាត់ ដែលគេដាក់គាត់ដូចជ្រូកមិនឲ្យវិលខ្លួនទៅណារួច ហើយនឹកឃើញថា គេនឹងឲ្យគាត់ងូតទឹកយ៉ាងដូចម្ដេច ហូបបាយយ៉ាងដូចម្ដេច បើជាបន្ទប់ដែលអាក្រក់យ៉ាងនេះ ។ សូមអរគុណ ។

**ស៖** សូមអរគុណលោក ។ មុនពេលដែលលោកប្រាប់យើងខ្ញុំ ចុងក្រោយដែលលោកឃើញបងប្រុសចុងក្រោយនៅមន្ទីរពេទ្យនោះ គាត់ប្រាប់លោកថា គាត់បានស្រឡាញ់ស្ត្រីម្នាក់ឈ្មោះ សៀង ឡួន ហើយគាត់បានសរសេរប្រវត្តិរូបផ្សេងៗ ថាសង្ឃឹមថាអង្គការអាចឲ្យគាត់រៀបការជាមួយស្ត្រីរូបនោះ តើលោកអាចជម្រាបតុលាការបានដែរឬទេ ថាមានអ្វីកើតឡើងចំពោះស្ត្រីដែលគាត់ស្រឡាញ់នោះ?

**ឆ៖** ក្នុងពេលនោះ កន្លងមកនេះ គឺគាត់បាននិយាយរៀបរាប់ប្រាប់ខ្ញុំថា គាត់បានធ្វើប្រវត្តិរូប និងអាចបានរៀបការជាមួយនារី សៀង ឡួន ដែលជាទីស្រឡាញ់ ដែលជាទីនឹករឭក ដែលគាត់ទន្ទេញមិនបាត់ពីមាត់នោះ ។ ក្រោយមកនារី សៀង ឡួន ក៏បានរងចាំអស់រយៈមួយឆ្នាំ ដែលនឹងសង្ឃឹមថា នារីនឹងបានជាគ្រួសារមួយរូប ។

តែផ្ទុយទៅវិញ កម្មអកុសល ដែលផ្ដល់ឲ្យគាត់ទាំងពីរមិនបានជួបជុំគ្នាព្រាត់ប្រាសគ្នា ធ្វើឲ្យនារី សៀង ឡួន មានការក្ដុកក្ដួល លែងចេញពីផ្ទះ អង្គុយសម្ងំសំកុកនៅក្នុងផ្ទះ ។ ដោយការសង្កេតរបស់ខ្ញុំនៅភូមិជិតគ្នារបស់ខ្ញុំ ក៏ខ្ញុំមានអារម្មណ៍នឹកឃើញអាណិតគាត់ និងមានការព្រួយបារម្ភចំពោះគាត់ ដែលគាត់នឹងមានសង្ឃឹមថាបានជាប្ដីប្រពន្ធនឹងគ្នា ។ តែផ្ទុយទៅវិញ គាត់បាននិរាសព្រាត់ប្រាស់គ្នាទៅវិញ ។ នារីនោះមានតែការទឹកភ្នែក និងការគិតព្រួយទុក្ខសោក ថានឹងបានជួបប្ដីដ៏ជាទីស្រឡាញ់ម្នាក់ តែផ្ទុយទៅវិញមិនបានដូចបំណង ។ នារីត្រូវទារុណកម្មផ្នែកផ្លូវចិត្ត មិនអាចបំពេញការងារបានរួសរាយដូចគេអ្នកដទៃឡើយ មានតែការក្រៀមក្រំ មានតែការគិតព្រួយចំពោះខ្លួនដែលនឹងមានសង្ឃឹមទៅថ្ងៃមុខបែរទៅជាកម្មអកុសលព្រាត់គ្នាទៅវិញ ។

**ស៖** គឺខ្ញុំសូមអនុញ្ញាតលោកប្រធាន ប្រហែលជាខ្ញុំសុំមួយវិនាទី ធ្វើការប្រឹក្សាជាមួយមេធាវីខ្ញុំសិន ។ សូមអរគុណលោកប្រធាន ។ ខ្ញុំចង់សួរសំណួរលោកចុងក្រោយ តើលោកអាចពន្យល់បានទេជូនតុលាការនេះ ថាមានអ្វីកើតឡើងចំពោះលោក?

**ឆ៖** ចំពោះរូបខ្ញុំ ចំពោះរូបខ្ញុំផ្ទាល់ គឺមានការរងគ្រោះដោយរបបអំពើព្រៃផ្សៃនេះ ។ ថ្ងៃមួយខ្ញុំក៏បានទៅធ្វើការនៅចម្ការកៅស៊ូ កាប់ដើមកៅស៊ូ ក្រោយមកបន្តិចម៉ោងប្រាំបួនព្រឹក ក៏នាំគ្នាសម្រាក ។ នៅពេលសម្រាកនោះ កម្មករទាំងឡាយក៏បាននិយាយថា នៅកន្លែងនេះ គេវ៉ៃមនុស្សច្រើនណាស់ទាំងខ្សែៗ ។ រូបខ្ញុំបានឮដូច្នេះ ក៏មានការក្តុកក្តួលក្នុងចិត្ត នឹកឃើញថា កន្លែងវ៉ៃនេះ គឺជាកន្លែងវ៉ៃដូចជាវ៉ៃបងខ្ញុំដែរអ៊ីចឹង ។ លុះដល់ដប់ប្រាំនាទីក្រោយមក គឺដំណើរការក្នុងការធ្វើការនៅកន្លែងនោះ ក៏បានចាប់ដំណើរការវិញ គេក៏កាប់ដើមកៅស៊ូ កាប់ដើមកៅស៊ូនោះទៅ ខ្ញុំក៏មានស្មារតីភ្លាំងភ្លាត់នឹកឃើញដល់ការទុក្ខវេទនារបស់បងខ្ញុំនេះ ។ ដល់លុះដើមកៅស៊ូរលំទៅ គេស្រែកឲ្យខ្ញុំរត់ ខ្ញុំក៏មានស្មារតីភ្លាំង រត់ លុះគេថាកៅស៊ូរលំហើយ នាំគ្នារត់ លុះខ្ញុំរត់ទៅ ខ្ញុំទាក់ជើងដួល ដោយខ្ញុំមានអារម្មណ៍នឹក គិតផ្តោតទៅលើបងដែលគេធ្វើរងគ្រោះដូចដែលកម្មករនៅទីនោះគាត់និយាយ ។

លុះដល់ ដើមកៅស៊ូនោះរលំទៅក៏ធ្លាក់មកលើដៃខ្ញុំនេះ ធ្វើឲ្យខ្ញុំពិការរហូតដល់សព្វថ្ងៃនេះ ។ ខ្ញុំពិការទាំងផ្លូវកាយ ពិការទាំងផ្លូវចិត្ត ពិការមួយជីវិតនឹកឃើញមួយជីវិត នូវជីវិតរបស់ខ្ញុំរស់នៅៗដោយទុក្ខវេទនា ទុក្ខលំបាក បងក៏ស្លាប់ ឪពុកក៏ព្រាត់ខ្លួនក៏ធ្លាក់ជាពិការ ការរកស៊ីក៏អស់សង្ឃឹមក្នុងជីវិតទៀត ។ ហេតុដូច្នេះហើយ ជីវិតខ្ញុំមានតែទុកវេទនានេះទេ ដែលនៅតាមអមខ្លួនខ្ញុំជាប់ មានតែការលំបាកនេះទេដែលស្ថិតនៅចំពោះមុខខ្ញុំ ដែលបន្សល់ឲ្យខ្ញុំរហូតមកនេះ ។

[១៦:១៦:៤៦]

**ស៖** សូមអរគុណ ។ តើលោកអាចបញ្ជាក់ទេ លោកអាចទុកការទាមទារសំណងនេះឲ្យមេធាវីរបស់លោក ជាអ្នកចាត់ចែង?

**ឆ៖** បាទ, ខ្ញុំយល់ស្រប ។

**លោក អាឡាំង វែនណឺ៖**

លោក លោកស្រីចៅក្រម យើងខ្ញុំពុំមានសំណួរអ្វីបន្ថែមចំពោះកូនក្តីរបស់ខ្ញុំនោះទេ ។ ដូចដែលខ្ញុំជម្រាបពីមុនអ៊ីចឹង នៅពេលដែលសមស្របកូនក្តីរបស់ខ្ញុំមានសំណើខ្លីតូចមួយ ហើយបន្ទាប់មកមានសំណួរមួយទៅកាន់ជនជាប់ចោទ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញា តើមានសំណួរអ្វីត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ?

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា៖**

**សួរដោយលោក សេងប៊ុន ឃាង៖**

អរគុណលោកប្រធាន ។ ជម្រាបសួរលោក នេត ផល្លី ។

**ស៖** តាមរយៈការជួបបងប្រុសរបស់លោកជាច្រើនដង តើលោកបានដឹងទេថា វត្តមានរបស់បងប្រុសលោកនៅក្នុងមន្ទីរស-២១ហ្នឹង ដោយសារមូលហេតុអីដែរ?

**ឆ៖** បាទ, ខ្ញុំមិនបានដឹងទេ ។

**ស៖** អរគុណ ។ អ៊ីចឹងតើលោកបានដឹងទេថា បងប្រុសរបស់លោកហ្នឹង ត្រូវអ្នកណាជាអ្នកនាំចូលបដិវត្តន៍?

**ឆ៖** គឺប្រធានភូមិ ឈ្មោះ អ៊ឹម ផន ភូមិជត្រាច នោះ ។

**ស៖** បាទ, អរគុណ ។ ចុះលោកស្គាល់ឈ្មោះ ឈូក សៅ ទេ?

**ឆ៖** បាទ ឈូក សៅ ខ្ញុំបានស្គាល់ ។

**ស៖** តើឈូក សៅ នោះមានទំនាក់ទំនងអ្វីជាមួយនឹងបងប្រុសរបស់លោកដែរ?

**ឆ៖** ឈូក សៅ នេះគឺគ្មានទំនាក់ទំនងអ្វីជាមួយបងខ្ញុំទេ គ្រាន់តែកាលក្នុងឆ្នាំ៧០, ៧១អីហ្នឹង គាត់ក៏បានទៅស្នាក់នៅភូមិគេនៅជិតហ្នឹង ខ្ញុំគ្រាន់តែបានតែស្គាល់តែប៉ុណ្ណោះ ។

**លោក សេងប៊ុន ឃាង៖**

អរគុណ ។ លោកប្រធានខ្ញុំអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមានសំណួរ សូមអញ្ជើញ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

មេធាវីការពារមិនមានសំណួរអ្វីសួរទៅដើមបណ្តឹងរដ្ឋប្បវេណីទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញនេះ យើងបានស្តាប់នូវសម្តីរបស់មេធាវី អាឡាំង វ៉ែនណឺ ដែលជាមេធាវីតំណាង

របស់លោក នេត ផល្លី តើលោកមានបំណងចង់ធ្វើការសង្កេត? ធ្វើក៏តាំងសំណួរជាក់លាក់មួយចំនួនចំពោះជនជាប់ចោទតាមរយៈយើងដែលជាប្រធានអង្គជំនុំជម្រះអ៊ីចឹងពិតមែនដែរឬទេ?

**លោក នេត ផល្លី៖**

បាទ, ពិតមែន ។

[១៦:២០:៤៩]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ លោកអង្គជំនុំជម្រះអនុញ្ញាត ប៉ុន្តែអង្គជំនុំជម្រះសូមរំឭកលោកថា ក្នុងនាមលោកជាភាគីក្នុងរឿងក្តី គប្បីការប្រើពាក្យសម្តី ឬក៏ការនិយាយក្នុងលក្ខណៈថ្លៃថ្នូរ មានសីលធម៌ ហើយមានគុណធម៌ខ្ពស់ ស័ក្តិសមគឺជាមនុស្សដែលមានគុណធម៌ មានវប្បធម៌ល្អប្រសើរនៅក្នុងការចូលរួម ចៀសវាងការប្រើប្រាស់វេទិកានៃដំណើរការសវនាការទៅជាវេទិកានៃការសងសឹក លោកយល់ដែរទេ?

**លោក នេត ផល្លី៖**

បាទ, ខ្ញុំយល់ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គជំនុំជម្រះអនុញ្ញាត ។

**លោក នេត ផល្លី៖**

ខ្ញុំសូមសួរថា តើបងប្រុសរបស់ខ្ញុំខុសអ្វីបានជាគេចាប់គាត់មកដាក់គុកទួលស្លែង ហើយសម្លាប់?

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទ យើងផ្ទេរនូវសំណួរនេះទៅដើមបណ្តឹងរដ្ឋប្បវេណីទៅលោក ដើម្បីលោកអាចឆ្លើយនឹងសំណួរនេះបានដែរឬទេ? បើអាចឆ្លើយបាន សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ខ្ញុំសូមនិយាយអំពីចរិតប្រវត្តិសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះកងទ័ពមកពីខាងបូព៌ា១ បក្សកុម្មុយនីស្តកម្ពុជាអត់ជឿទុកចិត្តទេ ។ ចាន់ ចក្រី ដកចេញពីកងពលមកទុកបញ្ឈរជើងនៅសេធិកាតាំងពីអើយម្ល៉េះ ។ នេះជាឧទាហរណ៍មួយ ហើយការចាប់សម្រិតសម្រាំងកងទ័ពមកពីខាងបូព៌ា ក៏ចេះតែមានជាបន្តបន្ទាប់ ក្រោយពី ឃឹម សម្បត្តិ បោកគ្រាប់បែកនៅក្រោយព្រះបរមរាជវាំង នៅថ្ងៃ៤មេសា ១៩៧៦ ។ រហូតដល់ចាប់ ចាន់ ចក្រី ចូលស-២១ ។ ចុងបញ្ចប់យកកង

ទ័ពពីបូព៌ា យុទ្ធជនមកពីបូព៌ាយកមកឲ្យស-២១ កម្ទេច ទាំងឈុតៗ ។ នេះវាជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ក្នុងហ្នឹង នេះគឺខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ ។ ហើយដោយឡែក បើសិនជាខ្ញុំមើលក្នុងបណ្ណសាលាប័ត្រឯកជន ដែល ស-២១ធ្វើ ក្នុងករណីឈ្មោះលោក ប៊ុនធី មិត្តប៊ុនធី នេះ មិត្តប៊ុនធី ចូលមកដល់ស-២១ នៅថ្ងៃ២៤ ខែធ្នូ ១៩៧៨ ។ ដូច្នេះ ចូលនៅក្នុងរយៈកាលចុងក្រោយបំផុតដែលបក្សកុម្មុយនីស្តកម្ពុជាចាប់កងបូព៌ា មកទាំងឈុតៗ ហើយយកទៅកម្ទេច ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណោះ ដោយគោរព ។

[១៦:២៤:១២]

**ប្រធានអង្គជំនុំ៖**

លោក នេត ផល្លី តើមានសំណួរអ្វីទៀតទេ សូមអញ្ជើញ ។

**លោក នេត ផល្លី៖**

បាទ, ខ្ញុំមានចង់បង្ហាញនៅរូបថតរបស់បងខ្ញុំនេះ គឺហាក់ដូចជាបងខ្ញុំដែលនៅអង្គុយក្បែរខ្ញុំដូច្នេះ ដែលនៅក្នុងតុលាការ បងខ្ញុំនឹងឃើញតុលាការដែលកាត់ទោសអ្នកជាប់ចោទ ។ បងខ្ញុំបានស្ងប់ចិត្ត ដោយមានតុលាការកម្ពុជានិងអន្តរជាតិ ។ បងខ្ញុំដែលមានវិញ្ញាណក្ខន្ធ ដែលបានស្លាប់នៅក្នុងស-២១នេះ សូមបងដឹងឮៗ គេបានកាត់ទោសជូនបងហើយ ។ កាលពីមុនគេយកបងចូលគុកទួលស្លែង គេឃ្លុំមុខ គេយកបងទៅសម្លាប់ក៏ឃ្លុំមុខ ។ ឥឡូវនេះ តុលាការគេបើកមុខឲ្យឃើញអ្នកដែលប្រព្រឹត្តអំពើព្រៃផ្សៃ ហើយ ។ សូមបង វិញ្ញាណក្ខន្ធស្ថិតនៅជាមួយខ្ញុំរៀងរហូត និងស្ថិតនៅក្នុងរូបថតនេះជារហូត ដើម្បីខ្ញុំ គោរពបង ធ្វើបុណ្យឧទ្ទិសកុសលជូនបង ធ្វើអ្វីៗគ្រប់ពេលវេលាជូនបង ។ បើខ្ញុំរកសាកសពនោះខ្ញុំ មិនដឹងទៅរកទីណាទេ មានតែរូបថតនេះ ដែលជាសាក្សីនិងជំនួសដែលឆ្អឹងដែលអ្នកគេសម្លាប់បង បង ដែលត្រូវគេសម្លាប់នោះមិនដឹងមួយណាទេ ។ សូមអស់យោបល់ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយករូបថតពីដៃដើមបណ្តឹងរដ្ឋប្បវេណីហើយដាក់បញ្ចាំងនៅម៉ាស៊ីនស្លាយ ដើម្បី បង្ហាញនៅក្នុងកញ្ចក់អេក្រង់ទូរទស្សន៍ជូនភាគី និងសាធារណជនបានឃើញនូវរូបថតរូបរបស់បងដើម របស់បណ្តឹងរដ្ឋប្បវេណីរូបនេះ ។

បានហើយសូមបង្ហាញទៅរូបភាពប្រក្រតីឡើងវិញ ។ ជាបន្តនេះ អង្គជំនុំជម្រះផ្តល់ឱកាសដល់ ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។

សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ដំបូងខ្ញុំសូមបញ្ជាក់ម្តងទៀតថា ខ្ញុំសូមទទួលស្គាល់ថាមិត្ត នេត ប៊ុនធី នេះមករងគ្រោះស្លាប់នៅមន្ទីរស-២១ មែន ។ ចូលមកដល់មន្ទីរស-២១ នៅថ្ងៃ២៤ ខែធ្នូ ១៩៧៨ នេះពិត ។ ហើយរឿងរ៉ាវជាប្រវត្តិសាស្ត្ររវាងបក្សកុម្មុយនីស្តកម្ពុជា និងកងទ័ពបូព៌ាខ្ញុំបានបញ្ជាក់ជូនអង្គសវនាការអម្បាញ់មិញហើយ ខ្ញុំអត់និយាយតទៅទៀតទេ ។ ទុក្ខសោករបស់យុទ្ធជននិងកម្មាភិបាលដែលប្រតិបត្តិការនៅខាងភូមិភាគបូព៌ាធំធេង ។ ទុក្ខវេទនាដែលលោក នេត ផល្លី ហៅ ឆើត ផល្លី ធ្វើសក្ខីកម្មនៅមុខអង្គជំនុំជម្រះនេះជាផ្នែកមួយនៃទុក្ខសោករបស់យុទ្ធជន និងកម្មាភិបាលភូមិភាគបូព៌ា ពីថ្ងៃ ១៧ មេសា រហូតដល់ថ្ងៃ៧ មករា ១៩៧៩ ។ ខ្ញុំសង្កេតឃើញសក្ខីកម្មក្នុងរយៈកាលនេះឈរនៅលើសេចក្តីពិតជាមូលដ្ឋាន ។ ដោយឡែកសក្ខីកម្មដែលលោក នេត ផល្លី ទទួលក្រោយមកវាជាការទទួល ឮពីគេ ភ្នែកគេអ្នកឃើញ លោកជាអ្នកឮ អានេះវាចូលក្នុងបញ្ហាមួយផ្សេងទៅទៀត ។

ខ្ញុំសូមសរុបសក្ខីកម្មរបស់លោក ផល្លី ជាពីរចំណែកយ៉ាងនេះ ។ សូមបញ្ជាក់ជូនតុលាការដោយគោរពប៉ុណ្ណេះ ។

[១៦:៣០:០០]

**ប្រធានអង្គជំនុំ៖**

លោក នេត ផល្លី ដំណើរការនៃការស្តាប់សេចក្តីថ្លែងការណ៍របស់លោក ក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណី ឃើញថាដល់ទីបញ្ចប់ហើយ ។ ហើយក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសូមជម្រាបថា លោកមានសិទ្ធិនៅក្នុងការចូលរួមនៅក្នុងដំណើរការសវនាការចាប់ពីថ្ងៃស្អែកបន្តទៅទៀត ឬក៏លោកទៅកាន់ទីកន្លែងណាដែលលោកចង់ទៅ នោះជាសិទ្ធិរបស់លោក ។

ឥឡូវនេះមុននឹងប្រកាសផ្អាកដំណើរការសវនាការសម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះសូមប្រកាសនូវសេចក្តីសម្រេចដោយផ្ទាល់មាត់អំពីការកែប្រែនូវកាលវិភាគ ក្នុងការស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានអង្គជំនុំជម្រះសម្រេចអញ្ជើញមកធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះ ដោយហេតុថាប៉ុន្មានថ្ងៃនេះអង្គជំនុំជម្រះបានស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឃើញថា មានការជឿនលឿនយ៉ាងច្រើនធៀបទៅនឹងពេលវេលាដែលបានគ្រោងទុក ។

ទន្ទឹមនឹងនេះ ក៏មានដើមបណ្តឹងរដ្ឋប្បវេណីខ្លះបានលះបង់សិទ្ធិនៅក្នុងការចូលរួមដើម្បីធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះ ។

ហើយម្យ៉ាងទៀតដើម្បីពន្លឿននីតិវិធីនៃដំណើរការសវនាការ និងជាការជម្រាបជូនដំណឹងជាមុនដល់គូភាគី និងសាធារណជនបានជ្រាបអំពីការកែប្រែនូវកាលវិភាគសម្រាប់កោះអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី ដែលនៅសេសសល់មកថ្លែងការណ៍ អំពីទុក្ខសោករបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះដូចខាងក្រោយមនេះ ។

សម្រាប់កម្មវិធីសវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះកោះអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូប គឺទីមួយ ដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង វ៉ាន់ឌី ។ ទីពីរ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ ស៊ុន្ទី ។ ទីបីដើមបណ្តឹងរដ្ឋប្បវេណី ភឹង ហ្គុតស៊ុនថារី ដែលជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមពីរ ដើម្បីមកធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃស្អែក ។

នៅថ្ងៃព្រហស្បតិ៍ ទី២០ ខែសីហា ឆ្នាំ២០០៩ គឺថ្ងៃខានស្អែកអង្គជំនុំជម្រះធ្វើការកោះអញ្ជើញនូវដើមបណ្តឹងរដ្ឋប្បវេណី ទីមួយគឺ ឈិន ណាវី, ទីពីរ ជុំ ស៊ីវ៉ាត់ និងទីបី អង្គជំនុំជម្រះនឹងស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អ៊ូ សាវរិត ដោយការចូលរួមពីចម្ងាយ *វីដេអូ ខនហ្វរិន* ដែលនឹងប្រព្រឹត្តទៅនៅរសៀលថ្ងៃខានស្អែក ។

និងសម្រាប់កម្មវិធីសប្តាហ៍ក្រោយ នៅថ្ងៃច័ន្ទ ទី២៤ ខែសីហា កោះអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី ទីមួយគឺ តូច មុន្និន, ទីពីរ រស់ មេន , ទីបី ជុំ នៅ ដែលជាមេធាវី ដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន ។ ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលជាជនជាតិអាមេរិកាំង អង្គជំនុំជម្រះនឹងស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ចេម ជេសប្រ្វេ នៅថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០៩ ។

អាស្រ័យហេតុនេះសូមភាគីនិងសាធារណជនបានជ្រាប ។ ហើយអង្គជំនុំជម្រះសង្ឃឹមជឿជាក់លើកិច្ចសហការពីមេធាវី អ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីប្រឹងប្រែងនៅក្នុងការរៀបចំដំណើរការចូលរួមនៅក្នុងសេចក្តីថ្លែងការណ៍តាមកាលបរិច្ឆេទនៃដំណើរការសវនាការដែលមានការប្រែប្រួលនេះ ។ ហើយអង្គជំនុំជម្រះប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តនៅថ្ងៃស្អែក និងស្តាប់សេចក្តីថ្លែងការណ៍នៅដើមបណ្តឹងរដ្ឋប្បវេណីដូចបានជម្រាបជូនអម្បាញ់មិញនេះ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំជនជាប់ចោទមកកាន់សាលសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង ១៦:៣៦នាទី]*